01108472 E1/314.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jun-2015, 15:28
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី២៩៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី

*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក វិុចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក កែវ គីន (2-TCW-910) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក កែវ គីន** (2-TCW-910)

សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី ..........ទំព័រ ៥

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ..........ទំព័រ ១៧

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ..........ទំព័រ ២៥

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី..........ទំព័រ ៣៧

សួរដោយលោក គង់ សំអុន ផ្តើមពី ..........ទំព័រ ៥៦

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី..........ទំព័រ ៦៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តស្ដាប់សក្ខីកម្មសាក្សី កែវ គីន។ ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរ-ការសវនាការនៅថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក កែវ គីន។ សាក្សីមានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការនេះ។ ថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCW-932។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិពន្ធ ឬញាតិលោហិតជាមួយនឹងជនជាប់ចោទពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅព្រឹកនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៦:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ជា ស៊ីវហ័ង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥

ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥ ដែលបានកត់សម្គាល់ស្ថានភាពសុខភាពរបស់ នួន ជា ថាមានអាការៈឈឺចង្កេះខ្លាំង និងវិលមុខពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការ ពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៧:៥៨]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសុំសួរទៅភាគីថា កាលពីម្សិលមិញ អង្គជំនុំជម្រះបានជម្រាបជូនដំណឹងទៅភាគីអំពីការកែប្រែនូវកាលវិភាគសវនាការមួយចំនួននៅចុងសប្តាហ៍នេះ ហើយនិងដើមសប្តាហ៍ក្រោយ ហើយដើម្បីច្បាស់លាស់នោះថា តើមាន -- តើភាគីណាចង់មានមតិយោបល់អ្វីដែរទេលើការដែលអង្គជំនុំជម្រះបានធ្វើការកែប្រែ កែសម្រួលនូវកាលវិភាគសវនាការរបស់ខ្លួនមួយចំនួនសម្រាប់ចុងសប្តាហ៍នេះ និងដើមសប្តាហ៍ក្រោយនេះ?

សូមអញ្ជើញ!

[០៩:០៩:២៥]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរកាលវិភាគ យើងបានទទួលដំណឹងកាលពីម្សិលមិញ គឺនៅម៉ោងបួនកន្លះ គឺមានការផ្លាស់ប្តូរពាក់ព័ន្ធនឹងសាក្សី។ នៅក្នុងកាលវិភាគនេះ ខ្ញុំគិតថាយើងអាចចាប់ផ្តើមសាក្សីបន្ទាប់នៅពេលព្រឹកស្អែក ដើម្បីឲ្យភាគីដែលមានវត្តមាននៅទីនេះមានពេលវេលាបន្តិច ដើម្បីអាចសួរទៅសាក្សី កែវ គីន រូបនេះ។ នេះជាការសំណើរបស់យើង គឺៗដើម្បីឲ្យយើងមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំសម្រាប់សាក្សីបន្ទាប់។ ដូច្នេះសូមឲ្យចាប់ផ្តើមសាក្សីបន្ទាប់នៅព្រឹកស្អែកលោកប្រធាន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមជម្រាបសួរលោកប្រធាន។ សូមអរគុណដែលឲ្យយើងផ្តល់យោបល់ចំពោះបញ្ហានេះ។ ចំពោះខ្ញុំៗ អត់មានការជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទេ ខ្ញុំគ្រាន់តែសុំឲ្យមានពេលវេលាបន្ថែមបន្តិចសម្រាប់ការដាក់ឯកសារនៅក្នុងអ៊ីនធីហ្វេស ពីព្រោះថាយើងមានពេលខ្លីពេក យើងនឹងអាចផ្ញើបញ្ជីឯកសារដែលយើងចង់ប្រើប្រាស់។ អ៊ីចឹងសូមឲ្យអង្គជំនុំជម្រះមានភាពបត់បែនបន្តិច។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:១០:៥៨]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ យើងយល់ថា គឺមានការប្រជុំជាមួយនឹងកូនសិស្សនៅថ្ងៃស្អែកចាប់ផ្តើមនៅម៉ោងដប់។ ដូច្នេះខ្ញុំចង់ដឹងថា តើវាប៉ះពាល់យ៉ាងណាដែរជាមួយកាលវិភាគនៃសវនាការរបស់យើងនៅស្អែកព្រឹក?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះមានបំណងជម្រាបជូនរឿងនេះដែរ ប៉ុន្តែចង់គិតថា ស្តាប់មតិយោបល់ភាគីសិន។ អង្គជំនុំជម្រះបានពិភាក្សាគ្នារួចហើយ ថានឹងជូនដំណឹងដល់ភាគីថា នៅព្រឹកថ្ងៃស្អែកហ្នឹង អង្គជំនុំជម្រះមិនធ្វើសវនាការទេ គឺសវនាការធ្វើនៅវេលារសៀល។ អ៊ីចឹងហើយគឺរសៀលនេះទំនងជាសាក្សីដែលមានរហស្សនាម 2-TCW-932 នេះយើងធ្វើតែមួយ*សេសស៊ិន*ទេ។ បើសហព្រះរាជអាជ្ញា

ដំណើរការនោះ គឺតែមួយ *សេសស៊ិន*ប៉ុណ្ណោះ។ ក្រៅពីនុំងយើងមានពេលមួយព្រឹកបន្ទាប់សម្រាប់ធ្វើការងារនេះ ហើយនិងរសៀលថ្ងៃសុក្រ។ ហើយពីនោះយើងមានពេលសម្រាករហូតដល់ថ្ងៃចន្ទ បានយើងបន្តបញ្ចប់។ ហើយនេះជាបញ្ហាដែលថា វាមានការផ្លាស់ប្តូរកាលវិភាគមួយចំនួនហ្នឹង វារួមទាំងបញ្ហានេះផងដែរ បញ្ហាខាងរដ្ឋបាលយកទីនេះធ្វើសិក្ខាសាលានៅព្រឹកថ្ងៃស្អែក។

ម៉េចទៅខាងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិមានអីផ្លាស់ប្តូរទេ បន្ទាប់ពីដឹងថា នៅថ្ងៃស្អែកអង្គជំនុំជម្រះមិនធ្វើសវនាការនៅពេលព្រឹក?

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:១២:៥៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន យើងអត់ដឹងផងក្នុងអ៊ីម៉ែលដែលយើងទទួល គឺថាអត់មានប្រាប់ពីការប្រែប្រួលម៉ោងសម្រាប់ស្អែកព្រឹកទេ។ ខ្ញុំមិនដឹងថា តើវាមានឥទ្ធិពលអ្វីប៉ះពាល់ ឬក៏អត់ទេ? ក៏ប៉ុន្តែខ្ញុំគិតថា យើងអាចចាប់ផ្តើមស្អែកនៅរសៀល ដើម្បីកុំឲ្យមានបញ្ហាប៉ះពាល់ទៅដល់កាលវិភាគ។ អ៊ីចឹងក៏អត់មានបញ្ហាអីដែរលោកប្រធាន។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយ យើងគោរពតាមក៏ប៉ុន្តែយើងមិនបានដាក់ឯកសារនៅក្នុងអ៊ីនធីហ្វេសសម្រាប់សាក្សីបន្ទាប់ដែលចាប់ផ្តើមនៅស្អែករសៀលទេ។ អ៊ីចឹងសូមឲ្យអង្គជំនុំជម្រះនិងភាគីមានភាពបត់បែនផង ពីព្រោះថាយើងអត់ទាន់បានជូនដំណឹងទៅដល់មេធាវីការពារក្តីសម្រាប់ការដាក់ឯកសារពាក់ព័ន្ធនឹងសាក្សីបន្ទាប់នេះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះនឹងពិនិត្យពិចារណាបន្ថែមទៀតលើបញ្ហានេះ ហើយនិងជម្រាបជូនដំណឹងភាគីនៅក្រោយពីសម្រាកនៅក្នុងវគ្គសវនាការទី១ ព្រឹកនេះ។

បាទ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

[០៩:១៤:៣៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានចំណុចតូចមួយដើម្បីសុំការបំភ្លឺ។ តើយើងនៅសល់ពេលប៉ុន្មានទៀតលោកប្រធាន? យើងមានរហូតទៅដល់ពេលឈប់សម្រាកម៉ោងដប់ ដប់នាទី ជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏យើងមានសិទ្ធិមានពេលវេលាបន្ថែមទៀតសម្រាប់សួរសាក្សីរហូតទៅដល់ម៉ោងដប់មួយ? នេះជាសំណើសុំការបំភ្លឺពីអង្គជំនុំជម្រះ។ ដូច្នេះវាអាស្រ័យទៅតាមការសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងសាក្សីបន្ទាប់។ ដូច្នេះសូមឲ្យអង្គជំនុំជម្រះបញ្ជាក់ឲ្យបានច្បាស់នៅពេលនេះមុននឹងខ្ញុំចាប់ផ្ដើមសួរសាក្សីរូបនេះ ដើម្បីឲ្យយើងអាចសម្របខ្លួនតាមបាន។

**ប្រធានអង្គជំនុំ៖**

ភាគីម្ខាងៗមានពេលពីរវគ្គនៃសវនាការក្នុងការសួរសាក្សីរូបនេះ។ ម្សិលមិញមានការលើសខ្វះបន្តិចបន្តួច អង្គជំនុំជម្រះបានបំពេញបន្ថែមរួចទៅហើយ គឺ១០នាទី។ អ៊ីចឹងម្សិលមិញអស់មួយវគ្គសវនាការហើយ។ ភាគីតំណាងសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានតែមួយវគ្គ នេះទៀតទេ។ ឥឡូវនេះដោយសារពេលវេលាអាចច្រើន គឺអង្គជំនុំជម្រះនឹងជូនរហូតត្រឹមម៉ោងដប់ ដប់ប្រាំនាទី សម្រាក។

[០៩:១៦:០៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សីខ្ញុំហ្នឹងសួរសំណួរមួយចំនួន ពាក់ព័ន្ធហ្នឹងប្រធានបទពីរជាសំខាន់។ ទី១ គឺពាក់ព័ន្ធទៅហ្នឹងការចាប់ខ្លួននៅការដ្ឋាន ដែលលោកបានឃើញ និងទី២ ខ្ញុំនឹងនិយាយអំពីលក្ខខណ្ឌការងារកម្មករដែលធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ ខ្ញុំសូមឲ្យលោកស្ដាប់សំណួរឲ្យបានច្បាស់ ហើយឆ្លើយឲ្យបានច្បាស់ៗ។ ជាដំបូង ខ្ញុំនឹងអានសម្រង់បី នៃចម្លើយរបស់លោក នៅក្នុងកំណត់ហេតុ E3/5273។ ក្នុងនោះលោកនិយាយអំពីការចាប់ខ្លួនកម្មករនៅការដ្ឋាន។ សម្រង់ទី១ គឺនៅទំព័រ៥ ជាភាសាខ្មែរ, ទំព័រ៤ ជាភាសាអង់គ្លេស និងទំព័រ៤ ជាភាសាបារាំង។ "ភាគច្រើនគឺមកពីភូមិភាគបូព៌ា មនុស្សខាងអ្នកបូព៌ាត្រូវបានសម្លាប់ខ្លួនច្រើនជាងអ្នកផ្សេង។ ខ្ញុំឃើញមនុស្ស គេចងអ្នកធ្វើ -- ខ្ញុំឃើញគេចងអ្នកធ្វើការនៅការដ្ឋានព្រលានយន្តហោះ ដែលមកពីភូមិភាគបូព៌ាម្ដង៣០នាក់ ដាក់ឡានចិនយក

ទៅភ្នំពេញ ព្រោះឃើញឡានចេញទៅតាមផ្លូវជាតិលេខ៥ ទិសទៅភ្នំពេញ។" នេះជាសម្រង់ទី១។

[០៩:១៧:៤១]

សម្រង់ទី២ គឺនៅទំព័រ៥ ជាភាសាខ្មែរ, ៥ ជាភាសាបារាំង និង៤ ជាភាសាអង់គ្លេស។ គេសួរសំណួរលោកដូចតទៅ៖ "តើលោកដឹងទេថា ហេតុអ្វីបានជាគេយកមនុស្សភូមិភាគបូព៌ា មកធ្វើព្រលានយន្តហោះនេះ? ហេតុអ្វីបានគេចាប់ចងមនុស្សទាំងនេះដាក់តាមឡានយកទៅភ្នំពេញ?" ពេលនោះលោកឆ្លើយដូចតទៅ៖ "ខ្ញុំបានឮគេនិយាយថា ពួកគេជាគិញ កា.ហ្សេ.បេ. ឬ សេ.អ៊ី.អា.។ គេយកពួកនេះមកលត់ដំ ពីព្រោះពួកគេត្រូវគេចោទថា ក្បត់ជាមួយអង្គការ។ ខ្ញុំមិនដឹងពីមូលហេតុដែលគេចាប់ចងពួកនេះទេ ប៉ុន្តែខ្ញុំឃើញផ្ទាល់នឹងភ្នែកចំនួនពីរបីដង ដោយគេភ្ជង់កាំភ្លើង និងចងរុញដាក់ឡាន ដឹកចេញទៅ។" សូមបញ្ចប់ការដកស្រង់។

សម្រង់ទី៣ គឺនៅទំព័រ៥ ទាំងបីភាសាតែម្ដង។ លោកបានឆ្លើយដូចតទៅ៖ "ខ្ញុំបានទៅលេងនៅមន្ទីររបស់ ល្វៃ នៅក្នុងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ហើយឃើញគេភ្ជង់កាំភ្លើង និងចងមនុស្សនៅទីនោះ ដែលគេធ្វើឡើងនៅម៉ោងប្រាំមួយ ឬប្រាំពីរយប់។ ក្នុងពេលចាប់ចងមនុស្សតែងតែមានវត្តមានរបស់ ល្វៃ"។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំហ្នឹងសួរសំណួរដើម្បីសុំការបំភ្លឺពីលោក ពាក់ព័ន្ធទៅនឹងចម្លើយនេះ។ តើលោកដឹងទេ ថាគេនិយាយអ្វីខ្លះទៅកាន់អ្នកភូមិភាគបូព៌ា ដែលត្រូវបានចាប់ខ្លួន និងចាប់ចង? គេប្រាប់អ្នកទាំងអស់ហ្នឹងយ៉ាងម៉េច ដើម្បីកុំឲ្យអ្នកទាំងអស់នុំងតដៃ ហើយមិនព្យាយាមរត់គេចនោះ?

[០៩:១៩:៥៣]

**លោក កែវ គីន៖**

**ឆ៖** បាទ ខ្ញុំឃើញគេកោះហៅប្រជុំអីចឹងទៅ គេភ្ជង់កាំភ្លើងចាប់ចង។ ហើយពួកហ្នឹងអត់មានដឹងខ្លួនទេ វាចូលក្នុង ដូចថាក្នុងមន្ទីរ គេបិទទ្វារជិត រួចរត់ទៅណារួច ព្រោះកងការពារគេនៅជុំវិញ។ រួចគេចងដាក់ឡានទៅ ជួនកាលម្យប់ហ្នឹងពីម៉ោងប្រាំមួយ ម៉ោងប្រាំពីរមានពីរឡាន បីឡាន តែមិនដឹងដឹកទៅឯណា ខ្ញុំអត់បាន -- ឃើញតែដឹកចេញ តាមមកតាមផ្លូវជាតិលេខ៥ហ្នឹង ដឹកចេញពីព្រលានហ្នឹង។ ឃើញតែប៉ុណ្ណឹង។ រួចពេលចងពេលអីហ្នឹង ឃើញវត្តមាន ល្វៃ ហ្នឹងគាត់នៅហ្នឹងជាប់ អត់មានមនុស្សពីណាទៀតក្រៅពីគាត់ហ្នឹង ហើយនិងកងការពារគាត់ហ្នឹង។ ហើយចាប់រួច លើកដាក់ឡានបោះដាក់ឡាន បើកឡានចេញមក ឡានចិន អាកង់ប្រាំមួយហ្នឹង ខ្ញុំក៏មិនសូវស្គាល់ប៉ុន្មានដែរ។ ខ្ញុំមើល

ឃើញពីចម្ងាយ អត់ប៉ានចូលទៅជិតគេ ដល់ឃើញគេយ៉ាងអ៊ីចឹង ខ្ញុំរត់មកវិញមក។ តែមិនដឹងគេដឹកយកទៅខាងណា ខ្ញុំអត់បានដឹង។ ឃើញដឹកម្តងពីរឡាន បីឡានអ៊ីចឹង។ ពួកដែលគេចាប់ចងហ្នឹង ច្រើនតែភូមិភាគបូព៌ាហ្នឹង។ ពួកហ្នឹងគេចោទថាក្បត់ ចោទថាស្អីឯណា ខ្ញុំក៏អត់សូវដឹងអារឿងហ្នឹងដែរ។ គេចោទថាគិញ កា.ហ្សេ.បេ, សេ.អ៊ី.អា អីហ្នឹង ឮតែគេនិយាយអ៊ីចឹង។

[០៩:២១:៣០]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំមានសំណួរជាក់លាក់តែម្តង សូមឲ្យលោកឆ្លើយខ្លីៗ។ ឡានដែលដឹកអ្នកដែលត្រូវបានគេចាប់ចងហ្នឹង ជាឡានរបស់កងពល៥០២ មែនទេ?

**ឆ៖** បាទ ជាឡានកងពលរបស់៥០២ហ្នឹង។ អត់មានឡានណាទេ ប៉ុនឡានហ្នឹង ខ្មែរបើកដែរ។

**ស៖** តើអ្នកបើកឡានហ្នឹង ក៏មកពីកងពល៥០២ ដែរមែនទេ? ហើយអ្នកបើកឡានហ្នឹងក៏ជាអ្នកធ្វើការនៅការដ្ឋានសាងសង់ព្រលានយន្តហោះហ្នឹងដែរ មែនទេ?

**ឆ៖** បាទ អ្នកបើកឡាននៅកង៥០២ហ្នឹងដូចគ្នា។ រួចអ្នកដែលបើកឡានហ្នឹង នៅសាងសង់ហ្នឹងដែរ ហើយខ្ញុំវាមិនសូវស្គាល់ច្បាស់ដែរ ប៉ុន្តែដឹងថាអ្នកនៅហ្នឹង។

**ស៖** លោកបានឆ្លើយថា លោកធ្វើការនៅរោងឡាន។ អ៊ីចឹងខ្ញុំគិតថាលោកស្គាល់ឡានទាំងអស់ហ្នឹងហើយ។ ពេលដែលលោកឃើញឡានបើកចេញទៅដោយមានដឹកមនុស្សដែលគេចាប់ចងមនុស្សមកពីបូព៌ាហ្នឹង តើលោកដឹងទេថា ប្រហែលជាប៉ុន្មានម៉ោងវិញដែរ ដែលឡានហ្នឹងត្រឡប់មកការដ្ឋានវិញ?

[០៩:២៣:០៥]

**ឆ៖** បាទ ប្រហែលជាម៉ោង ជួនកាលម៉ោងបី ម៉ោងបួនភ្លឺបានឃើញមកដល់វិញ។ ប៉ុន្តែឡានហ្នឹងកង់ឌុប អាឡានៗទាហានហ្នឹង។ ខ្ញុំអត់ស្គាល់ម៉ាកដែរ ប៉ុន្តែទៅឌុបតែមួយយប់ហ្នឹង ជិតព្រឹកបានឃើញមក ប៉ុន្តែមិនមែនមកដាក់នៅកន្លែងហ្គារ៉ាសខ្ញុំឯណា ដាក់នៅហ្គារ៉ាសខាងកើត ជិតព្រលាន – ខាងកើតព្រលានណោះ។ តែគេ -- មិនដឹងគេមកថ្ងៃរណា អីថ្ងៃរណា ប៉ុនព្រឹកឡើងខ្ញុំដើរទៅធ្វើការធ្វើអីឃើញឡានហ្នឹងមកវិញ។

**ស៖** បាទ សូមអរគុណ។ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅក្នុងឯកសារ ដែលខ្ញុំអានហ្នឹង លោកបានបញ្ជាក់ថា លោកបានស្តាប់ឮថា អ្នកបូព៌ាហ្នឹងត្រូវបានគេចាត់ទុកថា ជាអ្នកក្បត់អង្គការ ឬក៏ជាគិញ កា.ហ្សេ.បេ ឬជា សេ.អ៊ី.អា។ ហើយគេបញ្ជូនទៅកំពង់ឆ្នាំងហ្នឹង គឺដើម្បីអប់រំលត់ដំ។ តើ

លោកដឹងទេ ថាអ្នកណាជាអ្នកសម្រេចថា អ្នកបូព៌ាហ្នឹងជាជនក្បត់?

**ឆ៖** បាទ ខ្ញុំឮតែមេក្រុម មេកងគេនិយាយអ៊ីចឹង។ ថាពួកបូព៌ាហ្នឹងក្បត់ តែមិនដឹងទៅក្បត់រឿងអី ខ្ញុំអត់ដឹង។ ខ្ញុំឮតែមេក្រុម មេកងគេនិយាយប្រាប់អ៊ីចឹង។

[០៩:២៤:៤០]

**ស៖** នៅការដ្ឋាននោះ ទាហានបូព៌ាដែលគេចាត់ទុកថា ជាជនក្បត់ហ្នឹង គេចាត់ទុកពួកគាត់ហ្នឹងជាទាហានធម្មតាទេ ឬក៏ចាត់ទុកជាអ្នកទោសតែម្តង?

**ឆ៖** បាទ ដែលទាហានកងទ័ពបូព៌ាហ្នឹងគេថា ក្បត់ខ្លះអត់ខ្លះ។ តែមិនដឹងមួយណាក្បត់ មួយណាអត់ ខ្ញុំវាអត់ដឹង។ តែឃើញតែគេទៅចាប់មេៗ ដូចថ្នាក់ត្រឹមមេក្រុម មេកងហ្នឹង ឃើញគេចាប់ដាក់ឡានហ្នឹងទៅ។ គេចងក្រពាត់ស្លាប់សេក បិទមុខជិតៗ ដឹងមួយណា បើខ្ញុំអត់ស្គាល់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំងើបឡើងយឺតបន្តិច តែវាជាការកត់សម្គាល់របស់ខ្ញុំទៅលើសំណួរដែលព្រះរាជអាជ្ញាបានសួរ។ សំណួរនេះមិនអាចស្ថិតក្នុងករណីជាការអាច ឬមិនអាចនោះទេ គឺថាពួកគាត់ត្រូវតែជាអ្នកទោស ហើយពួកគាត់ត្រូវទទួលការធ្វើទារុណកម្មចំពោះគ្រប់សកម្មភាពដែលក្បត់។ ដូច្នេះសំណួរដែលសួរសាក្សីថា តើសាក្សីនោះជាអ្នកទោស ឬក៏ជាទាហាននោះ គឺជាការមិនត្រឹមត្រូវ។ ដូច្នេះខ្ញុំចង់បញ្ជាក់ឡើងវិញ ថានេះជាការសង្កេត មិនមែនជាការជំទាស់នោះទេ។

[០៩:២៦:៣៥]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកបាននិយាយថា ពួកបូព៌ាត្រូវបានគេចោទថាជាជនក្បត់។ ខ្ញុំនិយាយអំពីក្រុមអ្នកបូព៌ាទាំងអស់តែម្តង ខ្ញុំមិនសំដៅទៅលើតែអ្នកដែលគេចាប់ទេ។ ខ្ញុំចង់និយាយថា ឲ្យតែអ្នកមកពីបូព៌ាទាំងអស់នោះ ទោះអ្នកគេមិនចាប់ក៏ដោយនោះ ដែលធ្វើការនៅព្រលានយន្តហោះហ្នឹង គេដាក់នៅទីនុំងគឺដើម្បីអប់រំ ឬក៏ដើម្បីលត់ដំ?

**លោក កែវ គីន៖**

**ឆ៖** បាទ គេយកមកដាក់ដើម្បីលត់ដំ គេអប់រំ លត់ដំអប់រំហ្នឹង។ រួចបើពីណាគេធ្វើតាមគេទៅ

ក៏អត់អី ពីណាគេមិនធ្វើតាម គេចាប់ តែដឹងគេចាប់ពីបទរឿងអី បទល្មើសពីរឿងអី ខ្ញុំវាអត់បានដឹង។

**ស៖** លោកបាននិយាយថា លោកបានឃើញថា ការចាប់ខ្លួនហ្នឹងគឺនៅចំពោះមុខ ល្វៃ ហើយនិងកងការពាររបស់គាត់។ អ៊ីចឹងខ្ញុំចង់ដឹងថា តើនៅពេលចាប់ខ្លួនហ្នឹង មានកម្មាភិបាលណាផ្សេងទៀតក្រៅពី ល្វៃ ទេ ដែលមានវត្តមានហ្នឹង? លោកធ្លាប់ឃើញ សុង ទេ? កាលពីម្សិលមិញ លោកនិយាយថា គាត់ជាមេក្រុមរបស់លោកក្នុងគ្នារបស់លោក១០នាក់ ដែលជាអ្នកមកដល់ព្រលានយន្តហោះហ្នឹងដំបូងគេនៅក្នុងកងពល៥០២។ អ៊ីចឹងតើ សុង ហ្នឹងគាត់មានធ្លាប់មានវត្តមានទេ នៅពេលដែលគេចាប់ខ្លួនមនុស្សនោះ?

[០៩:២៨:១២]

**ឆ៖** បាទ សុង ហ្នឹងអត់មានទេ អត់មានឃើញមុខមកទេ។ ឃើញតែកម្មាភិបាលគេត្រឹមវរសេនាតូច វរសេនាធំអីឃើញគេ ខ្ញុំអត់ស្គាល់ឈ្មោះគេដែរ ខ្ញុំស្គាល់ច្បាស់តែ ល្វៃ ហ្នឹងមួយ។ ឃើញគេមកកន្លែងមន្ទីរហ្នឹង។

**ស៖** ក្នុងចំណោមនីរសារ ឬកងការពាររបស់ ល្វៃ ហ្នឹងមានឈ្មោះ ខុន ហៅ គុយ ទេ?

**ឆ៖** បាទ មាន។ ឈ្មោះ ខុន ហៅ គុយ ហ្នឹងមានតើ នៅជាមួយហ្នឹង ប៉ុន្តែដែលចាប់ចងហ្នឹងឈ្មោះ គុយ –ឈ្មោះ ខុន ហៅ គុយ– ហ្នឹងអត់នៅហ្នឹងទេ គាត់បែកចេញដែរហើយ។ មិនដឹងគាត់នៅខាងណាវាអត់ឃើញ។

**ស៖** តើលោកដឹងទេថា ខុន ហៅ គុយ នេះក្រៅពីជានីរសារនុ៎ង របស់ ល្វៃ ហ្នឹងគាត់ក៏មានតួនាទីយាមកាមទៅលើកម្មករដែលធ្វើការនៅការដ្ឋានដែរ។ តើមានអ៊ីចឹងទេ?

**ឆ៖** បាទ អត់ទេ។ គាត់កាន់ខាងឡាន ខាងអីឯណានោះ។ អត់មានយាមអីមានអីនឹងគេទេ ព្រោះគេដកសេចក្ដីទុកចិត្តក្រោយពីខ្ញុំមកទៀត។ ខ្ញុំបានជួបគាត់ហ្នឹង។

**ស៖** តើអ្នកការពារហ្នឹង គាត់ស្ថិតនៅកងពិសេសមួយ ដែលគេហៅថា "កងអង្គរក្ស ឬក៏កងការពារ" មែនទេ?

**ឆ៖** បាទ ស្ថិតនៅកងអង្គរក្សក៏ដោយ កងការពារក៏ដោយ ពីដើមគេហៅតែនីរសារ។ ឥឡូវច្រើនគេហៅកងការពារ។ កងការពារគាត់ហ្នឹងមានពីរបីនាក់ដែរ។

[០៩:៣០:៥៣]

**ស៖** ពាក់ព័ន្ធនឹងកម្មាភិបាលដែលលោកនិយាយថា លោកមិនចាំឈ្មោះនោះ តើលោកស្គាល់ឈ្មោះ ធួក, យ៉េង និង សួន លោកស្គាល់ឈ្មោះអ្នកទាំងបីនាក់ហ្នឹងទេ ធួក, យ៉េង និង សួន?

**ឆ៖** យ៉េង ស្គាល់។ ប៉ុន្តែ ធួក ហ្នឹងខ្ញុំស្គាល់ច្បាស់ ព្រោះនៅកង១៣២ ហើយនិង សេង, ពន្លក ខ្ញុំស្គាល់តែប៉ុន្មាននាក់ហ្នឹងហើយ។ ផុតពីហ្នឹងអត់ស្គាល់គេទេ។

**ស៖** កង១៣២ហ្នឹងមុនឆ្នាំ៧៥មែនទេ? ហើយ យ៉េង ហ្នឹងគាត់មានវត្តមានទេ នៅការដ្ឋានសាងសង់ព្រលានយន្តហោះហ្នឹង?

**ឆ៖** បាទ គាត់អត់មានវត្តមាននៅហ្នឹងទេ ប៉ុន្តែគាត់នៅកំពង់ឆ្នាំង នៅទីក្រុងកំពង់ឆ្នាំង។ នៅៗតែ ខុន ហៅ គុយ ហើយនិងខ្ញុំ ហើយអ្នកធ្វើសំណង់ ធ្វើសំណង់ហ្នឹង ដែលខ្ញុំស្គាល់ៗ ដែលខ្ញុំចំណាំមុខ។

**ស៖** សម្រង់ចុងក្រោយពាក់ព័ន្ធទៅនឹងការចាប់ខ្លួននិងការបាត់ខ្លួន គឺសម្រង់នៅក្នុងកំណត់ហេតុរបស់លោកគឺ E3/5273 ទំព័រខ្មែរជា៦ និងបារាំង៦ដែរ, អង់គ្លេសទំព័រទី៥។ “មានវគ្គរិះគន់ ទិតៀនចំពោះអ្នកដែលមិនបានសម្រេចតាមផែនការ។ ប្រសិនបើមានការទិតៀនច្រើនដងហើយ មិនមានការស្តាប់ទេ គេកម្ទេច។ ខ្ញុំដឹងថាអ្នកដែលគេត្រូវបានទិតៀនហ្នឹង គឺថាបានបាត់ខ្លួន។ ខ្ញុំមិនដែលឃើញគេសម្លាប់មនុស្សផ្ទាល់នឹងភ្នែកទេ។” សូមបញ្ចប់ការដកស្រង់។ តើម៉េចបានជាលោកដឹងថា បើគេទិតៀនពីរបីដងហើយមិនស្តាប់ គេយកទៅកម្ទេចចោលនោះ ម៉េចបានជាលោកដឹងរឿងនេះ?

[០៩:៣៣:៣២]

**ឆ៖** បាទ ព្រោះគេទិតៀនហើយ អត់ស្តាប់គេ បើពីរបីបួនប្រាំថ្ងៃបាត់ខ្លួន។ បាត់ខ្លួន រួចបានគេប្រជុំអ៊ីចឹង គេប្រាប់ថា កុំឲ្យធ្វើគំរូដូចសមមិត្តហ្នឹងអ៊ីចឹង ប្រយ័ត្នគេយកទៅកម្ទេច គេវៃសម្លាប់ចោលអ៊ីចឹង។ ហើយគេប្រាប់អ៊ីចឹង បើយើងអត់ធ្វើតាមគេ អត់ស្តាប់បង្គាប់គេ។ ប្រជុំទិតៀនគ្នាទៅវិញទៅមកអ៊ីចឹងទៅ អ្នកណាអនុវត្តបានមិនបាន គេដាក់ផែនការកម្ទេច។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺមិនមានត្រឹមតែចាប់ខ្លួន និងសម្លាប់អ្នកមកពីបូព៌ាទេ គឺមានការបោសសម្អាតផ្ទៃក្នុងនៅក្នុងកងពល៥០២ទៀត តើអ៊ីចឹងមែនទេ?

**ឆ៖** បាទៗ ត្រូវ។ គេបោសសម្អាត គេមើលទៅបងប្អូនណាជាប់ពាក់ព័ន្ធនិន្នាការអី គេដកចេញ គេបោសសម្អាត។ គេពិនិត្យមើលយើង បើយើងធ្វើការត្រឹមត្រូវជាមួយគេ អត់មានសេរី អត់ដើរហើរស្រេចតែចិត្តហ្នឹង អាហ្នឹងរស់នៅជាមួយគេបាន ប៉ុន្តែក្នុងគេតាមដាន។

**ស៖** ពាក់ព័ន្ធនឹងលក្ខខណ្ឌការងាររបស់លោក តើអ្នកធ្វើការនៅការដ្ឋានទោះជាមកពីកងពល

៥០២ ឬក៏កងពលផ្សេងទៀតក៏ដោយនោះ មានសិទ្ធិឈប់សម្រាកទេ? បើមាននោះ តើមួយខែគេឲ្យឈប់ប៉ុន្មានថ្ងៃ?

[០៩:៣៥:៣៣]

**ឆ៖** បាទ អ្នកនៅដូចជាកងពល៥០២ ដូចជារូបខ្ញុំរូបអីហ្នឹង ព្រលឹមងងឹតឡើងដល់ម៉ោងបួនកន្លះទៅជួយស្ទូងក្បែរៗព្រលាន ជួយស្ទូងប្រជាជនហ្នឹង។ ចេញពីម៉ោងបួនកន្លះ ម៉ោងប្រាំលុបមុខ លុបអី ម៉ោងប្រាំមួយចូលធ្វើការតាមសំណង់រៀងៗខ្លួនទៅទល់ម៉ោងមួយដណ្ដប់ បានសម្រាក។ ហើយអត់មានថ្ងៃអាទិត្យ ថ្ងៃសៅរ៍អីទេ អត់ទេ ធ្វើការជាប់រហូត។ អត់មានពេលសម្រាកពេលអីទេ សម្រាកតែហូបបាយ។

**ស៖** អ៊ីចឹងបើខ្ញុំគិតទៅ លោកនៅប្រហែលជាមួយឆ្នាំកន្លះ។ អ៊ីចឹងនៅក្នុងអំឡុងពេលហ្នឹងលោកធ្លាប់មានបានទទួលបានការអនុញ្ញាតឈប់សម្រាកទៅលេងក្រុមគ្រួសារទេ?

**ឆ៖** បាទ អត់មានពេលបានសុំគេទេ ព្រោះគេថាធ្វើប្រញាប់ៗ អត់ឲ្យយើងដើរសេរី ដើរទៅណាផ្ដេសផ្ដាសក្រៅពីការងារ គេហៅថាការងារស្នូល។ ក្រៅពីការងារស្នូលឲ្យធ្វើការ ឲ្យយើងដើរ -- គេអត់ឲ្យដើរ ថាយើងសេរី។ រួចគេឆាប់ ជំរុញឲ្យឆាប់ធ្វើឲ្យឆាប់រួច ប៉ុន្តែមិនដឹងថារួចនៅថ្ងៃណា បើព្រលានធំម្ល៉ឹងម្ល៉េះ។ អត់ដែលបានទៅលេងគ្រួសារអីទេ អត់ដែលបានទៅលេងម៉ែឪអីទេ អត់ទេ។ ម៉ែឪខ្ញុំជំនាន់នោះ គេជម្លៀសទៅបាត់ដំបងបាត់ទៅហើយ គេបញ្ជូនទៅហ្នឹងអស់ហើយ។

[០៩:៣៧:១៣]

**ស៖** សូមអរគុណ។ ខ្ញុំនៅសល់ពេលខ្លីណាស់ ឥឡូវនេះខ្ញុំសួរឲ្យលឿន។ នៅការដ្ឋានធ្វើការអ្នកដែលមកពីកងពលផ្សេងៗ ជាពិសេសអ្នកមកពីបូព៌ា តើមានសិទ្ធិជជែកគ្នាលេង និយាយគ្នា ពិភាក្សាគ្នា ជាមួយនឹងអ្នកដែលមកពីកងពលផ្សេងគ្នាទេ?

**ឆ៖** បាទ អត់មានទេ ព្រោះពេលធ្វើការអត់មានពេលបានជជែកគ្នាទេ។ មិនបាច់ទៅត្រឹមកងពលបូព៌ាទេ តែ៥០២ហ្នឹងក៏អត់មានពេលជជែកគ្នា ជជែកគ្នាឯណា មេក្រុមគេនៅតាមដានជាប់រហូត។ យើងអាល័យតែប្រាជ្ញអាល័យតែព្រោក អាហ្នឹងគេៗទិតៀនយើង ដូចៗខ្ញុំបាននិយាយពីខាងដើមអ៊ីចឹង។ គិតតែពីធ្វើការតែម្ដង ទាល់តែដល់ម៉ោងមួយដណ្ដប់ អាហ្នឹងមេក្រុមគេប្រាប់ឲ្យសម្រាក យើងសម្រាកទៅ។

**ស៖** ពាក់ព័ន្ធនឹងអ្នកធ្វើការនៅការដ្ឋាន លោកបានឆ្លើយនៅទំព័រ៦ ក្នុងភាសាទាំងបីនៃឯកសារ

E3/5273។ លោកបានឆ្លើយថាដូចតទៅ៖ “ខ្ញុំឃើញអ្នកនៅការដ្ឋានឈើដោយសារតែអត់មានអាហារគ្រប់គ្រាន់ និងធ្វើការហួសកម្លាំង។” សូមបញ្ចប់ការដកស្រង់។ ក្រៅពីអ្នកមកពីកងពល៥០២ ទាហានផ្សេងទៀតដែលនៅការដ្ឋាននោះ ពួកគាត់មានសុខភាពល្អទេ មានកម្លាំងមាំមួនទេ ឬក៏មើលទៅរាងកាយអីស្គមស្គាំង?

[០៩:៣៩:១៤]

**ឆ៖** បាទ អត់ដែរ អត់មានកម្លាំងកំហែងអីប៉ុន្មានទេ ប៉ុន្តែធ្វើម៉េចបំណាច់តែខ្លាចគេ ចេះតែទ្រាំធ្វើទៅ។ បាយទឹកខ្លះក៏គ្រប់គ្រាន់ ខ្លះក៏អត់ដែរ ដូចតែគ្នាអ៊ីចឹង។ មែន -- ក្រុមគេខ្លះគេហូបយ៉ាងម៉េច ខ្ញុំអត់ដឹង ប៉ុន្តែក្រុមខ្ញុំវា១ធម្មតាហើយ បើឃ្លានទៀតមិនដឹងជារកពីណា មានតែប៉ុណ្ណឹងហើយ ចេះតែទ្រាំៗទៅ។ ឆ្អែតមិនឆ្អែត ចេះតែដល់នាំគ្នាហូបសម្រាកទៅ ដល់ម៉ោងសម្រាក១ទៅ។

**ស៖** តើលោកដឹងទេថា ក្រុមផ្សេងទៀតដែលមិនមែននៅក្នុងកងពល៥០២នោះ របបអាហារហ្នឹងវាប្រសើរជាង ឬក៏អន់ជាងកងពល៥០២របស់លោក?

**ឆ៖** ខ្ញុំអត់ដឹងផង អត់ដឹង។ ដឹងគេហូបគ្រប់គ្រាន់អត់មិនដឹង មានមិនដឹង ខ្ញុំអត់ដឹង ព្រោះដូចខ្ញុំជម្រាបខាងដើម អត់មានពេលដើរទេ។ គឺថាសម្រាក គឺដឹងនៅកន្លែងសម្រាក ធ្វើការអត់មានថ្ងៃណាដែលថាសម្រាកអី អត់។ បើយើងតាមដើរតាមកន្លែង គេថាយើងដើរទាក់ទងគ្នាអ៊ីចេះអ៊ីចុះ វរ១ជាប់ទៀត។ អ៊ីចឹងយើងអត់មានពេលដើរទេ។

**ស៖** សំណួរចុងក្រោយ គឺជាសំណួរដែលពាក់ព័ន្ធនឹងលោកផ្ទាល់តែម្តង គឺពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឡាន ហើយនិងគ្រឿងចក្រ ដូចជារ៉ូឡូជាដើម។ កាលម្សិលមិញហ្នឹងគឺមានសាក្សី គាត់និយាយថា មានស្ត្រីម្នាក់ គាត់បានធ្វើអត្តឃាតដោយរត់ចូលរ៉ូឡូ។ ហើយមានសាក្សីផ្សេងទៀតហ្នឹងគឺ 2-TCW-866 នៅក្នុងកំណត់ហេតុ E3/5294 សុំទោសគឺ84, 5284 គឺនៅទំព័រទី៤ ក្នុងភាសាទាំងបី។ គាត់បាននិយាយថា៖ “ខ្ញុំស្តាប់ឮថាមានអ្នករត់ចូលកង់ឡានដើម្បីសម្លាប់ខ្លួន ក៏ប៉ុន្តែខ្ញុំមិនដឹងមូលហេតុទេ។ ហើយការណ៍ដែលសម្លាប់ខ្លួនតាមវិធីរត់ចូលកង់ឡាននេះ គឺថាកើតឡើងញឹកញាប់ណាស់។” ចុះលោកផ្ទាល់ ដែលលោកធ្វើការនៅរោងឡាន លោកធ្លាប់ស្តាប់ឮ ឬក៏ឃើញថាមានការធ្វើអត្តឃាតបែបនេះទេ?

[០៩:៤២:០៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា នេះជាឧទាហរណ៍ដ៏ល្អនៃសំណួរនាំមុខ។ គាត់អាចចាប់ផ្តើមសួរដំបូង ដូចថាតើសាក្សីដឹងអំពីការសម្លាប់ខ្លួនដែរឬទេ ជាជាងការដែលផ្តល់នូវព័ត៌មានពីសាក្សីដទៃទៀត អំពីបញ្ហានេះ ហើយសួរគាត់ទៅផ្ទាល់តែម្តង។ គេៗអត់អនុញ្ញាតឲ្យ -- អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យយើងសួរសំណួរនាំមុខ ប៉ុន្តែព្រះរាជអាជ្ញាគាត់អាចសួរបាន។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន នេះជាវិធីសាស្ត្រដែលលោកមេធាវី កូប៉េ គាត់ប្រើប្រាស់រាល់តែដង ក៏ប៉ុន្តែឥឡូវនេះខ្ញុំរៀបចំសំណួរឡើងវិញ ដើម្បីឲ្យវាអញ្យាក្រឹត។

[០៩:៤២:៥៧]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី តើលោកស្តាប់ឮ ឬក៏ធ្លាប់ឃើញមានករណីសម្លាប់ខ្លួននៅការដ្ឋានទេ គឺជាពិសេស គឺការរត់លោត -- រត់ចូលកង់ឡានសម្លាប់ខ្លួននោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

សុំទោសដែលខ្ញុំត្រូវកាត់ ប៉ុន្តែគាត់បានផ្តល់ព័ត៌មានដល់សាក្សីរួចទៅហើយ។ ដូច្នេះការនាំមុខ វានៅតែជាការនាំមុខ។ វាអត់មានប្រយោជន៍អី ដែលគាត់គ្រាន់តែងើបឈរ ហើយកែសំណួរឡើងវិញតែប៉ុណ្ណោះ។ ចំពោះខ្ញុំ ខ្ញុំធ្វើការសួរបែបនេះ ព្រោះខ្ញុំសួរជាការសួរដេញដោលផ្ទាល់។ ដូច្នេះខ្ញុំគិតថា សាក្សីមិនគួរទទួលបាននូវសំណួរបែបនេះទេ ហើយខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួរបែបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន មិនមានការបែងចែកខុសគ្នា រវាងការសួរដេញដោល និងការសួរផ្តញ់ទេ។ សាក្សីជាសាក្សីរបស់អង្គជំនុំជម្រះ មិនមែនជាសាក្សីរបស់មេធាវីការពារក្តី ឬរបស់ព្រះរាជអាជ្ញាទេ មិនមាន។ ដូច្នេះខ្ញុំសូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំសួរសំណួរបែបនេះ។

[០៩:៤៤:១៤]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៥:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមសម្រេចលើបញ្ហានេះ។ ទី១ ជម្រាបជូនភាគីថា អង្គជំនុំជម្រះបានកំណត់ច្បាស់លាស់លើវិធាននៃការហាមប្រាមហាមឃាត់មិនឱ្យភាគីតាំងសំណួរដេញដោល ប្រភេទសំណួរមួយចំនួន នៅក្នុងនោះមានប្រភេទសំណួរនាំមុខ។ បញ្ហាទី២ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី គឺលោកមេធាវី វ៉ិចទ័រ កូប៉េ ដោយសារមូលហេតុ សំណួរនេះគឺមិនទំនងជាសំណួរដែលនាំមុខទេ គឺសំណួរដែលអាចឱ្យសាក្សីឆ្លើយតបបាន។ ហើយសាក្សីឆ្លើយតបនឹងសំណួរចុងក្រោយដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ ប្រសិនបើលោកចាំនូវសំណួរដែលសួរ។

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៏ ដេស្សាឯល៖**

**ស៖** ក្រៅពីចម្លើយរបស់សាក្សីផ្សេងៗទៀតនោះ តើលោកខ្លួនឯងផ្ទាល់ហ្នឹង លោកធ្លាប់ឮ ឬក៏ឃើញករណីសម្លាប់ខ្លួនដោយផ្ទាល់ភ្នែកទេ? បើលោកមិនឃើញទេ សូមប្រាប់ថាមិនឃើញ។

**លោក កែវ គីន៖**

**ឆ៖** បាទ ខ្ញុំអត់ដែលឃើញ ហើយអត់ដែលឮ ព្រោះខ្ញុំនៅធ្វើតែរោង ធ្វើរោងដាក់ឡាន មិនមែនអ្នកបើកឡាន មិនមែនអ្នកបើករ៉ូឡូអីទេ ព្រោះខ្ញុំធ្វើរោង ធ្វើជាងផ្ទះ ធ្វើជាងរោងហ្នឹង ខ្ញុំអត់ដែលឮ អត់ដែលឃើញទេ។ ខ្ញុំនៅតែមួយកន្លែង។

[០៩:៤៦:៤៧]

**ស៖** តើលោកធ្លាប់ស្ដាប់ឮ ឬក៏ធ្លាប់ដឹងថាមានការប៉ុនប៉ងរត់ចេញពីការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹង អត់ឮដែរអាហ្នឹង។ អត់ដឹង អត់ឮថាគេរត់ គេប៉ុនប៉ងរត់ ប៉ុនប៉ងអីផង។ តាមខ្ញុំស្មានមើល បើរត់ក៏រត់មិនរួចពីគេដែរ ព្រោះបើអត់មានឮជជែកថាវារករត់រកអីទេ អត់មួយក្រុមខ្ញុំហ្នឹង។ អត់មានប៉ុនប៉ងចង់ទៅនេះ ចង់ទៅនោះ ព្រោះនឹកឃើញថា ទៅក៏មិនរួចខ្លួនដែរ។

**ស៖** សូមអរគុណ។ ចំណុចចុងក្រោយពីព្រោះដើមបណ្ដឹងរដ្ឋប្បវេណីក៏គាត់សួរសំណួរមួយចំនួនដែរ ពាក់ព័ន្ធនឹងហេតុការណ៍នៅចុងរបបខ្មែរក្រហមនៅពេលដែលវៀតណាមចូលមកជិតព្រលាន

យន្តហោះ។ តើកម្មាភិបាលកងពល៥០២ និងមេដឹកនាំហ្នឹងធ្វើអីខ្លះ? ហើយចុះកម្មកររាប់ពាន់នាក់ដែលធ្វើការនៅទីនោះ គេធ្វើយ៉ាងម៉េចដែរចំពោះអ្នកទាំងអស់ហ្នឹង ហើយគេទៅណាដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:៤៨:២២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ ហើយនិងជំទាស់ផងដែរទៅលើសំណួរនេះ ខ្ញុំគិតថានេះជាការលើកឡើងចុងក្រោយរបស់ព្រះរាជអាជ្ញា។ កថាខណ្ឌ៣០៤, ៣០៥ គឺការសម្លាប់ដោយខុសច្បាប់ពាក់ព័ន្ធទៅនឹងកម្មាភិបាលទាំងអស់នេះ ពាក់ព័ន្ធទៅនឹងកម្មាភិបាលបូព៌ា ក្រោយឆ្នាំ៧៩ គឺវាស្ថិតនៅក្រៅវិសាលភាព – ស្ថិតនៅក្រៅយុត្តាធិការពេលវេលា។ ដូច្នេះខ្ញុំមិនប្រាកដថាព្រះរាជអាជ្ញាគាត់នឹងឈានទៅដល់ពេលវេលានោះ ឬក៏អត់ទេ ប៉ុន្តែខ្ញុំសូម -- ខ្ញុំសង្ឃឹមថាព្រះរាជអាជ្ញាគាត់នឹងចាំអំពីយុត្តាធិការលើពេលវេលារបស់អង្គជំនុំជម្រះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ សំណួររបស់ខ្ញុំ គឺនៅចុងខែធ្នូ ដើមខែមករាទេ វាស្ថិតនៅក្នុងវិសាលភាពហើយ។ ទី២ ទោះបីជាឧក្រិដ្ឋកម្មប្រព្រឹត្តិក្រោយខែមករាក៏ដោយ ក៏យើងចង់ដឹង ថាតើវាមានរឿងអ្វីកើតឡើង? វាអាចបំភ្លឺពាក់ព័ន្ធទៅនឹងឋានៈរបស់មនុស្ស ដែលត្រូវបានសម្លាប់ក្រោយខែមករា។ ដូច្នេះនេះជាបរិបទប្រវត្តិសាស្ត្រ ខ្ញុំសួរសំណួរបែបនេះ វាទោះបីជាតាមលក្ខណៈបច្ចេកទេស វាអាចចេញក្រៅវិសាលភាពបន្តិចក៏ដោយ។ អ៊ីចឹងលោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរសំណួរនេះ។

[០៩:៤៩:៥៧]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥០:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី នួន ជា ចំពោះសំណួរនេះ។ ហើយសំណួរនេះគឺមានពាក់ព័ន្ធទៅនឹងយុត្តាធិការពេលវេលា ដោយចុងឆ្នាំ៧៨ និងដើមឆ្នាំ៧៩។ ម៉្យាង

ទៀតគឺវាពាក់ព័ន្ធផ្ទាល់ទៅនឹងបរិបទដែលអង្គជំនុំជម្រះកំពុងតែសវនាការនេះ អាចសួរបាន។

ដូច្នេះសាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរឡើង ដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ ប្រសិនបើចងចាំ។ បើមិនចាំទេ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិតាំងសំណួរជាថ្មីម្តងទៀត ទី១។ ទី២ អង្គជំនុំជម្រះថែម បន្ថែមពេលវេលា១០នាទីថែមទៀតដែលមានការខាតបង់ពេលវេលាដោយសារការជំទាស់តវ៉ានេះ សម្រាប់ភាគីតំណាងសហព្រះរាជអាជ្ញា។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំនឹងរៀបសំណួរឡើងវិញលោកសាក្សី។ នៅពេលដែលវៀតណាមចូលជិតមកដល់កំពង់ឆ្នាំង តើកម្មាភិបាលកងពល៥០២ ហ្នឹងមានប្រតិកម្មយ៉ាងណាដែរ? ហើយជាពិសេសនុំង តើគេធ្វើយ៉ាងម៉េចចំពោះកម្មកររាប់ពាន់នាក់ដែលធ្វើការនៅការដ្ឋាននោះ? គេនាំអ្នកទាំងអស់ហ្នឹងយកទៅណាដែរ នៅពេលដែលវៀតណាមជិតចូលមកដល់នោះ?

[០៩:៥២:១៣]

**លោក កែវ គីន៖**

**ឆ៖** បាទ វៀតណាមជិតមកដល់ កម្មករហ្នឹងឃើញតែគេដឹកទាំងឡានៗចេញតាមផ្លូវព្រលានតែមិនដឹងថាគេបត់ទៅខាងណា។ ហើយកម្មាភិបាល តាល្វៃ ហ្នឹង ខ្ញុំអត់ដឹងដែរ មិនដឹងគាត់ចេញទៅណាអីទៅណី ខ្ញុំអត់បានឃើញគាត់ចេញទៅណាផង។ មិនដឹងគាត់ទៅតាំងពីថ្ងៃរណាថ្ងៃរណី បើសភាពការណ៍ខ្ញុំអត់ដឹងដែរ ដឹងតែគេអ្នកធំៗ គេឲ្យយើងរត់ចេញ ខ្ញុំរត់ចេញតែម្តង។ ប៉ុន្តែមិនដឹងគេដឹកទៅណាទៀត កម្មករ កងទ័ពអស់ហ្នឹង។ ខ្ញុំអត់ដឹងគេដឹកទៅឯណា ប៉ុន្តែដឹកទៅតាមផ្លូវព្រលានហ្នឹង។ តាល្វៃ ហ្នឹងមិនដឹងគាត់ចេញតាំងពីថ្ងៃរណាទៀត ខ្ញុំអត់ដឹងដែរ។ បានត្រឹមតែមេកងៗគេប្រាប់ បើយើងចេញព្រលានហ្នឹង រៀបចំអីវ៉ាន់ចេញទាំងអស់ទៅ។

**ស៖** ចុះក្រោយមកទៀតនោះ លោកដឹងអ្វីទេ ពាក់ព័ន្ធនឹងការសម្លាប់ទាហានបូព៌ានៅដើមខែមករា ឆ្នាំ១៩៧៩ហ្នឹង ក្នុងចំណោមកម្មករដែរធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងនោះ?

[០៩:៥៣:៤០]

**ឆ៖** បាទ ខ្ញុំអត់សូវដឹងទេ ប៉ុន្តែឮតែគេថា ក្បត់ជាមួយបក្ស ជាមួយអង្គការ ជាមួយអីហ្នឹង។

ប៉ុន្តែឮគេថាអ៊ីចឹង។ ខ្ញុំអត់ដែលឃើញគេសម្លាប់ផ្ទាល់ផង ឃើញតែគេដឹកចេញតាមផ្លូវព្រលានហ្នឹង។ គេថាក្បត់ហ្នឹងក្បត់ៗ គេថាក្បត់ៗហ្នឹង ខ្ញុំអត់ដឹង។ ឃើញដឹកពួកបូព៌ាចេញទៅតាមផ្លូវព្រលាន បត់ទៅរមាសទៅអីមិនដឹង មិនដឹងទៅប្រឡោះណា បើខ្ញុំរត់ចេញពីហ្នឹងដែរ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកសាក្សីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរសុំការបញ្ជាក់ពីលោក។ ខ្ញុំនឹងចាប់ផ្តើមសួរសំណួរពាក់ព័ន្ធទៅនឹងការឃាមកាម គឺគេឃាមកាមលោក និងកម្មករផ្សេងទៀត។ កាលពីម្សិលមិញ និងថ្ងៃនេះ លោកបាននិយាយអំពីការឃាមកាមនេះដែរ។ ខ្ញុំចង់សួរលោកថា តើលោកស្គាល់តែកុងឡានដែលធ្វើការនៅការដ្ឋានទេ? ពីព្រោះថាលោកៗទទួលខុស -- លោកធ្វើការនៅរោងឡាន។ អ៊ីចឹងជាទូទៅ តើលោកស្គាល់តែកុងឡាននៅការដ្ឋានហ្នឹងទាំងអស់ទេ?

[០៩:៥៥:២៩]

**លោក កែវ គីន៖**

**ឆ៖** បាទ ខ្ញុំអត់ស្គាល់គេ ព្រោះគេចូលមកដល់យប់ គេសម្រាកទៅ ព្រលឹមងងឹតឡើងគេចេញបាត់ទៅ មិនដឹង។ តែកុងឡានហ្នឹង ខ្ញុំអត់សូវដែលស្គាល់គេផង។ និយាយរួមទៅវាអត់មានពេលពិភាក្សាអត់មានពេលប្រាជ្ញ និយាយលេងអីជាមួយអត់។ អត់ស្គាល់ទេ បើតែកុងឡានច្រើនម្ល៉េះៗ មិនដឹងតែកុងឡានមួយណា។

**ស៖** សូមអរគុណ។ ចុះលោកស្គាល់ឈ្មោះ ចាន់ ម៉ន ទេ?

**ឆ៖** បាទ ស្គាល់ ចាន់ ម៉ន។ ពីដើមគាត់ឈ្មោះ ខុន ហៅ គុយ ទេ។ តែដល់គាត់ -- បើថាឈ្មោះ ចាន់ ម៉ន ខ្ញុំស្គាល់ ព្រោះនៅអង្គភាពជាមួយគ្នាពីដើម។

**សៈ** តើលោកដឹងទេថា ចាន់ ម៉ន ហៅ គុយ ហ្នឹងគាត់មានមុខងារអីដែរ? ខ្ញុំគិតថាដូចព្រឹកមិញលោកបាននិយាយហើយ ក៏ប៉ុន្តែខ្ញុំចង់សួរបញ្ជាក់ម្តងទៀត។

[០៩:៥៦:៥៨]

**ឆ៖** គាត់អត់មានមុខងារអីទេ បែក -- អង្កាល់នៅជាមួយខ្ញុំហ្នឹង។ ដល់បែកចេញពីខ្ញុំគាត់មានមុខងារទៀតតែមិនដឹង ខ្ញុំអត់ដឹង។ ព្រោះបែកៗកាលរត់ មុនរត់ហ្នឹង។ គាត់នៅបើកឡាន ស្គាល់តែតែកុងឡាន ម៉ន ហ្នឹងមួយហ្នឹងហើយខ្ញុំ។

**សៈ** សូមអរគុណ។ ខ្ញុំនឹងអានចម្លើយរបស់គាត់ ដែលគាត់បានមកផ្តល់សក្ខីកម្មមុនលោកបន្តិចនេះនៅក្នុងសវនាការនេះ។ ខ្ញុំនឹងដកស្រង់នូវចម្លើយរបស់គាត់ពាក់ព័ន្ធទៅនឹងការយាមកាមនៅការដ្ឋាន។ គាត់ត្រូវបានស្តាប់កាលពីថ្ងៃទី០៩ ខែមិថុនា គឺប្រហែលជាម៉ោង១៤:៣៩នាទី គាត់បានឆ្លើយដូចតទៅ៖ "មានក្រុមទាហានដែលយាមកាម ទាហានហ្នឹងមកពីមជ្ឈិម ក៏ប៉ុន្តែខ្ញុំមិនដឹងថាមកពីណាឲ្យច្បាស់ទេ។ ព្រឹកឡើងពួកគាត់យាម ហើយជិះឡានដើរល្បាត។ ខ្ញុំមិនដឹងថាពួកគេហ្នឹងជាអ្នកណាទេ ក៏ប៉ុន្តែខ្ញុំធ្លាប់ឮគេប្រាប់ថា ពួកហ្នឹងជាទាហាន។" ព្រឹកមិញនេះលោកនិយាយអំពីកងការពារ ឬក៏កងអង្គរក្ស។ អ៊ីចឹងខ្ញុំចង់ដឹងថា តើតាមរយៈចម្លើយរបស់ ចាន់ ម៉ន ហ្នឹងអ្នកដែលយាមជិះឡានល្បាតហ្នឹង គឺអ្នកដែលនៅក្នុងក្រុមកងការពារហ្នឹង ឬក៏មកពីកងណាផ្សេង?

[០៩:៥៨:៤៣]

**ឆ៖** កាលនៅក្នុងកងពលជាមួយនឹងកងពល៥០២ ជាមួយនឹងដែលកងការពារក្រុមចិនអីហ្នឹង។ អត់មានកងពលណាមកជាមួយទេ មានតែកងពល៥០២ហ្នឹងពីរបីនាក់ ជិះឡានដូចខ្ញុំជម្រាបខាងដើម ជិះឡានពីកំពង់ឆ្នាំងមកធ្វើការជាមួយចិនហ្នឹង អាហ្នឹងកងការពារចិនហ្នឹង។ បីបួនប្រាំនាក់ ប៉ុន្តែខ្ញុំភ្លេចឈ្មោះហើយ ចាំតែ ម៉ន ហ្នឹងមួយទេ។

**សៈ** សូមអរគុណ។ នេះជាអ្វីដែលខ្ញុំយល់តាមរយៈចម្លើយរបស់លោក ចាន់ ម៉ន។ តើមានទាហានដែលដើរល្បាត ក៏ប៉ុន្តែមិនស្ថិតនៅក្នុងកងពល៥០២ទេ? លោកមាននៅចាំទេ?

**ឆ៖** បាទ ខ្ញុំដូចជាអត់នៅចាំ ព្រោះខ្ញុំវាអត់បានដើរទៅណា តែនៅធ្វើរោងធ្វើតែរោងហ្នឹង ម៉្ងៃពីរថ្ងៃបីបួនថ្ងៃបានរួច រោងហ្នឹង។ ម្ល៉ោះហើយគាត់ ចាន់ ម៉ន គាត់បានដើរ ខ្ញុំអត់សូវបានដើរទេ។ នៅធ្វើតែ

រោងហ្នឹង។ ពីដើម ចាន់ ម៉ន ហ្នឹងគាត់ឧស្សាហ៍ គាត់ៗដឹងហើយ។

**ស៖** សូមអរគុណ។ លោកបាននិយាយថា លោកមិននៅកន្លែងរោងឡាន។ អ៊ីចឹងខ្ញុំចង់ឲ្យលោកឆ្លើយតបទៅនឹងចម្លើយរបស់លោកនៅក្នុងកំណត់ហេតុ ដែលលោកបានឆ្លើយនៅមុខចំពោះសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5273 ERN ជាភាសាបារាំងគឺ 00355857, ជាភាសាអង់គ្លេស 0029 0501, ជាភាសាខ្មែរគឺ 00282943។ គេសួរលោកអំពីស្ថានភាពការងារនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ហើយលោកបានឆ្លើយដូចតទៅ៖ "ចាប់ពីម៉ោងបួនកន្លះទៅដល់ម៉ោងប្រាំព្រឹក អ្នកនៅការដ្ឋានត្រូវទៅជួយស្ទូងប្រជាជននៅតាមស្រែនៅក្បែរព្រលានជារៀងរាល់ថ្ងៃ"។ តើលោកនៅចាំចម្លើយនេះដែលលោកបានឆ្លើយនៅចំពោះមុខចៅក្រមសហចៅក្រមស៊ើបអង្កេតទេ?

**ឆ៖** ខ្ញុំនៅចាំសំណួរហ្នឹង ចាំ ដឹងថាម៉ោងប្រាំ ម៉ោងប្រាំមួយធ្វើការហ្នឹង។ តាំងពីម៉ោងបួនដល់ម៉ោងប្រាំធ្វើការ ជួយស្ទូងជួយអីហ្នឹង នៅចាំតើ។

[១០:០១:៤២]

**ស៖** ចុះខ្លួនលោកផ្ទាល់ហ្នឹង លោកមានបានទៅជួយស្ទូងប្រជាជនទេ?

**ឆ៖** ទៅបង ទៅទាំងអស់តែគ្នាហ្នឹង អត់មាននរណាបានសម្រាកនៅរង់ចាំទាល់តែភ្លឺទាល់តែអីទេ អត់ទេ ទៅ។ នៅតែអ្នកដាំបាយមួយទេ ដែលនៅរោងហ្នឹង តែផុតពីនោះទៅជួយស្ទូងគ្រប់តែគ្នាហើយ។ រាល់តែព្រឹកអ៊ីចឹងតែម្តង។ លើកលែងតែប្រជាជនឈប់ស្ទូង អាហ្នឹងបាន បានលែងជួយស្ទូងដែរ។ លើកលែងយើងមានភារកិច្ចឲ្យទៅនេះទៅនោះឆ្ងាយអ៊ីចឹងទៅ យើងអត់បានជួយស្ទូងគេទេ។ តែអ្នកនៅហ្នឹងត្រូវទៅជួយស្ទូងខ្លះ។

**ស៖** តើលោកអាចឆ្លើយឲ្យបានច្បាស់ជាងហ្នឹងបន្តិចបានទេ? លោកទៅជួយស្ទូងហ្នឹងរៀងរាល់ព្រឹក ហើយបន្ទាប់មកលោកទៅរោងឡានក្រោយពីស្ទូងហើយ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទៗអ៊ីចឹង។ ពេលព្រឹកយើងទៅជួយស្ទូង ដែលអ្នកធ្វើស្រែជិតៗព្រលានហ្នឹង។ ទៅគ្រប់តែគ្នាហ្នឹង។ ស្ទូងដល់ម៉ោងប្រាំកន្លះអី យើងងើបចេញទៅ ទៅធ្វើការងារស្នូលទៅ គេថាការងារស្នូល។ លាងដៃលាងជើង ហូបបាយពេលព្រឹកអី បបរពេលព្រឹកអ៊ីចឹងទៅ យើងទៅ តាមការងាររៀងៗខ្លួនអ៊ីចឹងទៅ។ អត់មានខានថ្ងៃណាទេ។

**ឆ៖** តើលោកអាចពន្យល់អង្គជំនុំជម្រះបានទេថា លោកទៅធ្វើការស្ទូងហ្នឹងនៅកន្លែងណា? នៅជិតការដ្ឋានព្រលានយន្តហោះ ឬក៏នៅឆ្ងាយពីការដ្ឋាន?

**ឆ៖** បាទ នៅជិនព្រលានយន្តហោះហ្នឹង ក្បែរៗហ្នឹងនៅ គេហៅភូមិប៉ាតឡាង នៅក្បែរៗព្រលានហ្នឹង។ យើងដើរទៅប្រហែលជា១០នាទីអី ដើរដល់ហើយ ជួយស្ទូងគេទៅ។ អត់មាននៅឆ្ងាយទេ បើនៅឆ្ងាយដើរ គេអត់ឲ្យយើងទៅទេ បើនៅជិតគេឲ្យយើងទៅ។ ជួយស្ទូងគ្រប់តែគ្នាហ្នឹង។ ជួយស្ទូងតែពួករោង -- ពួកធ្វើរោង ពួកឡានគេបើកចេញទៅបាត់ៗតាំងពីព្រលប់ហើយ តាំងពីងងឹតៗណោះ។ មិនដឹងថាគេទៅខាងណា ឡានគេដឹកដីដឹកអីនោះ។

[១០:០៤:១៨]

**ស៖** ប្រជាជនដែលលោកទៅជួយស្ទូងហ្នឹង គាត់ដឹងថាលោកជាកងទ័ពទេ?

**ឆ៖** បាទ ដឹង ៗថាកងទ័ពដែរហ្នឹង។ ដឹងថាយើងធ្វើព្រលានហ្នឹង ប្រាកដកងទ័ពហើយ ព្រោះអត់មានប្រជាពលរដ្ឋណាចេញចូលក្នុងព្រលានហ្នឹងបានទេ។ មានតែបានតាមផ្លូវក្បែរៗព្រលានហ្នឹងបាន បើថាក្នុងព្រលាន អត់ឲ្យប្រជាជនចូលទេ។

**ស៖** ដើម្បីឲ្យច្បាស់ ខ្ញុំចង់ដឹងថាតើស្រែហ្នឹងនៅក្នុងការដ្ឋានព្រលានយន្តហោះហ្នឹង ឬក៏នៅខាងក្រៅការដ្ឋានទេ?

**ឆ៖** បាទ ខាងក្រៅការដ្ឋាន អត់មាននៅក្នុងការដ្ឋានទេ នៅក្រៅការដ្ឋាន នៅក្បែរៗ នៅខាងកើតព្រលាន ខាងត្បូងព្រលានអាស្រែគេហ្នឹង។ អត់មាននៅក្នុងទេ នៅក្រៅៗ។

**ស៖** ប្រជាជនដែលលោកជួយស្ទូងហ្នឹង គាត់ដឹងទេថាមានការដ្ឋានសាងសង់ព្រលានយន្តហោះនៅជិតស្រែរបស់គាត់ហ្នឹង?

**ឆ៖** បាទ គាត់ដឹងតើ។ ដឹងក៏អត់ប៊ានចូលប៊ានអីដែរ ព្រោះកងទ័ពគេហាមអត់ឲ្យចូល គាត់អត់ប៊ានចូលទេ។ គាត់ថីមិនដឹង បើនៅធ្វើព្រលានក្បែរហ្នឹងហើយ ជិតស្រែគាត់ហ្នឹងហើយ។

[១០:០៦:១៨]

**ស៖** សូមអរគុណ។ នៅពេលដែលកម្មករចេញពីម៉ោងបួនកន្លះ ទៅជួយស្ទូងប្រជាជនហ្នឹង តើពួកគាត់មានត្រូវបានគេយាមកាមទេ?

**ឆ៖** បាទ អត់ទេ អត់មានយាមកាមទេ ដើរដាស់គ្នីដាស់គ្នាទៅបណ្តោយហ្នឹង អត់មានពីណាយាមទេ។

**ស៖** លោកទៅស្ទូងហ្នឹង លោកដើរទៅ ឬក៏លោកជិះឡានទៅ?

**ឆ៖** ដើរទៅតែម្តង អត់មានឡានទេ ដើរទៅៗស្រែជិតៗហ្នឹង។ ដើរទៅទាំងអស់គ្នាហ្នឹងតែម្តង

ដែលពួកដែលអត់មានការងារបើកឡានបើកអីហ្នឹង។

**ស៖** ដើម្បីឱ្យខ្ញុំយល់ច្បាស់ទៅលើចំណុចនេះ ខ្ញុំចង់ដឹងថា ក្រោយពីស្ទូងហើយ កម្មករទាំងអស់ត្រឡប់ទៅធ្វើការតាមភារកិច្ចរៀងៗខ្លួននៅការដ្ឋានវិញ តើអ៊ីចឹងមែនទេ ចម្លើយលោកអម្បាញ់មិញនេះ?

**ឆ៖** បាទ ពិតប្រាកដហើយ។ ផុតពីជួយស្ទូងគេ ម៉ោងតែម៉ោងប្រាំកន្លះចេញពីស្ទូងហើយ ទៅលាងដៃលាងជើងទៅធ្វើការរៀងខ្លួន តាមភារកិច្ចដែលគេចាត់តាំងយើង។ អត់មានទៅណាក្រៅពីធ្វើការហ្នឹងទេ។ ស្ទូងរួច ត្រូវតែឡើងទៅ ស្ទូងអត់រួចមិនរួចក៏ដោយ ឱ្យតែម៉ោងប្រាំកន្លះចេញហើយ ត្រូវទៅធ្វើការងារ គេហៅការងារស្នូលគេ។

[១០:០៨:២៥]

**ស៖** សូមអរគុណ។ ខ្ញុំចង់ឱ្យលោកឆ្លើយតបទៅនឹងចម្លើយរបស់ ចាន់ ម៉ន ដែលគាត់បានមកផ្ដល់សក្ខីកម្មមុនលោកនេះ។ គាត់បានឆ្លើយថា គាត់បានចូលធ្វើកងទ័ពនៅអាយុ១៤ឆ្នាំ។ ចំពោះលោកបើខ្ញុំគិតទៅ គឺលោកអាយុប្រហែលជាជិត២០ឆ្នាំ នៅពេលដែលលោកទៅធ្វើការនៅការដ្ឋានកំពង់ឆ្នាំង។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា នេះមិនមែនជាសក្ខីកម្មរបស់សាក្សីកន្លងមកទេ។ កាលពីម្សិលមិញ គាត់បានបញ្ជាក់ថាគាត់ក្លាយទៅជានីរសារកងទ័ពនៅឆ្នាំ៧៣ ហើយគាត់កើតនៅឆ្នាំ៥៤ ដូច្នេះគាត់ចូលទាហាននៅអាយុ១៩ឆ្នាំ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

ដើម្បីចៀសវាងការពិភាក្សាគ្នាវែងឆ្ងាយ ខ្ញុំសូមដកស្រង់ប្រតិចារឹកនៅថ្ងៃទី០៩ មិថុនា គឺនៅម៉ោង ០៩:១៨:២០ គេសួរថា៖ “តើលោកចូលបដិវត្តន៍នៅឆ្នាំណា?” ហើយគេសួរបន្តទៀតថា៖ “តើលោកអាយុប៉ុន្មាន?” គាត់បានឆ្លើយថា គាត់អាយុប្រហែលជា១៤ឆ្នាំ។ អ៊ីចឹងគាត់បញ្ជាក់ហើយថា គាត់អាយុ១៤ឆ្នាំ។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីបន្តសួរទៅទៀត។ ដូច្នេះយើងបានស្ដាប់ឮចម្លើយរបស់គាត់ថា គាត់មានអាយុ១៤ឆ្នាំនៅពេលដែលគាត់ចូលកងទ័ព លោកចំពោះលោកប្រហែលជាអាយុ២០ឆ្នាំ នៅពេលដែលលោកនៅធ្វើការការដ្ឋាន។

[១០:១០:២០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

គាត់ចូលកងទ័ពបដិវត្តន៍នៅឆ្នាំ -- នៅអាយុ១៤ឆ្នាំ។ ប៉ុន្តែគាត់ក្លាយទៅជាទាហានអាយុ១៩។ ដូច្នេះគ្រាន់តែចូលបដិវត្តន៍មិនមែនមានន័យថា គាត់ក្លាយទៅជាកងទ័ពដោយស្វ័យប្រវត្តិនោះទេ។ ការពិតគាត់ក្លាយទៅជាកងទ័ពអាយុ១៩ឆ្នាំ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំនឹងសួរសំណួរឡើងវិញ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកសាក្សី តើលោកមានកត់សម្គាល់ឃើញថា មានយុវជនអាយុ១៤ឆ្នាំទៅដល់១៨ឆ្នាំ ដែលធ្វើការនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងទេ?

**លោក កែវ គីន៖**

**ឆ៖** រឿងហ្នឹងខ្ញុំវាមិនសូវច្បាស់ដែរ ព្រោះអត់ដឹងអាយុគេប៉ុន្មានអីប៉ុន្មាន ព្រោះឃើញតែមនុស្សសុរករៗតែគ្នា តែដឹងគេអាយុប៉ុន្មាន។ ខ្ញុំអត់ដឹង។ ឃើញតែស្រុករៗខ្ញុំ ស្រុករៗអីហ្នឹងធ្វើព្រលានហ្នឹង។ តែដឹងអាយុគេប៉ុន្មានអីប៉ុន្មាន ខ្ញុំអត់បានដឹងទេ។

[១០:១១:៤២]

**ស៖** ចុះមានស្ត្រីទេ នៅការដ្ឋាននុ៎ង? ហើយបើមាន មានច្រើនទេ?

**ឆ៖** បាទ មាន។ មានច្រើនដែរ ភាគច្រើនបើកឡាន បើកឡានដឹកដី។ មាន៣០-៤០នាក់អីណោះមនុស្សស្រីបើកឡានហ្នឹង។ ខ្ញុំឃើញឡានទៅទាំងខ្សែៗសោះ ឡានដឹកដីហ្នឹង។

**ស៖** សូមអរគុណ។ ពេលវេលាខ្លីណាស់ ខ្ញុំសូមសួរឲ្យលឿន។ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតគឺនៅឯកសារ E3/5273 ជាភាសាបារាំងគឺ 00355858, ជាភាសាអង់គ្លេស 00290502, ជាភាសាខ្មែរ 00282942។ លោកនិយាយអំពីអ្នកផ្គាក់ខ្លួនឈឺ ហើយលោកបានឆ្លើយកាលពីព្រឹកមិញទៅសហព្រះរាជអាជ្ញា ត្រង់ពីចំណុចនេះផងដែរ។ លោកបានបញ្ជាក់ថា អ្នកឈឺហ្នឹងគេដឹកទៅពេទ្យមន្ទីរពេទ្យកំពង់ឆ្នាំង។ តើលោកនៅរក្សាចម្លើយហ្នឹងទេ?

[១០:១៣:២១]

**ឆ៖** បាទ ខ្ញុំនៅចាំ។ ព្រោះអ្នកឈឺគេដឹកទៅកំពង់ឆ្នាំង ឈឺខ្លះអត់បាយ ខ្លះធ្វើការខ្លាំងហួសកម្លាំង។ អ៊ីចឹងគេដឹកទៅហ្នឹង។ អត់មានឡានពេទ្យអីដឹកទៅទេ ឡានដឹកដីដឹកអីហ្នឹងដឹកទៅ។ ដេកពេទ្យច្រើនដែរហ្នឹង។ ណាមួយវាហូបអត់គ្រប់គ្រាន់ខ្លះផង អត់ងងុយធ្វើការទល់ម៉ោងប្រាំពីរទៅដប់កន្លះឯណោះ យប់រួចមានបានដេកអីពេញភ្នែកស្រួលបួលអត់។ ដល់ហើយមានការឈឺអីខ្លះអ៊ីចឹង។

**ស៖** អ្នកដែលត្រូវគេបញ្ជូនទៅមន្ទីរពេទ្យហ្នឹង ត្រឡប់មកធ្វើការនៅការដ្ឋានហ្នឹងវិញទេ?

**ឆ៖** បាទ ខ្លះជាឃើញគេត្រឡប់មកវិញ។ ខ្លះដឹងគេជាដឹងគេអី វាអត់ឃើញខ្លះត្រឡប់មកវិញខ្លះបើភាគច្រើនឃើញមកវិញ។ តាមឈឺខ្លាំងឈឺតិចអ៊ីចឹងទៅ ឈឺច្រើនឈឺតិចអ៊ីចឹងទៅ អ្នកដែលឆាប់ជាហ្នឹងត្រឡប់មកវិញ មកធ្វើការហ្នឹងវិញដែរទេ។

**ស៖** នៅការដ្ឋានសាងសង់ព្រលានយន្តហោះមានពេទ្យ ឬមានកន្លែងចែកថ្នាំសម្រាប់ឲ្យអ្នកដែលឈឺនៅការដ្ឋានហ្នឹងទេ?

**ឆ៖** អត់មានទេ។ អត់មានពេទ្យ អត់មានអីទេ អត់មានអ្នកចែកថ្នាំចែកអីទាំងអស់ អត់។ យើងឈឺយើងជាអី ទាល់តែសូមច្បាប់គេ បើថាឈឺក្បាលឈឺអីសុំច្បាប់គេ ប្រាប់មេក្រុមប្រាប់អីគេទៅគេជូនកាលគេយកមកឲ្យ ជួនកាលអត់។ ទាល់តែឈឺខ្លាំង គេបញ្ជូនទៅពេទ្យតែម្តង។

[១០:១៥:២៦]

**ស៖** តើលោកអាចរៀបរាប់កន្លែងដែលលោកសម្រាកនៅការដ្ឋានហ្នឹងបានទេ?

**ឆ៖** បាទ ខ្ញុំរៀបរាប់សម្រាកហ្នឹង ខ្ញុំសម្រាកតែនៅខាងលិចព្រលានហ្នឹងខ្ញុំ។ សម្រាកនៅតែហ្នឹង កន្លែងតាមរោងឡានហ្នឹង។ ធ្វើកន្លែងរោងឡានមួយកន្លែង កន្លែងសម្រាកមួយកន្លែងអ៊ីចឹងទៅ។ នៅកន្លែងសម្រាកចងអង្រឹងចងអីអ៊ីចឹងទៅ អត់មានគ្រែ អត់មានអីទេ។ អត់មានមុង គ្មានស្អីទេ ដេកចងអង្រឹងដេកហ្នឹងតែម្តង តាមរោងឡាន មួយសមៗខ្លួនទៅ។

**ស៖** នៅរោងឡានហ្នឹង លោកសម្រាកហ្នឹងគ្នាច្រើនទេ?

**ឆ៖** បាទ បីបួនដប់នាក់ទៅ ចងអង្រឹងតាមសសររោងឡានទៅ រោងដាំបាយរោងអី ធ្វើផ្សេងអ៊ីចឹងទៅ។ ដល់តែរោងសម្រាកស្រួលបួលអត់មានទេ អត់មានគ្រែ អត់មានមុង អត់មានអីទេ។ ចងអង្រឹងដេកតាមរោងឡានហ្នឹង។ អត់មានបន្ទប់ អត់មានរនាំង អត់ជញ្ជាំងមានអីទេ។

**ស៖** នៅសម័យនោះ តើលោកឃើញទាហានផ្សេងទៀត ដែលធ្វើនៅការដ្ឋានហ្នឹងមានកន្លែង

គេងផ្សេងទៀតទេ?

**ឆ៖** បាទ មានកន្លែងផ្សេងៗពីគ្នា គេធ្វើរោងដូចកន្លែងខ្ញុំហ្នឹងដែរ។ បើថាអ្នកបើកឡាន ដេកហ្កាវ៉ាសឡានហ្នឹងទៅ។ កងទ័ពគេផ្សេង គេបោះជំរំបោះអី មានតង់មានរោងប្រក់ស្លឹកប្រក់អីអីចឹងទៅ។ គេធ្វើរោងធំ ខ្លះក៏មានគ្រែ ខ្លះក៏មានអង្រឹងអីចឹងទៅសម្រាកទៅ។ ប៉ុន្តែជញ្ជាំង រនាំងអីអត់មានទេ កណ្ដាលវាលល្ហល្ហេវហ្នឹងហើយ។

**សៈ** សូមអរគុណ។ តើលោកដឹងទេថា កម្មករហ្នឹងសម្រាកតាមកងពលមែនទេ? ឧទាហរណ៍ដូចជា កងពល៥០២ហ្នឹង គាត់សម្រាកម្តុំគ្នាគាត់ ឬក៏មានការសម្រាកលាយឡំគ្នា?

**ឆ៖** បាទ អត់មានទេ អត់មានសម្រាកជាមួយគ្នាទេ ផ្សេងៗពីគ្នា តាមក្រុមអីចឹងទៅ។ ដូចខ្ញុំជម្រាប សម្រាកតាមក្រុមទៅ ថាបើអ្នកណានៅជិតរោងឡាន ចងអង្រឹងតាមរោងឡានហ្នឹងទៅ។ បើកងពលគេផ្សេងៗ គេបោះជាតង់ បោះជាស្លឹកកណ្តប ធ្វើរោងធ្វើអីសម្រាកនៅណោះ។ អត់មានដេកច្រឡូកច្រឡំគ្នាទេ។ សូម្បីតែក្រុមក៏អត់ច្រឡូកច្រឡំគ្នាដែរ។ ខ្លាចយើងប្រាជ្ញយើងព្រោកច្រើន គេថាយើងទាក់ទងគ្នីគ្នាអី។ ម្ល៉ោះហើយយើងអត់មានពេលទំនេរសម្រាកជុំគ្នាទេ។ មានតែតាមកន្លែងតែម្តង ម៉ោងប្រាំពីរប្រាំបីស្ងាត់ហើយ អត់មានដើរទៅឯណាបាន។ អត់មានជជែកគ្នាអីបាន។

[១០:១៩:២៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកសាក្សី ខ្ញុំអស់ពេលហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាបចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់មួយខ្វះម្ភៃនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២០ នាទី ដល់ម៉ោង ១០:៤១ នាទី)*

[១០:៤១:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ដំបូងនេះអង្គជំនុំជម្រះសូមជម្រាបជូនទៅភាគី នៅព្រឹកមិញនេះ អង្គជំនុំជម្រះសាលាដំបូងបានសួរយោបល់ភាគីនានាទាក់ទងនឹងការផ្លាស់ប្ដូរកាលវិភាគសវនាការនាពេលចុងក្រោយនេះ។ ការិយាល័យសហព្រះរាជអាជ្ញាបានស្នើថា អង្គជំនុំជម្រះគួរពន្យារពេលស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-932 រហូតដល់ថ្ងៃស្អែកដើម្បីទុកពេលវេលាសមស្របដល់សហព្រះរាជអាជ្ញាក្នុងការត្រៀមរៀបចំ។ ភាគីផ្សេងទៀតក៏បានកត់សម្គាល់ថា ពួកគេអាចនឹងទទួលបានអត្ថប្រយោជន៍ពីការពន្យារពេលនេះ ដើម្បីរៀបចំសំណួរ និងឯកសារពាក់ព័ន្ធនឹងសាក្សីរូបនេះ។ ដោយពិចារណាឃើញថាការជូនដំណឹងដល់ភាគីពីការផ្លាស់ប្ដូរកាលវិភាគត្រូវបានធ្វើឡើងក្នុងរយៈពេលខ្លី អង្គជំនុំជម្រះឯកភាពតាមសំណើសុំ និងសម្រេចស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-932 នៅពេលរសៀលថ្ងៃស្អែក ដែលនឹងចាប់ផ្ដើមពីម៉ោងមួយកន្លះ សូមភាគីជ្រាប។

បាទ អស់លោកស្រី លោកស្រីចៅក្រម តើមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ? បើមានសូមអញ្ជើញបាទ។ លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ សូមអញ្ជើញ!

[១០:៤៣:០៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរតិចតួចទេ ដើម្បីសុំបំភ្លឺចំពោះចម្លើយមួយចំនួនដែលលោកបានឆ្លើយ។ ប្រសិនបើខ្ញុំយល់មិនច្រឡំទេ ព្រឹកមិញនេះលោកបានឆ្លើយថា ឪពុករបស់លោកត្រូវបាន -- ឪពុកម្ដាយរបស់លោកត្រូវបានគេជម្លៀស។ តើឪពុកម្ដាយរបស់លោករស់នៅកំពង់ឆ្នាំងមែនទេ? គឺនៅជិតនឹងការដ្ឋានព្រលានយន្តហោះនោះតែម្ដង តើអ៊ីចឹងមែនទេ?

**លោក កែវ គីន៖**

**ឆ៖** បាទ ឪពុកម្ដាយខ្ញុំនៅឆ្ងាយពីព្រលានយន្តហោះជាង២០គីឡូដែរ តែឪពុកម្ដាយខ្ញុំ ដល់ពេលបែកភ្នំពេញភ្លាម អត់ជម្លៀស ទាល់តែ៧៥, ៧៦ បានគេបញ្ជូនទៅបាត់ដំបង។ បញ្ជូនទៅអស់ អត់មាននៅនឹងកំពង់ឆ្នាំងហ្នឹងទៀតទេ គេយកទៅទាំងសហករណ៍ៗហ្នឹង ហើយខ្ញុំដឹងតាមរយៈបងប្អូន។ ហើយមួយជួរខាងស្រុក -- ខាងឃុំខ្ញុំហ្នឹង គេបញ្ជូនអ្នកដែលជាប់និន្នាការអត់ល្អ មិនល្អអីគេបញ្ជូនទៅហ្នឹងអស់ហើយ។

**ស៖** តើអ្នកដែលរស់នៅជិតការដ្ឋានព្រលានយន្តហោះហ្នឹងត្រូវបានគេជម្លៀសចេញដែរឬទេ?

[១០:៤៤:៥៥]

**ឆ៖** បាទ អ្នកនៅជិតហ្នឹងអត់មានជម្លៀសអីចេញផង ឃើញតែគេនៅខាងលិចព្រលានហ្នឹង ប្រហែលជាជាប់ដី១គីឡូអីទៅ កន្លះគីឡូអីនៅហ្នឹងឡើយ អត់ឃើញជម្លៀសចេញផង។ នៅទាំងអស់តែគ្នាតាមភូមិទៅ ប្រជាពលរដ្ឋនៅទាំងអស់។ អត់មានឃើញពីណាទៅណាទេនៅហ្នឹង លើកលែងឪពុកម្ដាយខ្ញុំអីទេ ថាជាប់ពាក់ព័ន្ធនិន្នាការហ្នឹង បានមានគេជម្លៀសចេញ។ គេបញ្ជូនទៅទាំងបងទាំងកូនទៅបង្ហើយមួយគ្រួសារហ្នឹង មិនមែនតែគ្រួសារខ្ញុំទេ ទូទៅទាំងអស់តែគ្នាដែរ។ គេបញ្ជូនទៅពាយ័ព្យហ្នឹង គេហៅ “ពាយ័ព្យៗ” ហ្នឹង។

**ស៖** ខ្ញុំចង់សួរសំណួរមួយចំនួនពាក់ព័ន្ធនឹងវគ្គរៀនសូត្រ ដែលលោកបានចូលរួមពាក់ព័ន្ធទៅនឹងបញ្ហាវិន័យយោធា។ តើលោកចាំទេថា លោកមានធ្លាប់បានចូលរួមវគ្គរៀនសូត្រពាក់ព័ន្ធនឹងវិន័យយោធាទេ?

**ឆ៖** បាទ ខ្ញុំនៅចាំ។ រៀនកាលនុ៎ង រៀននៅ ហៅភូមិព្រៃមិច។ រៀនរឿងវិន័យយោធាហ្នឹង រៀនវិន័យទ័ពហ្នឹង គេអត់ឲ្យយើងសេរីទេ។ បំពាក់បំប៉នយើង តាមច្បាប់មាគ៌ារបស់បក្សគេហ្នឹង ដូចថាឲ្យយើងគោរពវិន័យចាត់តាំងច្បាស់លាស់អីចឹងហ្នឹង។ អត់មានបង្រៀនអីក្រៅពីរៀនការងារភារកិច្ចផ្ទាល់ខ្លួនរបស់ខ្លួនឯងហ្នឹង រឿងយោធាហ្នឹង ឲ្យយើងក្ដាប់បក្សគេឲ្យច្បាស់លាស់ ព្រោះយើងអនុវត្តតាមគោលការណ៍គេហ្នឹង។ ដឹងតែប៉ុណ្ណឹង។

[១០:៤៧:១៧]

**ស៖** តើលោកចាំពីកាលបរិច្ឆេទដែលលោកបានចូលរួមក្នុងកិច្ច -- ក្នុងវគ្គរៀនសូត្រហ្នឹងទេ?

**ឆ៖** ខ្ញុំអត់បានចាំទេ ដឹងទី -- ខ្ញុំអត់បានចាំអីទេ មិនដែលដឹងពីខែណាទៅខែណា ខ្ញុំភ្លេចអស់

ហើយ។ តែដឹងតែខ្ញុំរៀននៅភូមិព្រៃមិច ស្រុកស្ទឹទៀតខ្ញុំអត់ស្គាល់ ខាងលិចបេង-ថ្លុង។ មេកងគេបង្រៀនបង្ហាត់ ហើយគេបង្រៀនយើង។ ខ្ញុំចាំច្បាស់តែប៉ុណ្ណឹង។

**ស៖** លោកទើបតែនិយាយអំពីការរៀនសូត្រនៅព្រៃមិច។ ខ្ញុំនឹងអានចម្លើយរបស់លោកពាក់ព័ន្ធនឹងចំណុចនេះ។ ក៏ប៉ុន្តែជាបឋម ខ្ញុំចង់ដឹងថាតើវគ្គរៀនសូត្រហ្នឹង ត្រូវបានរៀបចំឡើងមុនជ័យជម្នះ១៧មេសា ឬក៏ក្រោយជ័យជម្នះ១៧ មេសា?

**ឆ៖** បាទ មុន១៧មេសាហ្នឹង។ រៀនមុន១៧មេសាហ្នឹង អត់មានរៀនក្រោយ ខ្ញុំដឹង ខ្ញុំចាំច្បាស់ណាស់។

**ស៖** នេះជាចម្លើយរបស់លោកនៅក្នុងឯកសារ E3/5273, ERN ជាភាសាបារាំង 00355855, ERN ជាភាសាអង់គ្លេស 00290499, ជាភាសាខ្មែរ 00282940 ទៅដល់ 41។ "ខ្ញុំបានចូលរួមក្នុងវគ្គរៀនសូត្រនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា នៅព្រៃមិចខេត្តកំពង់ស្ពឺ ដែលមានមេកងជាអ្នកបង្រៀន ដោយនិយាយសំខាន់ពីរឿងពង្រឹងស្មារតីគោរពបក្ស តាមផែនការចាត់តាំងមិនឲ្យប្រកែកតវ៉ា។ គេបាននិយាយថា បើអ្នកណាប្រឆាំងនឹងកម្ទេចចោល ដែលមានន័យថា សម្លាប់ចោល។ មុនឆ្នាំ១៩៧៥ នៅក្នុងកងរបស់ខ្ញុំធ្លាប់មានការកម្ទេចមនុស្សពាក់ព័ន្ធនឹងការមិនគោរពវិន័យ ឬគេចោទថាជាគិញ កា.ហ្សេ.បេ ឬ សេ.អ៊ី.អា ឬខូចសីលធម៌។ល។ ការកម្ទេចនៅពេលនោះ គឺគេចាប់ចងបិទមុខយកទៅសម្លាប់ចោល ហើយកប់នៅក្នុងរណ្ដៅ។" ខ្ញុំចង់ដឹងថា តើលោកនៅរក្សាចម្លើយដែលខ្ញុំទើបតែអានអម្បាញ់មិញហ្នឹងទេ?

[១០:៥១:០៣]

**ឆ៖** បាទ ខ្ញុំនៅចាំ។ ខ្ញុំនៅចាំចម្លើយខ្ញុំពីមុនមក ខ្ញុំឆ្លើយយ៉ាងអ៊ីចឹងហើយ។

**ស៖** តើលោកចាំឈ្មោះមេកង ដែលជាអ្នកបង្រៀនហ្នឹងទេ? ហើយសិក្ខាកាមដែលចូលរួមហ្នឹងមានប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ខ្ញុំអត់ចាំ ភ្លេចឈ្មោះអស់បាត់ហើយ។ រៀនទៅដប់ម្ភៃនាក់ទៅ ២០នាក់ ពីរក្រុម។ ប៉ុនមេកង ខ្ញុំភ្លេចឈ្មោះអស់ហើយ ព្រោះយូរយារណាស់ដែរហើយ។ ខ្ញុំមិនដឹងគាត់ឈ្មោះអីៗ ភ្លេចលែងចាំឈ្មោះគាត់ហើយ។

**ស៖** តើមុន១៧ មេសាហ្នឹងយូរទេ ឬគ្រាន់តែមុនបន្តិចបន្តួចទេ អាវគ្គរៀនសូត្រហ្នឹង?

**ឆ៖** បាទ យូរដែលហើយ។ ទំនង៧៤ហ្នឹងហើយ តាមខ្ញុំស្មានមើល ប្រហែល៧៤ហើយ។

**ស៖** គឺបន្តិចក្រោយពេលដែលលោកបានចូលធ្វើជាយោធាខ្មែរក្រហម ឬក៏លោកចូលហើយ បានយូរដែរ?

**ឆ៖** ខ្ញុំចូលទៅយោធា ធ្វើខ្មែរក្រហមហើយ បានមករៀនសូត្រហ្នឹង។ ចូលបាន ចូលដើម៧២ អ៎! ដើម៧២ហ្នឹងហើយ។

[១០:៥៣:២១]

**ស៖** អ៊ីចឹងលោកធ្វើជាយោធានៅដើមឆ្នាំ៧២ ហើយវគ្គរៀនសូត្រនៅ៧៤។ ដូច្នេះតើមាន ការកែប្រែវិន័យទេ? គេមានរឹតបន្តឹងកាន់តែតឹងឡើងៗទេ?

**ឆ៖** មានបាទ គេរឹតបន្តឹងវិន័យយើង តឹងឡើងៗដែរហ្នឹងណា មិនឲ្យបន្ធូរបន្ថយដូចមុន ដែល យើងអត់ទាន់យល់ច្បាស់ ដល់ពេលប្រជុំហើយ យើងយល់ច្បាស់ដឹងថាវិន័យគេតឹងតែង យើងយល់ថា តឹងហ្នឹងហើយ។

**ស៖** លោកបានឆ្លើយថា៖ "មុនឆ្នាំ៧៥ នៅក្នុងកងខ្ញុំ ធ្លាប់មានការកម្ទេចមនុស្សពាក់ព័ន្ធនឹងការ មិនគោរពវិន័យ។" លោកបានឃើញដោយផ្ទាល់ភ្នែកពីការកម្ទេចហ្នឹងមែនទេ?

**ឆ៖** បាទ ខ្ញុំអត់បានឃើញទេ ប៉ុន្តែក្នុងអង្គភាពហ្នឹង អង្គភាពដែលនៅជាមួយគ្នាហ្នឹង គេទៅ អ៊ីចឹងទៅ។ ដល់គេត្រឡប់មកវិញ គេប្រាប់ខ្ញុំថា គេកម្ទេចមនុស្សអស់ មនុស្សដែលអត់គោរពវិន័យ គោរពអី គេកម្ទេចចោលអ៊ីចឹងហើយ។ គេនិយាយអ៊ីចឹង។

**ស៖** ចុះបរិយាកាសនៅក្នុងជួរកងទ័ពហ្នឹងយ៉ាងម៉េចដែរ? នៅពេលហ្នឹងលោកមានការភ័យ ខ្លាច ឬក៏យ៉ាងម៉េច? លោកមានអារម្មណ៍យ៉ាងម៉េចដែរ នៅពេលដែលលោកដឹងថា មានការកម្ទេចអ្នក ដែលមិនគោរពវិន័យបែបនេះនោះ?

[១០:៥៥:១១]

**ឆ៖** បាទ ភ័យៗខ្លាចតែគេកម្ទេចចោលដូចគេពីមុនៗអ៊ីចឹង ប៉ុន្តែមិនដឹងធ្វើម៉េចបើនៅក្នុងរបប គេទៅហើយ។ យើងដាកចេញក៏អត់រួច ទាល់តែធ្វើតាមគេ។ ព្រោះសម័យនោះដឹងហើយ មនុស្សគ្រាន់ តែខុសសីលធម៌បន្តិចបន្តួចក៏គេវៃចោលដែរ ទម្រាំតែយើងអត់គោរពវិន័យគេ អត់អីគេ អាហ្នឹងគេកម្ទេច ចោលហើយ។ អ៊ីចឹងខំប្រឹងប្រែងតាមតែគេទៅ មិនដឹងថាថ្ងៃណាបានស្រួល ខំធ្វើៗទៅ។

**ស៖** លោកបានឆ្លើយថា ការកម្ទេចនៅពេលនោះគឺគេចាប់ចងបិទមុខយកទៅសម្លាប់ចោល ហើយកប់ក្នុងរណ្តៅ។ គេប្រាប់លោកអំពីរឿងនេះ ឬក៏លោកបានឃើញគេចាប់ខ្លួនហ្នឹងផ្ទាល់នឹងភ្នែក

របស់លោក?

**ឆ៖** ខ្ញុំឃើញគេចាប់ផ្ទាល់នឹងភ្នែក តែយកទៅវ៉ៃយកទៅអី ខ្ញុំអត់ៗដឹង។ មិនដឹងគេទៅវ៉ៃត្រង់ណាដែរ ប៉ុន្តែចាប់ចងចាប់អី ខ្ញុំឃើញ។ ចងមុខ ចងដៃ ហើយគេនាំទៅ មិនដឹងគេនាំទៅណា។ យើងអត់ហ៊ានដេញដោលគេទេ វរៗគេថាយើងជាប់ពាក់ព័ន្ធជាមួយក្រុមហ្នឹងអីនោះ។ គេចោទយើងទៀត អ៊ីចឹងយើងអត់ហ៊ានសួរដេញដោលគេទេ។

[១០:៥៧:០១]

**ស៖** តើលោកមានឃើញដោយផ្ទាល់ភ្នែកនូវការកប់សាកសពយោធាដែលគេសម្លាប់ហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលឃើញទេ ឮតែមិត្តភក្តិដែលនៅជាមួយហ្នឹងគេនិយាយប្រាប់អ៊ីចឹង និយាយប្រាប់ខ្ញុំអ៊ីចឹង។

**ស៖** ដូច្នេះហេតុការណ៍នេះកើតឡើងតាំងពីមុនថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ទៅទៀត។ ក្រោយ១៧ មេសា ៧៥ តើស្ថានភាពហ្នឹងកាន់តែប្រសើរឡើង ឬក៏កាន់តែអាក្រក់ឡើង? ហើយលោកកាន់តែភ័យឡើងទៀត ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ កាន់តែៗពិបាកៗឡើងដែរហ្នឹង ប៉ុន្តែចេះ អារឿងភ័យៗដែរ មិនមែនស្រួលដូចពីនេះណា។ យូរគេរឹតតឹងតិចៗ។ តែអ្នកអត់តាមគេ គេថាយើង គេថាក្បត់ ថាអីគេ ម្ល៉ោះហើយចេះតែទ្រាំតាមគេទៅ។

**ស៖** ដូច្នេះរាល់ការណែនាំណាមួយ គឺត្រូវតែអនុវត្តតាមដោយមិនមានការប្រកែកតវ៉ាអីទាំងអស់។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

[១០:៥៨:៥០]

**ឆ៖** បាទ ត្រូវ។ អត់មានប្រកែក អត់មានតវ៉ាអីបានទេ។

**ស៖** តើលោកចាំទេថា លោកធ្លាប់មានបានទទួលបញ្ជា ឬក៏ការណែនាំណាដែលមានលក្ខណៈឧក្រិដ្ឋទេ?

**ឆ៖** បាទ អត់។ អត់មានបានស្តាប់ពាក្យណែនាំ ពាក្យឧក្រិដ្ឋហ្នឹង អត់។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីសកម្មភាពរបស់លោកនៅព្រលានយន្តហោះពោធិ៍ចិនតុង។ តើលោកអាចបញ្ជាក់ឡើងវិញបានទេថា លោកនៅព្រលានយន្តហោះពោធិ៍ចិនតុងហ្នឹងរយៈពេលប៉ុន្មានខែដែរ?

**ឆ៖** ខ្ញុំមកនៅតាំងតែដើមឆ្នាំ៧៥ -- ឆ្នាំ៧៦ ខ្ញុំនៅយាមឃ្លាំងជាមួយក្រុមខ្ញុំដទៃហ្នឹង។ រួចយាមជម្រះស្មៅជម្រះអី ហើយយាមស្បៀងយាមអីជាមួយឈ្មោះ ម៉េង ហ្នឹង។ តែមិនដឹងនៅឯណាទេ ម៉េង ហ្នឹង ខ្ញុំអត់ដឹងថានៅឯណាទេ។ គេចោទខ្ញុំពីរនាក់ ម៉េង ហ្នឹងជាប់និន្នាការ ឲ្យខ្ញុំនៅយាមនៅហ្នឹង។ ដល់ក្រោយមកទៀតគេចាត់តាំងឲ្យខ្ញុំទៅធ្វើព្រលានហ្នឹង។ ទៅគ្នាដប់នាក់ដូចដែលខ្ញុំជម្រាបខាងដើមអ៊ីចឹងមុនដំបូង។

[១១:០០:៥២]

**ស៖** មុនគេចាត់តាំងលោកឲ្យទៅពោធិ៍ចិនតុងហ្នឹង លោកឈរជើងនៅឯណា? ហើយលោកមានមុខងារអីដែរ លោកជានីរសាររហូត ឬក៏យ៉ាងម៉េច? ហើយលោកឈរជើងនៅកន្លែងណា?

**ឆ៖** ខ្ញុំនៅខាងកើតពោធិ៍ចិនតុងហ្នឹង ផ្ទះល្វែងនៅផ្លូវបត់ហ្នឹង នៅយាមឃ្លាំងដូចខ្ញុំជម្រាបអ៊ីចឹង។ នៅយាមឃ្លាំងពីរបីនាក់ អំ! ១០នាក់ ហើយជម្រះស្មៅ ហើយនិងយាមឃ្លាំងស្បៀងគេហ្នឹង។ នៅជាមួយឈ្មោះ ម៉េង ឈ្មោះអី។ ខ្ញុំស្គាល់តែ ម៉េង មួយ។ ម៉េង ហ្នឹងជាប់និន្នាការដូចខ្ញុំដែរ។ តែផុតពីហ្នឹងមិនដឹងទៅខាងណាខាងណី។

**ស៖** តើលោកធ្លាប់ធ្វើជានីរសារ ឬក៏កងការពារឲ្យ ល្វៃ ទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ធ្វើនីរសារបានតែមួយឆ្នាំ។ ផុតពីហ្នឹងមកបាន ដូចខ្ញុំជម្រាបអ៊ីចឹង គេថាខ្ញុំពាក់ព័ន្ធឪពុកខ្ញុំធ្វើជំទប់ ធ្វើស្អីអ៊ីចឹងទៅ គេដឹងខ្ញុំមានឪពុកធ្វើអ៊ីចឹង ជាប់និន្នាការ គេលែងឲ្យយើងដើរជាមួយហើយ គេលែងទុកចិត្តយើងហើយ។ ថាយើងនៅ ឪពុកម្ដាយនៅរបប លន់ នល់ មានធ្វើជាមុខងារជំទប់អីអ៊ីចឹង ហើយក៏ឈប់ឲ្យយើងនៅជាមួយ។ យើងបែកចេញៗពីក្រុមគាត់ហ្នឹង ប៉ុន្តែអត់នៅឆ្ងាយដែរទេ នៅគ្រាន់តែថាបែកពីក្រុម។

[១១:០២:៤៧]

**ស៖** នៅពេលដែលលោកនៅធ្វើការជិត ល្វៃ តើលោកធ្លាប់នាំគាត់ទៅចូលរួមកិច្ចប្រជុំអីទេ? ហើយលោកមានដឹងទេថា ល្វៃ ហ្នឹងគាត់មានធ្លាប់ជួបមេដឹកនាំធំៗទេ?

**ឆ៖** ខ្ញុំៗដឹងតែត្រឹមគាត់ទៅជួបចៅហ្វាយខេត្តចៅហ្វាយអីហ្នឹង ប៉ុន្តែគេចូលជួបទៅ ខ្ញុំនៅឯក្រៅ គេម៉េចឲ្យយើងចូល ម៉េចឲ្យខ្ញុំចូល។ ពីរនាក់អីហ្នឹង ខ្ញុំនៅក្រៅ នៅចាំគេហ្នឹង ទាល់តែគេប្រជុំអីរួចបានចេញ បានទៅតាមគេទៀត។ ដឹងថាគាត់ប្រជុំរឿងអីៗ ខ្ញុំអត់ដឹង។

**ស៖** គាត់ទៅជួបចៅហ្វាយខេត្តណាដែរ?

**ឆ៖** ជួបចៅហ្វាយខេត្តកំពង់ឆ្នាំង ឈ្មោះ តាសារុន ប៉ុន្តែមិនដឹងបច្ចុប្បន្នគាត់នៅឯណា អត់ដឹង។ ទៅជួប ដូចថាមួយខែឬពីរខែគាត់ទៅជួបម្តង បបួលខ្ញុំអ៊ីចឹងទៅនាំទៅៗ។ ប៉ុន្តែខ្ញុំអត់បានចូលក្នុងនឹងគេ អត់បានចូលទៅជិតគេទេ នៅនឹងក្រៅនេះទេ។

**ស៖** តើលោកធ្លាប់នាំ ល្វៃ ទៅមើលការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងទេ?

[១១:០៤:៣៣]

**ឆ៖** ខ្ញុំអត់ដែលនាំគាត់ទេ អត់ៗដែល។ ព្រោះដូចខ្ញុំជម្រាបអ៊ីចឹងថា ខ្ញុំវាបែកចេញពីហ្នឹង គេលែងឲ្យនៅជិតហ្នឹងហើយ លែងឲ្យនៅជាមួយ លែងនៅក្នុងក្រុមទៀតហើយ។ មានតែគ្នាគេហ្នឹងគេទៅដើរមើលដើរអីហ្នឹង។ ភាគច្រើនគេមិនសូវដើរមើលផង គេនៅក្នុងផ្ទះគេហ្នឹង ហើយបើកឡានតាមផ្លូវចុះឡើងៗហ្នឹង។ តែគេចុះមើលចុះអី ខ្ញុំអត់បានដឹង ព្រោះខ្ញុំ នៅដូចតែជម្រាបអ៊ីចឹង ធ្វើតែហ្កាវ៉ាស ធ្វើតែរោង។

**ស៖** នៅពេលដែលលោកធ្វើការនៅព្រលានយន្តហោះពោធិ៍ចិនតុង តើលោកធ្លាប់មានឃើញមេដឹកនាំមកទស្សនកិច្ចទេ? ហើយធ្លាប់ឃើញគណៈប្រតិភូបរទេសមកទេ? ហើយបើធ្លាប់ឃើញ តើជាអ្នកណាដែរ?

**ឆ៖** ខ្ញុំអត់ដែលបានឃើញទេ ព្រោះខ្ញុំនៅយាមឯកើតព្រលានណោះ នៅផ្ទះល្វែងខាងកើតណោះ។ ខ្ញុំអត់ដែលបានចូលទៅក្នុងព្រលានហ្នឹងទេ មិនដឹងគេ គណៈប្រតិភូណាមក អត់ដឹង។ តែយូរៗឃើញយន្តហោះគេដាក់មួយៗអ៊ីចឹងដែរ។ ខ្ញុំមិនដឹងប្រតិភូខាងណាខាងណី ខ្ញុំអត់ស្គាល់គេ ព្រោះអត់បានចូល អត់បានទៅជិតគេទេ។

[១១:០៦:២៤]

**ស៖** អ៊ីចឹងលោកមិនដែលធ្លាប់ឮគេនិយាយគ្នាថា មានគណៈប្រតិភូណាអីមកទស្សនកិច្ចអីទេ លោកមិនដែលជជែកជាមួយមិត្តភក្តិអី អំពីរឿងហ្នឹងទេ?

**ឆ៖** អត់ អត់ដែលផង។ អត់ដែលជជែកពីរឿងគណៈប្រតិភូអី ខាងណាខាងណីមក អត់ដែលបានជជែកទេ។ ខ្ញុំអត់ដែលបានឃើញគេផង។

**ស៖** ខ្ញុំមានសំណួរពីរពាក់ព័ន្ធទៅនឹងលក្ខខណ្ឌការងារនៅព្រលានយន្តហោះកំពង់ឆ្នាំង។ លោកបាននិយាយអំពីពេលម៉ោងធ្វើការ។ ខ្ញុំចង់សួរលោកថា លោកដឹងទេថា មានកម្មករខ្លះហ្នឹងធ្វើការនៅពេលយប់នៅការដ្ឋានហ្នឹង? តើមានទេ?

**ឆ៖** បាទ មានតើ។ មានធ្វើគរគោកគរដី ហើយទាំងគេទាំងខ្ញុំហ្នឹង ធ្វើទាំងអស់តែគ្នាហ្នឹង។ ទាល់តែដល់ម៉ោងដប់កន្លះបានសម្រាក។ ធ្វើទាល់តែរៀងរាល់ថ្ងៃ រៀងរាល់យប់អ៊ីចឹង ចាប់ពីម៉ោងប្រាំពីរទៅទល់ម៉ោងដប់កន្លះបានមកសម្រាក ងូតទឹកងូតអី ចូលសម្រាន្តតែម្តង ចងអង្រឹងដេករៀងៗខ្លួន។

**សៈ** នៅពេលយប់ហ្នឹង គេធ្វើការអីដែរ? ហើយពេលធ្វើការពេលយប់ហ្នឹង មានភ្លើងបំភ្លឺទេ?

[១១:១៨:១៥]

**ឆ៖** បាទ មាន។ ធ្វើការអី ដូចខាងរ៉ូឡូគេខាងបញ្ជាន់ដីអ៊ីចឹងទៅ អាត្រាក់គេខាងឈូសដី ឈូសឆាយអ៊ីចឹងទៅ។ ហើយខ្ញុំណេះដើរខាងស្រោចទឹកស្រោចអីអ៊ីចឹងទៅ។ មើលដីណាដែលមានគល់មានឈើ មានឫសមានអីហ្នឹង គេឲ្យយើងរើសចេញទៅ ដែលឡានចាក់ដីចាក់អីហ្នឹង។ ធ្វើទាល់តែដល់ម៉ោងដប់កន្លះ បានសម្រាក។

**សៈ** តើកម្មករប្រើប្រាស់ទឹកហ្នឹង គេយកមកពីណាដែរ លោកដឹងទេ? ហើយទឹកដែលផឹកហ្នឹងគឺទឹកស្អាតទេ?

**ឆ៖** បាទ ទឹកអត់ស្អាតទេទឹកនោះ។ ទឹកគេដឹកតាមស៊ីទែនឡានមក។ ទឹកយើងហូបហ្នឹងអត់ដែរល្អទេទឹក។ ដើរមកជួនកាលឡានបាញ់ទៅ ជួនកាលទៅយើង ឫសគល់ ឫសដូចខ្ញុំជម្រាបអ៊ីចឹងឫសៗគល់ឫសឈើដែលនៅកម្ទេចកម្ទីនៅក្នុងព្រលានហ្នឹង។ រើសយកចេញក្រៅកន្លែងការដ្ឋានគេធ្វើហ្នឹង។

**សៈ** តើមានបន្ទប់ទឹក បង្គន់អីសម្រាប់ឲ្យកម្មករបត់ដៃបត់ជើងទេ?

**ឆ៖** បាទ អត់មានទេ។ អត់មានបន្ទប់ អត់មានបន្ទប់ទឹក បន្ទប់អីស្រួលបួលទេ មានព្រៃ បត់ដៃបត់ជើងមានតែទៅព្រៃ។

[១១:១០:៤២]

**សៈ** តើមានមូសទេ? មាន -- (សូមទោស) មានរុយ -- បាទត្រូវហើយ មានមូសទេ? ហើយមានមនុស្សកើតជំងឺគ្រុនចាញ់ដោយសារតែមូសហ្នឹងទេ?

**ឆ៖** បាទ មាន។ មានតើ អត់មានមុងមានអីចងដេកហ្នឹង មូសខាំតាមចិត្តហ្នឹងហើយ មានជំងឺគ្រុនចាញ់ច្រើនដែរ។

**សៈ** តើលោកអាចរៀបរាប់អំពីរោគសញ្ញាដែលកើតមានចំពោះអ្នកដែលឈឺហ្នឹងបានទេ?

ជាញឹកញាប់ហ្នឹងមានរោគសញ្ញាបែបណាដែរ?

**ឆ៖** បាទ រោគសញ្ញាមានតែគ្រុនក្ដៅ ហើយនិងញាក់តែម្ដង ខ្ញុំពិនិត្យឃើញអ៊ីចឹងមួយៗ ទាំងក្រុមខ្ញុំក្រុមអីក៏អ៊ីចឹងដែរ ក្ដៅរងាៗញាក់តែម្ដង។ អត់មានថ្នាំ មានពេទ្យមកចែកថ្នាំចែកអី អត់មានទេ។ មានតែគ្រុន បើអនុញ្ញាតពីមេកងគេយកទៅពេទ្យ អាហ្នឹងបានៗទៅ បើថាទៅខ្លួនឯង ម៉េចបានទៅ អត់បានទៅទេ។ ទាល់តែគេយកយើងទៅ។ អត់មានថ្នាំ មានអីលេបដូចយើងឥឡូវទេ។

**ស៖** តើអ្នកធ្វើការខ្លះនោះមានហើមដៃហើមជើងទេ? ហើយមានអ្នកណាខ្លះ មានរាករូសអីទេ?

**ឆ៖** បាទ មានតើ ហើមដៃហើមជើង រាករូស ប៉ុន្តែវាមិនសូវច្រើនដូចជាគ្រុន ដូចខ្ញុំជម្រាបគ្រុនញាក់ គ្រុនក្ដៅ។ សម្បូរគ្រុនក្ដៅជាង ហើមដៃហើមជើងមាន រាករូសមាន។ មានស្ទើរគ្រប់កន្លែងទាំងអស់។

[១១:១៣:០០]

**ស៖** តើលោកធ្លាប់ឃើញ ឬធ្លាប់ឮថាមានកម្មករហ្នឹងស្លាប់ដោយសារតែធ្វើការហួសកម្លាំងទេ?

**ឆ៖** ខ្ញុំអត់បានឃើញទេ។ បានឃើញតែគេចុចយកថ្មយកអីហ្នឹង ផ្ទុះថ្មខ្ទាតត្រូវខ្ទាតអីស្លាប់ ខ្ញុំឃើញ។ បើថាធ្វើការហួសកម្លាំង ដូចខ្ញុំជម្រាបអ៊ីចឹងមិនមែននៅជិតគ្នា មិនមែនបានដើរទៅឯណាទៅឯណីអត់ទេ។ នៅបើថានៅត្រង់ណានៅតែហ្នឹង អត់មានបានទៅជជែកកន្លែងនេះកន្លែងនោះទេ អត់។ អ៊ីចឹងអត់ដឹងព័ត៌មាន។ បើថ្មអីខ្ទាត ខ្ញុំឃើញ ខ្ទាតត្រូវស្លាប់មែន។

**ស៖** ក្រៅពីអ្នកដែលខ្ទាតថ្មត្រូវស្លាប់ហ្នឹង តើលោកធ្លាប់ឃើញ ឬធ្លាប់ឮគេនិយាយអំពីគ្រោះថ្នាក់ប្រភេទផ្សេងទៀតទេ?

**ឆ៖** បាទ អត់ ១ឮផង។ អត់ឮគេនិយាយគ្រោះថ្នាក់ប្រភេទអីៗ អត់មានឮនិយាយប្រាប់ផង។

**ស៖** មុននេះពេលដែលខ្ញុំនិយាយអំពីបញ្ហារៀនសូត្រអំពីវិន័យ លោកនិយាយអំពីការដាក់ទណ្ឌកម្មចំពោះអ្នកដែលខុសសីលធម៌។ តើលោកអាចឆ្លើយបញ្ជាក់បានទេថា ពាក្យថា “ខុសសីលធម៌”ហ្នឹងមានន័យថាម៉េចដែរ?

**ឆ៖** បាទ ខុសសីលធម៌ហ្នឹងបានន័យថា យើងរួមភេទរួមអីជាមួយគ្នាអ៊ីចឹង ដល់តែគេអត់ដឹង ដល់ពេលគេដឹង គេយកយើងទៅកម្ទេចចោលទៅ។ អាហ្នឹងគេហៅ “ខុសសីលធម៌” ជំនាន់ហ្នឹងនោះ។

**ស៖** ប្រសិនបើអ្នកណាម្នាក់ត្រូវបានគេចាប់បានកំពុងតែលួចរបស់របរស៊ី គេអាចចាត់ទុកថាជាបទល្មើសខុសសីលធម៌ទេ?

[១១:១៦:០២]

**ឆ៖** អាហ្នឹងក៏ខុសដែរ។ លួចរបស់របរគេហួបហ្នឹង។ តែគេដឹង គេចាប់យើង។ អាហ្នឹងក៏ថា ខុស ខុសវិន័យគេ។

**ស៖** លោកបាននិយាយអំពីអ្នកដែលគេចោទថា ជាខ្មែរសេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ។ តើលោក អាចជម្រាបជូនអង្គជំនុំជម្រះបានទេថា តើលោកយល់ថាម៉េចដែរពាក្យថា “កា.ហ្សេ.បេ និង សេ.អ៊ី.អា” នេះ?

**ឆ៖** បាទ ខ្ញុំយល់ កា.ហ្សេ.បេ, សេ.អ៊ី.អា គេថាគិញសម្ងាត់។ គិញអីអ៊ីចឹងទៅណ៎ា បើថា កា.ហ្សេ.បេ ហ្នឹងណ៎ា ខ្ញុំឮតែគេនិយាយអ៊ីចឹងទេ។ ម្ល៉ោះហើយគេចោទយើងថា កា.ហ្សេ.បេ អ៊ីចឹង គេ ថាយើងធ្វើការឲ្យអ្នកនេះអ្នកនោះនៅនេះ នៅអីណានៅអីណីទៅ យកចោទយើង។ ហើយការពិតយើង អត់មាននេះទេ គ្រាន់តែជជែកជុំគ្នាក៏អត់បានផង។ មិនដឹង កា.ហ្សេ.បេ ស្អីៗក៏មិនដឹងដែរ ប៉ុន្តែឮគេថា ចោទថាគិញ ខាងវៀតណាមខាងអីអ៊ីចឹង គេកម្ទេចយើងចោលហើយ ឲ្យតែគេដឹង។ ប៉ុន្តែការពិតយើង អត់សោះ។ គ្រាន់តែជជែកលេងជជែកអីបន្តិចបន្តួចហ្នឹង ក៏អត់បាន។ ជជែកជុំគ្នាជាក្រុមអីក៏អត់បាន មិនបាច់ក្រុមទេ ត្រឹមបីនាក់ឡើងលើទៅហ្នឹង គេរករឿងយើងហើយ គេទិតៀនដូចខ្ញុំជម្រាបអ៊ីចឹង។

**ស៖** នៅពេលដែលគេនិយាយអំពី សេ.អ៊ី.អា តើលោកដឹងទេថា គេសំដៅថា សេ.អ៊ី.អា ហ្នឹង មកស៊ើបការណ៍ពីអ្នកណាដែរ?

**ឆ៖** បាទ ខ្ញុំ -- ថា សេ.អ៊ី.អា ហ្នឹងថា សេ.អ៊ី.អា ស៊ើបការណ៍យកទៅឲ្យពួកអាមេរិកាំងអី អ៊ីចឹងទៅ ហើយទៅដឹងអាមេរិកាំងនៅឯណាផង អត់ឃើញផង ឮតែគេនិយាយថាអ៊ីចឹង។

[១១:១៨:៤០]

**ស៖** ហើយចុះ កា.ហ្សេ.បេ ហ្នឹង ភ្នាក់ងារហ្នឹងគេស៊ើបការណ៍ឲ្យអ្នកណាដែរ លោកដឹងទេ?

**ឆ៖** បាទ ស៊ើបការណ៍ឲ្យវៀតណាម។ កា.ហ្សេ.បេ ហ្នឹងខ្ញុំឮតែគេនិយាយអ៊ីចឹង។

**ស៖** តើគេមានចោទអ្នកណាម្នាក់ថាជា កា.ហ្សេ.បេ, ជា សេ.អ៊ី.អា ទាំងពីរហ្នឹងតែម្តងទេ? ឬ ក៏គេគ្រាន់តែចោទថា អ្នកហ្នឹងជាខ្មែរ សេ.អ៊ី.អា ឬ កា.ហ្សេ.បេ គេមិនដែលចោទអ្នកណាម្នាក់ថា ជា ខ្មែរឲ្យទាំង កា.ហ្សេ.បេ និង សេ.អ៊ី.អា ទេ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ តែគេចោទអ៊ីចឹងហើយ គេចាប់ហើយ។ អត់មាននិយាយអីច្រើនដូចយើងឥឡូវទេ តែ គេចោទហើយ ស្រួលមិនស្រួលសាមីខ្លួនថា ធ្វើ កា.ហ្សេ.បេ, សេ.អ៊ី.អា ហ្នឹងអត់ដឹងខ្លួនផង ហៅទៅ

ចាប់បណ្តោយហ្នឹង។ ឲ្យការពិតគ្នាអត់ដឹងអីផង មិនដឹង ក.ហ្សេ.បេ អីហ្នឹងយ៉ាងម៉េច ហើយ សេ.អ៊ី.អា ហ្នឹងយ៉ាងម៉េច ក៏អត់ដឹង។ ឲ្យតែគេចោទហើយ អត់រួចទេ។

**ស៖** តើលោកដឹងទេ នៅពេលដែលគេចាប់ខ្លួនមនុស្សហ្នឹង គឺការចោទប្រកាន់ហ្នឹងគឺគ្មានមូលដ្ឋានទេ គេចេះតែចោទហើយចាប់ទៅ តើលោកដឹងថាអ៊ីចឹងទេ?

**ឆ៖** បាទ ចឹមិនដឹង។ ប៉ុន្តែនិយាយជាមួយគេម៉េចស្តាប់ យើងតួនាទីតិចតួច អត់មានតួនាទីអីផង។ តែគេហៅថ្នាក់លើចាប់ ដឹងតែថ្នាក់លើចាប់ហ្នឹងហើយ។ តែមិនដឹងបទទោសបទអី ខ្ញុំអត់ដឹង។ គេថាតែ សេ.អ៊ី.អា, ក.ហ្សេ.បេ ហ្នឹង ខ្ញុំឮតែគេថាអ៊ីចឹង ថាតាមតែគេ ស្តាប់តាមគេទៅ។ ប៉ុន្តែភាគច្រើន គេចោទតែយ៉ាងអ៊ីចឹង។

[១១:២១:២២]

**ស៖** លោកសាក្សី តើគេមានឲ្យលោកសរសេរប្រវត្តិរូបទេ? ហើយបើមានហ្នឹង តើគេឲ្យធ្វើហ្នឹងញឹកញាប់ទេ?

**ឆ៖** ធ្វើប្រវត្តិរូបហ្នឹង មេក្រុមគេដើរធ្វើឲ្យយើង។ ជួនកាលគេអត់ធ្វើប្រវត្តិរូបផ្ទាល់ខ្លួនឯង ជួនកាលគេទៅស៊ើបសួរឯផ្ទះឯណោះ យើងអត់ដឹងថាគេទៅធ្វើឯហ្នឹងទេ។ រួចដល់ធ្វើអ៊ីចឹងទៅ គេស៊ើបសួរ ម្នាក់នេះធ្វើអីៗ បងប្អូនធ្វើអីៗ គេដឹងអស់រលីង។ ហើយលាក់ម៉េចជិតគេ បើគេ ភ្នាក់ងារនៅជិតផ្ទះជិតអីគរគោកគរដី ច្រើនយ៉ាងនេះ។ តាមគេស៊ើបប្រវត្តិរូបដឹងមក បានដឹងយើងជាប់និន្នាការ គេដកយើងចេញ យើងដឹងខ្លួនយើងហើយ។ ប្រវត្តិរូបហ្នឹងគេតែងតែធ្វើតាមភូមិអ៊ីចឹង។

**ស៖** ពាក្យ "ទុកចិត្ត" ហ្នឹងជាពាក្យដែលលោកបានប្រើយ៉ាងញឹកញាប់។ ដូច្នេះនៅសម័យនោះ លោកមានអ្នកណាដែលលោកទុកចិត្តទាំងស្រុងទេ នៅក្នុងចំណោមគ្នាដែលលោកធ្វើការហ្នឹង?

**ឆ៖** បាទ អត់មានទេ។ ទុកចិត្តទាំងស្រុងអត់មាន។ យើងម៉េចហ៊ានទុកចិត្តគេ បើគេ ជួនកាលយើងនិយាយស្អីៗទៅ គេទៅរាយការណ៍ប្រាប់មេកងមេអីអ៊ីចឹងទៅ គេចោទយើងថា យើងអីចេះអ៊ីចុះទៀត ពិបាក។ អ៊ីចឹងយើងម៉េចហ៊ានទុកចិត្តគេ។

[១១:២៣:៣១]

**ស៖** ខ្ញុំមិននិយាយអំពីមេដឹកនាំទេ ខ្ញុំនិយាយពីលោកនេះ។ ឧទាហរណ៍ដូចជា តើលោកអាចនិយាយរឿងសម្ងាត់អីប្រាប់មិត្តភក្តិលោកទេ? ឬក៏លោកអត់ហ៊ាននិយាយអីទេ លោកតែងតែខ្លាចជាប្រចាំ ខ្លាចថាបើនិយាយទៅ គឺមានហេតុការណ៍អាក្រក់អីកើតឡើងចំពោះលោក?

**ឆ៖** បាទ អ៊ីចឹងហើយ អត់ប៉ាននិយាយទេ។ អត់ប៉ាននិយាយអីទាំងអស់។ ទោះបីមិត្តភក្តិនៅជិតគ្នាជិតស្និទ្ធយ៉ាងណា ក៏អត់ប៉ាននិយាយ។ ថ្ងៃនេះគេត្រូវជាមួយយើង ថ្ងៃក្រោយទៅ ខ្លាចគេអត់ត្រូវជាមួយយើងទៅ គេរាយការណ៍ប្រាប់មេកងមេអីទៅ។ គេចោទយើងអ៊ីចេះមួយអ៊ីចេះពីរទៅ យើងយ៉ាប់ទៀត។ ព្រោះសម័យហ្នឹង អត់មានជជែកតវ៉ា អត់មានរកផ្លូវច្បាប់អីបាន។

**ស៖** នៅក្នុងកងផ្សេងៗហ្នឹង តើមានអ្នកណាម្នាក់ដែលជាគិញ ឬក៏ជាមានអ្នកណាម្នាក់ទទួលបន្ទុកស៊ើបការណ៍ទៅលើអ្នកកម្មករដែលធ្វើការទាំងអស់ហ្នឹងទេ?

**ឆ៖** ចេះតែមានហើយ ប៉ុន្តែខ្ញុំអត់ដឹង មិនដឹងមួយណា ព្រោះគេលាក់ការណ៍សម្ងាត់របស់គេដែរ។ គេតាមដានគ្រប់សកម្មភាពយើងធ្វើការធ្វើងារហ្នឹង តែដឹងមួយណា វាអត់ដឹង។ តាមរយៈពីមេក្រុម វាមិនដឹង តាមមេក្រុមមេពួកអី វាមិនដឹង អត់ដឹងដែរ។

[១១:២៥:៥០]

**ស៖** តើលោកដឹងទេ ថាការរាយការណ៍ប្រាប់ថា ឧទាហរណ៍ថាប្រាប់ថា អ្នកនេះធ្វើអ៊ីចេះធ្វើអ៊ីចុះអីអ៊ីចឹង អាចមានប្រយោជន៍ទេ?

**ឆ៖** និយាយរួមទៅ អត់ប៉ាននិយាយប្រាប់ផងខ្ញុំ។ ទោះបីគេធ្វើមានគុណសម្បត្តិ គុណអីអាម៉េចក៏អត់ប៉ាន ស្រេចតែគេពិនិត្យមើលឃើញយើង គេតាមយើងគ្រប់ជំហាន។

**ស៖** នៅពេលដែលលោកធ្វើការនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង លោកធ្លាប់ឮគេនិយាយអំពីស-២១ ឬក៏មន្ទីរសន្តិសុខផ្សេងទៀតទេ?

**ឆ៖** បាទ ស-២១ ខ្ញុំឮតែគេនិយាយដែរ។ មន្ទីរសន្តិសុខផ្សេងៗអី មិនដឹងនៅកន្លែងណា ខ្ញុំអត់ដឹងដែរ តែដល់ឮតែស-២១ ខ្ញុំឮតែគេនិយាយអ៊ីចឹង។ ស-២១ៗហ្នឹង ហ្នឹងដឹង។ ទើបដឹងច្បាស់ថាកន្លែងហ្នឹងកន្លែងគុក ទើបដឹងឥឡូវ បើពីដើមអត់ដឹង។

[១១:២៧:៣៣]

**ស៖** តើលោកធ្លាប់ទៅដល់ស-២១ ទេ?

**ឆ៖** អត់ទេ អត់ដែលទៅទេ អត់ដែលទៅសោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី ខ្ញុំអស់សំណួរហើយ។ លោកប្រធាន ខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញ ដល់សាក្សីរូបនេះសម្រាកនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:២៨ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដែលដំបូងនេះ គឺក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោក។ នៅពេលព្រឹកមិញលោកបានផ្ដល់សក្ខីកម្មថា លោកបានចូលកងទ័ពនៅក្នុងឆ្នាំ៧៣ ដើម្បីវាយប្រយុទ្ធជាមួយកងកម្លាំង

លន់ នល់។ តើលោកចូលរួមកងទ័ពនៅក្នុងឆ្នាំ៧៣ ដោយសារតែមានការអំពាវនាវរបស់សម្ដេចឪ ឬមួយក៏ដោយសារហេតុផលផ្សេង ទើបនៅពេលនោះលោកចូលទាហាន?

**លោក កែវ គីន៖**

**ឆ៖** បាទ ខ្ញុំកាលពីដើរអំពាវនាវតាមភូមិ គេហៅចូលកងទ័ពដើម្បីសម្ដេចឪ ម្ល៉ោះហើយចេះតែចូលទៅ។ ចូលនេះចូលដាក់ -- គេនាំទៅ ឈ្មោះ ល្វៃ និងឈ្មោះ វ៉ាត ហ្នឹងនាំទៅ។

**ស៖** ហើយកងទ័ពដែលលោកចូលឆ្នាំ៧៣នុ៎ង តើគេហៅថាកងទ័ពខ្មែរក្រហម ឬមួយកងទ័ពប្រដាប់អាវុធរំដោះជាតិកម្ពុជា? តើគេឈ្មោះថាយ៉ាងម៉េចដែរ?

**ឆ៖** បាទ គេហៅកងទ័ពខ្មែរក្រហម ខ្លះគេអ៊ីចឹង ខ្លះគេហៅកងទ័ពរំដោះជាតិ។

**ស៖** នៅពេលដែលលោកចូលកងទ័ពឆ្នាំ៧៣ តើលោកមានទទួលការបណ្ដុះបណ្ដាលផ្នែកយោធា ឧទាហរណ៍ដូចជាគេមានបង្រៀនប្រើប្រាស់កាំភ្លើង ឬក៏ការវាយឆ្មក់កងកម្លាំងខ្មាំងអ្វីដែរឬទេ?

**ឆ៖** បាទ គេប្រាប់ គេប្រើប្រាស់ខ្ញុំគ្រាន់តែទៅឲ្យរៀបតែកាំភ្លើង កាំភ្លើងដៃកាំភ្លើងអីហ្នឹង ហើយនៅរៀនយុទ្ធសាស្ត្រវាយឆ្មក់ ដូចគាត់ថាហ្នឹង បន្តិចបន្តួចមែន។

[១៣:៣៣:៣៨]

**ស៖** តើលោកចូលរួមក្នុងការរៀន ការបណ្ដុះបណ្ដាលហ្នឹង វាមានរយៈពេលប៉ុន្មានដែរ?

**ឆ៖** បើរៀន ជួនកាល៣ថ្ងៃ។ ៣ថ្ងៃអស់ហើយ ឈប់បង្រៀនហើយ។

**ស៖** តើលោកធ្លាប់ចូលរួមនៅក្នុងការវាយប្រយុទ្ធដែរឬទេ នៅក្នុងឆ្នាំ៧៣ដល់ថ្ងៃ១៧ មេសា ឆ្នាំ៧៥? ខ្ញុំចង់សួរថា តើលោកធ្លាប់បាញ់ខ្មាំងដែរឬទេ?

**ឆ៖** បាទ ធ្លាប់។ ធ្លាប់ចូលប្រយុទ្ធនៅសមរភូមិស្ពានសាបអង្គាម កំពង់ឆ្នាំង មកខាងនេះ ខាងទួលលាបខាងអីហ្នឹង ធ្លាប់ចូលទៅប្រយុទ្ធអ៊ីចឹងដែរ។

**ស៖** តើលោកបាន ឬក៏យុទ្ធមិត្ត – កងយុទ្ធមិត្តដែលប្រយុទ្ធជាមួយលោកហ្នឹង ធ្លាប់មានរបួស ធ្លាប់មានអ្វីដែរទេ?

**ឆ៖** បាទ មានរបួស មានស្លាប់អ៊ីចឹងដែរ ពីរបីនាក់អ៊ីចឹងដែរ។

**ស៖** ចុះលោកផ្ទាល់ លោកធ្លាប់ត្រូវរបួសទេ?

**ឆ៖** ខ្ញុំអត់ត្រូវទេ ទើបមកត្រូវយើងសម័យយើងឥឡូវនេះ សម័យយើង៧៩ ធ្វើទាហានខាងណោះបានត្រូវ។

[១៣:៣៥:២៦]

**ស៖** នៅពេលដែលលោកចូលរួមក្នុងសមរភូមិពីឆ្នាំ៧៣ដល់៧៥ តើលោកធ្លាប់ប្រយុទ្ធ ឬក៏ធ្លាប់ចូលរួមនៅពេលយប់ដែរឬទេ?

**ឆ៖** យប់ក៏ធ្លាប់ចូលរួម ប៉ុនខ្ញុំភាគតិច ខ្ញុំនៅកាលនោះនៅក្មេងដែរ គេមិនសូវឲ្យទៅប៉ុន្មានដែរ។ អាគេដូចគ្នាគេចាស់ៗ គ្នាគេធ្លាប់ដឹងប្រយុទ្ធធ្លាប់ដឹងអី អាហ្នឹងគេរុញទៅ។ ខ្ញុំយូរៗទៅម្ដងដែរ។

**ស៖** តើលោកចាំទេថា ក្នុងឆ្នាំ៧៣ ដល់៧៥ ដែលលោកចូលរួមក្នុងការប្រយុទ្ធហ្នឹង តើលោកហើយនិងយុទ្ធមិត្តរបស់លោកហ្នឹងទទួលរបបអាហារប៉ុន្មានដែរ លោកចាំទេ?

**ឆ៖** ខ្ញុំអត់បានចាំ។ វាយូរដែរហើយ មិនដឹងរបបហ្នឹងអាម៉េចអីម៉េច។ អត់បានចាំ។

**ស៖** ខ្ញុំយល់អំពីចំណុចនេះលោក។ តើលោក ហើយនិងយុទ្ធមិត្តរបស់លោកនៅក្នុងការប្រយុទ្ធហ្នឹងធ្លាប់កើតជំងឺគ្រុនចាញ់ដែរឬទេ?

**ឆ៖** បាទ មានៗច្រើន កើតជំងឺគ្រុនចាញ់ហ្នឹង កើតច្រើនលើក ច្រើនគ្នាដែរ។

**ស៖** នៅពេលដែលលោកនៅក្នុងសមរភូមិ តើលោកមានបន្ទប់ទឹកប្រើប្រាស់ត្រឹមត្រូវទេ?

**ឆ៖** អត់ៗមាន។ មានតែប៊ីដុងទឹកដាក់ជាប់ចង្កេះ មានតែប៉ុណ្ណឹង អត់មានបន្ទប់ អត់មាន។ គ្រាន់ពេលហូបបាយក៏អត់មាន ហូបបាយក្នុងត្រង់សេ។

**ស៖** តើលោក ហើយនិងយុទ្ធមិត្តរបស់លោកហ្នឹងធ្លាប់កើតជំងឺរាក ឬក៏រាកមួលអីដែរឬទេ?

**ឆ៖** បាទ ធ្លាប់កើត។ កើតដូចខ្ញុំជម្រាបអ៊ីចឹង ធ្លាប់កើតតាំងពីគ្រុនញាក់ តាំងពីរាករូសហ្នឹងក៏មាន ពីរបីនាក់អ៊ីចឹងដែរ ជួបម្ដងៗ។

[១៣:៣៨:២១]

**ស៖** តើលោកឬក៏កម្មាភិបាលរបស់ក្រុមលោកហ្នឹងធ្លាប់ដែលទទួលរបួសដោយសារហេតុការណ៍ ឬក៏ដោយសារគ្រោះថ្នាក់ផ្សេងៗដែរឬទេ?

**ឆ៖** កម្មាភិបាលច្រើនរបួសដែរ ខ្លះរបួស។ ខ្ញុំអត់ដែលរបួស សម័យហ្នឹងអត់ដែលរបួស។ ច្រើនតែទៅយកបាយយកអីឲ្យគេអ៊ីចឹង។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំនឹងសួរលោកអំពីរយៈពេលក្រោយឆ្នាំ៧៥វិញ លោកនៅក្នុងកងពលមួយ ហើយកងពលនោះនៅពេលក្រោយមកក្លាយទៅជាកងពល៥០២។ ដូច្នេះខ្ញុំចង់សួរថា លោកដឹងទេហេតុអ្វីបានជាកងពល៥០២ គឺជាកងពលដែលត្រូវទទួលខុសត្រូវក្នុងការកសាង

ព្រលានយន្តហោះអ៊ីចឹង លោកដឹងពីមូលហេតុទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។ អត់ធ្វើនៅកង -- អត់ដឹងការទទួលខុសត្រូវ៥០២ ខាងសំណង់ហ្នឹង ខ្ញុំអត់ដឹងទេ។

**ស៖** ឥឡូវនេះយើងជជែកគ្នាអំពីរយៈពេលខែកុម្ភៈ មីនា ឆ្នាំ៧៦ គឺជារយៈពេលដែលលោកនិយាយថា លោកបានចាកចេញទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង លោកនៅក្នុងកង៥០២។ តើនៅពេលនោះលោកចាំទេ ថាតើនៅក្នុងកងណាមួយ តើកងវរសេនាតូច ឬកងអនុសេនាតូច ឬក៏កងពលតូចណាមួយដែលលោកស្ថិតនៅក្នុងទេ? តើលោកចាំអំពីឈ្មោះកងនីមួយៗដែលលោកនៅក្នុងហ្នឹងទេ?

**ឆ៖** ខ្ញុំភ្លេចអស់បាត់ហើយ។ ដឹងតែកង៥០២ ខ្ញុំអត់ដឹង ស្គាល់តែកងហ្នឹងមួយ។

[១៣:៤០:៤២]

**ស៖** តើលោកនៅក្នុងកងវរសេនាធំ៥១, ៥២ ឬក៏នៅក្នុងកងពលតូច៥ -- កងវរសេនាតូច ៥០៣, ៥០៤? តើលោកនៅចាំអំពីឈ្មោះកងហ្នឹងទេ?

**ឆ៖** មិនស្គាល់ទេ។ ស្គាល់តែកង១៣២, ១៣០ ស្គាល់តែប៉ុណ្ណឹង។ ៥១, ៥២ ខ្ញុំអត់ដឹងផង។

**ស៖** ខ្ញុំយល់អំពីចំណុចនេះលោក។ តាមសក្ខីកម្មរបស់លោក ខ្ញុំយល់ឃើញថា មេបញ្ជាការ ល្វៃ គាត់ជាអ្នកបញ្ជូនលោក គឺគាត់បញ្ជូនលោកទៅកំពង់ឆ្នាំង -- ទៅព្រលានយន្តហោះកំពង់ឆ្នាំង នៅក្នុងខែកុម្ភៈ ឬក៏មីនា។ ហើយលោកនិយាយផងដែរថា អ្នកនៅក្នុងកងពលរបស់លោកគេនិយាយថា លោកហ្នឹងជាមនុស្សមាននិន្នាការ។ ខ្ញុំចង់ដឹងថា ហេតុអ្វីក៏គេនិយាយថាលោកមានជាប់និន្នាការ ប៉ុន្តែបែរជាមេបញ្ជាការ ល្វៃ ហ្នឹងបញ្ជូនលោកឱ្យទៅធ្វើការត្រៀមរៀបចំកសាងការដ្ឋានព្រលានយន្តហោះទៅវិញ?

**ឆ៖** បាទ ព្រោះខ្ញុំជាប់ពាក់ព័ន្ធនិន្នាការហ្នឹង គេលែង – និយាយរួមលែងនៅជាមួយ គេលែងឱ្យនៅក្នុងក្រសួងមន្ទីរជិត ល្វៃ ហ្នឹងហើយ។ គេឱ្យយើងនៅឆ្ងាយ ចេញពីក្រុមហ្នឹង ចេញពីក្រុមឆ្ងាយពីក្រុមហ្នឹង ទៅនៅក្រុមជាមួយក្រុមដូចខ្ញុំជម្រាបពីខាងដើម ដូចក្រុមធ្វើរោងឡានរោងអីហ្នឹង ព្រោះក្រុមហ្នឹងធ្វើការវាល់ៗល្ងាច ដូចគេលត់ដំយើងអ៊ីចឹង ព្រោះយើងជាប់និន្នាការ។ អ៊ីចឹងហើយគេលែងទុកយើងនៅកន្លែងមន្ទីរហ្នឹងទៀតហើយ កន្លែងមន្ទីរកងពលហ្នឹងទៀតហើយ។

[១៣:៤៣:១២]

**ស៖** ខ្ញុំយល់ពីចំណុចនេះ ប៉ុន្តែលោកបានផ្តល់សក្ខីកម្មថា លោកស្ថិតនៅក្នុងក្រុមឈានមុខដែល

មានកម្មាភិបាល១០នាក់ ហើយចូលរួមដោយកម្មាភិបាលចិន។ ហើយលោកចាប់ផ្ដើមការងារនៅក្នុងការដ្ឋានព្រលានយន្តហោះសម្ងាត់។ ដូច្នេះតើលោកអាចពន្យល់បានទេថា ហេតុអ្វីបានជាលោកដែលជាមនុស្សជាប់និន្នាការ បែរជាគេបញ្ជូនឲ្យទៅកសាងការដ្ឋានដែលមានលក្ខណៈសម្ងាត់បែបនេះទៅវិញ?

**ឆ៖** ចំណុចហ្នឹងខ្ញុំអត់ដឹងដែរ ព្រោះឃើញតែបញ្ជូនអីចឹង។ អ្នកជាប់ពាក់ព័ន្ធហ្នឹងបញ្ជូនដូចតែគ្នា ប៉ុន្តែបញ្ជូន ៗឲ្យធ្វើការធ្ងន់ជាងគេហ្មង អត់មានធ្វើការស្រាលទេ។ អត់មាននៅទំនេរអីបាន។ ដូចថាដាច់ឡែកចេញពីមន្ទីរហ្នឹងហើយ គេបញ្ជូនឲ្យទៅនៅធ្វើការ ដូចអានេះដូចគេលត់ដំយើង ឲ្យយើងដឹងៗខ្លួនថាជាប់ពាក់ព័ន្ធអីចឹង ជាប់និន្នាការអីចឹង។ យើងខំកសាងខ្លួនទៅ ខ្លាចលោម៉េចៗទៅគេចោទដូចនិន្នាការអីចឹងទៀត ខ្លាចគេចាប់ខ្លួនចាប់អីអីចឹងទៅ ចេះតែខំប្រឹងធ្វើទៅ។

**ស៖** ខ្ញុំពិបាកយល់បន្តិចទៅលើសក្ខីកម្មរបស់លោក។ គេបញ្ជូនលោកទៅព្រលានយន្តហោះកំពង់ឆ្នាំងនៅខែកុម្ភៈ មីនា ឆ្នាំ៧៦ ជាមួយនឹងកម្មាភិបាលដទៃទៀត រួមជាមួយនឹងទីប្រឹក្សាចិន។ ហើយបន្ទាប់មកគឺលោកធ្វើការនៅយានដ្ឋាន។ ខ្ញុំស្ដាប់ទៅវាហាក់ដូចជា លោកបំពេញការងារជាទាហានកងវិស្វកម្ម។ វាជាការងាររបស់ទាហាន។ តើខ្ញុំនិយាយអីចឹងខុស ឬក៏ត្រូវ?

**ឆ៖** បាទ ត្រូវ។ ដូចកងវិស្វកម្ម ដូចយើងសម័យឥឡូវនេះ។

[១៣:៤៥:៤៤]

**ស៖** បាទ ត្រឹមត្រូវហើយ។ ខ្ញុំមិនយល់ថា ហេតុអ្វីបានលោកហៅថា “លត់ដំ” ទៅវិញ?

**ឆ៖** ពាក្យថា “លត់ដំ” ហ្នឹងព្រោះធ្វើការវាល់ៗល្ងាច វាល់ៗព្រឹកចេញពីកន្លែងៗយើងធ្លាប់នៅស្រួល ហើយយើងទៅនៅកន្លែងលំបាកវិញ អាហ្នឹងគេឲ្យយើងលត់ដំ។ ដូចគាត់ថា កងវិស្វកម្មធ្វើការវាល់ៗល្ងាច។ លត់ដំបាយទឹកអីក៏មិនសូវគ្រប់ដូចមុនដែរ។ លើកមុនគ្រាន់ហូបគ្រាន់ ដល់តែពេលយើងទៅលត់ដំអីចឹងហើយ អត់សូវហូបគ្រាន់ទេ។

**ស៖** កងទ័ពបដិវត្តន៍កម្ពុជាត្រូវបានបង្កើតនៅក្នុងពាក់កណ្ដាលឆ្នាំ៧៥ គឺក្នុងរដូវវស្សាឆ្នាំ៧៥។ ដូច្នេះខ្ញុំចង់ដឹងថា តើកងទ័ពបដិវត្តន៍កម្ពុជាមានភារកិច្ចអ្វីដែរ? ដូច្នេះខ្ញុំចង់ដឹងថា កងទ័ពនីមួយៗនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជាហ្នឹង គាត់មានភារកិច្ចអ្វីដែរ?

**ឆ៖** បាទ ខ្លះវាមានការងារនៅយាមការពារអីទៅ ខ្លះវាទៅធ្វើការដូចសំណង់ ដូចស្ពានអីចឹងទៅ ដូចការដ្ឋានជីកប្រឡាយជីអី។ តែមិនដឹងថា កងទ័ពណាៗ ព្រោះខ្ញុំអត់ស្គាល់គាត់។ ជីកប្រឡាយ ធ្វើស្រែធ្វើអីហ្នឹង ហើយមកខាងសំណង់ហ្នឹង។ មានភារកិច្ចតែប៉ុណ្ណឹង។

**ស៖** សូមអរគុណដែលលោកបានឆ្លើយ។ អ៊ីចឹងការងារដែលធ្វើឡើងដោយកងទ័ពនៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង មិនមែនជាភារកិច្ចរបស់កងទ័ពដែលត្រូវកសាងការពារជាតិមែនទេ ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ស្រាប់តែឃើញតែគេហៅទៅសុទ្ធតែកងទ័ពទៅធ្វើអ៊ីចឹង។ ឃើញតែគេហៅទៅធ្វើពព្រាតពព្រោង គរគោកគរដីអ៊ីចឹង មិនដឹង -- គេហៅទៅធ្វើ ធ្វើចេះតែធ្វើតាមគេទៅ ទាំងគេទាំងខ្ញុំហ្នឹង។

[១៣:៤៨:៤២]

**ស៖** ខ្ញុំយល់លោកសាក្សី។ នៅព្រឹកមិញនេះ លោកបានប្រើប្រាស់ពាក្យមួយនៅពេលដែលលោករៀបរាប់ពីភារកិច្ចរបស់ទាហានកងទ័ពហ្នឹង លោកប្រើពាក្យថា "ភារកិច្ចចម្បង – ភារកិច្ចស្នូល" គឺកាន់ភារកិច្ចដែលធ្វើឡើងដោយកងទ័ពនៅក្នុងឆ្នាំ៧៦។ អ៊ីចឹងតើនេះ ខ្ញុំចង់ដឹងថាតើភារកិច្ចស្នូលរបស់កងពល៥០២ហ្នឹង គឺជាការកសាងព្រលានយន្តហោះដើម្បីការពារជាតិ ឬមួយក៏មិនមែនទេ?

**ឆ៖** ខ្ញុំអត់សូវដឹងដែរ ព្រោះកសាងការពារស្អី ខ្ញុំអត់ថា អត់សោះ។ បើឃើញតែគេកសាងហ្នឹងកសាងអំពីនឹងគេនឹងឯងទៅ។ តែដឹងគេកសាងការពារជាតិមិនដឹង ការពារឲ្យខាងស៊ីវិលមិនដឹងៗ ខ្ញុំអត់ដឹងដែរ។

**ស៖** ខ្ញុំយល់លោកសាក្សី។ មុនពេលដែលខ្ញុំសួរលោកអំពីស្ថានភាពនៅព្រលានយន្តហោះកំពង់-ឆ្នាំង ខ្ញុំចង់សួរលោកសំណួរលោកពីរបីផ្សេងទៀតសិន។ ខ្ញុំគិតថា ក្រោយការរំដោះ លោកបោះទីតាំងនៅព្រលានយន្តហោះពោធិ៍ចិនតុង។ តើនៅក្នុងពេលនោះ គឺថានៅពេលដែលលោកនៅក្នុងកងពលទ័ពអាកាស តើកង -- ថាតើយន្តហោះចម្បាំង និងឧទ្ធម្ភាគចក្រចម្បាំងរបស់កងទ័ពបដិវត្តន៍កម្ពុជាហ្នឹងមានប៉ុន្មានដែរ លោកចាំទេ?

**ឆ៖** ខ្ញុំអត់ដឹង អត់ៗបានចាំ អត់បានប៊ានចូលមើលផង។ ចូលតែអ្នកមានភារកិច្ច គេធ្វើការនៅហ្នឹងបានគេឲ្យចូល។ ខ្ញុំនៅតែក្រៅណេះ នៅតែខាងកើតៗផ្សារ ខាងកើតព្រលាន។ គ្រាន់ឃើញឃើញពីរបីថ្ងៃឃើញយន្តហោះដាក់ម្តង។ ជួនកាលកន្លះខែអីឃើញដាក់ម្តង ឲ្យញឹកញាប់ដូចរាល់ថ្ងៃហ្នឹងអត់ទេ។

[១៣:៥១:២៥]

**ស៖** ខ្ញុំយល់ថា គេអត់ឲ្យលោកចូលទៅក្នុងកន្លែងចតយន្តហោះទេ ប៉ុន្តែតើខ្ញុំអាចនិយាយបាន

ទេថា កងទ័ពអាកាសរបស់កម្ពុជាប្រជាធិបតេយ្យមាន១យន្តហោះ ហើយនិងកន្ទុំរុយចាស់ៗពីរបីគ្រឿង តែប៉ុណ្ណឹងទេ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

សាក្សីៗកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ នេះគឺជាសំណួរនាំមុខសម្បើមណាស់ ដែលបង្ហាញថា ភស្តុតាងមួយចំនួន ហើយបង្ហាញប្រភព បង្ហាញឯកសារអ្វីទាំងអស់ មិនអាចបង្ហាញអ្វីដែលអាចឱ្យ យើងយល់ឃើញថា សំណួររបស់គាត់ហ្នឹងមានលក្ខណៈសត្យានុម័តនោះទេ។ អ៊ីចឹងសូមឱ្យបង្ហាញ ប្រភព បង្ហាញភស្តុតាង ព័ត៌មានមួយចំនួន ដើម្បីឱ្យអាចចោទសំណួរយ៉ាងដូច្នេះបាន។

[១៣:៥២:៣៩]

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាព័ត៌មានសំខាន់ ប៉ុន្តែអ្វីដែលខ្ញុំចង់បញ្ជាក់គឺ ឯកសារដែលយើងទទួលបាននេះគឺឯកសារ របស់ព្រះរាជអាជ្ញាដែលបានដាក់ចូលទៅក្នុងអ៊ីនធឺហ្វេស ប៉ុន្តែខ្ញុំនឹងបន្តទៅមុខទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំមានសំណួរមួយទៀតដែលចង់សួរលោក លោកសាក្សី។ គឺខ្ញុំចង់សួរទាក់ទងទៅនឹង ស្ថានភាពដែលកងពល៥០២ ត្រូវដោះស្រាយ។ ប្រហែលជាលោកធ្លាប់ឮនៅក្នុងខែកុម្ភៈ មីនា ឆ្នាំ៧៦។ តើលោកធ្លាប់ឮអំពីការទម្លាក់គ្រាប់បែកដោយយន្តហោះចម្បាំងនៅសៀមរាប គឺនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ៧៦ តើលោកបានឮពីព័ត៌មាននេះទេ?

**លោក កែវ គីន៖**

**ឆ៖** បាទ ខ្ញុំអត់ៗឮផង អត់ដឹងផង។ អត់មានឮគេនិយាយអីផង។

**ស៖** ខ្ញុំសួរលោកដូច្នេះ ព្រោះថាលោកនិយាយថា លោកធ្វើការជាប់ជាមួយនឹងមេបញ្ជាការ ល្វៃ។ តើលោកអត់ដែលឮគាត់និយាយអំពីបញ្ហានេះ ឬមួយក៏លោកធ្លាប់ស្តាប់ឮវិទ្យុភ្នំពេញគេនិយាយ អំពីការទម្លាក់គ្រាប់នៅសៀមរាបអី លោកអត់ដែលឮទេ?

**ឆ៖** បាទ អត់ដែលឮផង អត់ឮសោះ។

**ស៖** តើលោកធ្លាប់ឮអំពីការគប់គ្រាប់បែកនៅព្រះបរមរាជវាំង ដែលកើតឡើងនៅក្នុងពេលប្រហែលៗគ្នាហ្នឹង គឺក្នុងខែកុម្ភៈ ឆ្នាំ៧៦ លោកធ្លាប់ឮទេ?

**ឆ៖** បាទ អត់ៗឮ អត់ដឹង អត់ឮគេនិយាយ។ គេអត់ផ្សាយអត់អីផង ស្ងាត់ឈឹង។

[១៣:៥៤:៥៧]

**ស៖** ឥឡូវនេះខ្ញុំនឹងបន្តទៅព្រលានយន្តហោះកំពង់ឆ្នាំង។ លោកបាននិយាយថា លោកគឺជាកម្មាភិបាលមួយរូបក្នុងចំណោមកម្មាភិបាលដំបូងៗគេមកពីកងពល៥០២ ដែលមកដល់ព្រលានយន្តហោះ – ការដ្ឋានព្រលានយន្តហោះនេះ។ ដូច្នេះខ្ញុំចង់ដឹងថា តើនៅក្នុងខេត្តកំពង់ឆ្នាំងហ្នឹង គឺគេមានផ្លូវរត់របស់យន្តហោះរួចទៅហើយ គឺផ្លូវរត់ដែលគេកសាងឡើងដោយពួកអាមេរិករួចទៅហើយ ឬមួយក៏លោកអត់ដឹងទេ? គឺខ្ញុំចង់សួរលោកថា លោកដឹងថាមុនពេលដែលខ្មែរក្រហមកសាងហ្នឹង គឺមានផ្លូវរត់យន្តហោះដែលអាមេរិកាំងកសាងរួចទៅហើយ លោកដឹងទេ?

**ឆ៖** បាទ ដឹងតើ ដឹងព្រលានយន្តហោះមាននៅខាងលិចកំពង់ឆ្នាំងមាន។ ខ្ញុំដឹងថាមានដែរ។

**ស៖** តើៗចម្ងាយពីផ្លូវរត់ចាស់ ហើយមកការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងវាមានចម្ងាយប្រហែលប៉ុន្មានដែរ?

**ឆ៖** ចម្ងាយទៅជិត២០គីឡូ តាមស្មានមើលទៅឆ្ងាយដែរ ពីកំពង់ឆ្នាំងមកក្រាំងលាវណោះ។ ខ្ទង់២០គីឡូហើយយ៉ាង តាមខ្ញុំស្មានដឹងមើលទៅ។

[១៣:៥៦:៤១]

**ស៖** ដូច្នេះកងពល៥០២ អត់ប្រើប្រាស់ផ្លូវរត់ចាស់ហ្នឹងទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អត់ៗផ្លូវ អត់ប្រើប្រាស់ផ្លូវរត់ចាស់ទេ។ ប្រើផ្លូវថ្មី ព្រោះផ្លូវថ្មីហ្នឹងអង្កាល់រត់ហ្នឹងមិនទាន់បានប្រើប្រាស់ផង។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំបន្តទៅនិយាយអំពីការងាររបស់លោក គឺការងារនៅព្រលានយន្តហោះ។ លោកនិយាយថា ការងាររបស់លោកភាគច្រើនគឺ ថែរក្សាជួសជុលរថយន្តនៅហ្គារ៉ាស – នៅយានដ្ឋាន។ ដូច្នេះខ្ញុំចង់ដឹងថាតើអ្វីដែលខ្ញុំនិយាយហ្នឹងគឺជា ទូទៅគឺជាការងាររបស់លោក អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំអត់អ្នកចេះជួសជុល។ ខ្ញុំជួលជុលតែរោង រោងដាក់ឡានហ្នឹង។ ខ្ញុំជួសជុលតែរោងដាក់

ឡានទេ បើថាឡានខ្ញុំអត់ចេះទេ។ ជួលជុលធ្វើតែរោងដាក់ហ្គារ៉ាស ដាក់ឡានហ្នឹង។ ចេះធ្វើតែរោងហ្នឹង បើឡានខ្ញុំអត់ចេះធ្វើទេ អ្នកគេផ្សេង។

**សៈ** តើលោកធ្វើការតែជួសជុលរោងឡានទេ ឬមួយក៏លោកជាអ្នកបើកឡានផងដែរ?

**ឆៈ** បាទ ខ្ញុំៗអត់ទេ អត់ចេះបើកទេ។ ខ្ញុំអត់ចេះបើកឡានទេ ជួសតែជុលរោងឡាន។ រោងដាក់សម្ភារៈផ្សេងៗស្អីៗ គ្រឿងឡានគ្រឿងអីហ្នឹង ខ្ញុំចេះតែជួលជុលធ្វើ។ បើថាឲ្យធ្វើឡាន ចេះជួសជុលឡានអត់ទេ អត់ចេះទេ។

[១៣:៥៨:៥៣]

**សៈ** ខ្ញុំយល់លោក។ ខ្ញុំមិនប្រាកដថាខ្ញុំស្តាប់បាន១០០ភាគរយទេ ប៉ុន្តែខ្ញុំចង់សួរថាតើភារកិច្ចជាចម្បងរបស់លោក គឺថាលោកនៅរោងឡាន ឬក៏ជួសជុលឡានហ្នឹង តើលោកមានការងារអីផ្សេងទៀតដែរឬទេមុនឆ្នាំ៧៩ហ្នឹង ឬមួយក៏លោកធ្វើការងារតែជួសជុលរោងឡាននោះទេ?

**ឆៈ** បាទ រួចពីជួសជុលរោងឡានរោងអីហ្នឹងទៅ រួចនាំគ្នាទៅដាំបន្លែដាំអីហូបខ្លួនឯងហ្នឹងទៅ អត់មានការងារអី បើមានការងារ ធ្វើតែរោងឡាន។ ប៉ុនភាគច្រើនធ្វើរោងឡានពេលថ្ងៃ ខ្មង់ថ្ងៃល្ងាចអីចឹងទៅ ឆ្លៀតកាប់ដីដាំបន្លែហូបខ្លួនឯងខ្លះអីខ្លះអីចឹងទៅ។ អត់មានទៅណាទៀត។

**សៈ** ប៉ុន្តែតើការងារដែលលោកធ្វើគឺ មានតែជួសជុលរោងឡាន ហើយនិងដាំបន្លែទេ? ខ្ញុំចង់និយាយថា លោកធ្វើតែការងារពីរនេះទេឬ រហូតដល់ពេលដែលវៀតណាមចូលមកនោះ?

[១៤:០០:១៨]

**ឆៈ** ធ្វើតែការងារពីរហ្នឹង រួចដល់វៀតណាមចូលមក បានខ្ញុំបែកផ្លូវគ្នាចេញពីព្រលានហ្នឹង។

**សៈ** ខ្ញុំយល់លោកសាក្សី។ តើលោកអាចពន្យល់ខ្ញុំបានទេ ហេតុអ្វីលោកថាការងាររបស់លោកនៅព្រលានយន្តហោះហ្នឹង វាពិបាកជាងនៅពេលដែលលោកនៅសមរភូមិ ព្រោះថានៅពេលដែលលោកនៅសមរភូមិហ្នឹង លោកមានការងារដូចជាលំបាកជាង។ ដូច្នេះខ្ញុំចង់ដឹងថា ហេតុអ្វីបានជាលោកនិយាយថា ចាប់ពីខែកុម្ភៈ មីនា ៧៦ មកការងាររបស់លោកកាន់តែពិបាកជាងមុន។ លោកអាចពន្យល់បានទេ?

**ឆៈ** បាទ ការងារវាពិបាក ពិបាកគេប្រើទាំងយប់ទាំងថ្ងៃ ដូចខ្ញុំថាអីចឹង។ បើមានសួរទំនេរណាបើគេរឹតបន្តឹងវិន័យទៀត។ រឿងពិបាក ពិបាកការងារច្រើន។ មិនមែនពិបាកតែខ្ញុំ ពិបាកទាំងអស់គ្នាបីបួនប្រាំនាក់ហ្នឹង។ ធ្វើមិនទាន់ឲ្យគេ គេរករឿង គេទិតៀនអីចឹងទៅ។ ធ្វើៗជួនកាលខ្លះទាំងស័ង្កសី ខ្លះ

ដែកគោលអ៊ីចឹងទៅ អាល័យតែរត់ទៅរកស័ង្កសីដែកគោលទៅ ធ្វើអត់ទាន់ឲ្យគេ គេរករឿងទៀត។ គេទម្រាំតែដឹកយកមកឲ្យ។

**ស៖** ប៉ុន្តែខ្ញុំចង់ដឹងថា តើការបែងចែកភារកិច្ចហ្នឹង គឺការជួសជុលរោងឡាន ហើយនិងការដាំបន្លែហ្នឹង វាមានការបែងចែកការងារយ៉ាងម៉េចដែរ? ហើយហេតុអីបានជាលោកថា ការងារទាំងពីរហ្នឹងវាពិបាកខ្លាំង?

[១៤:០២:២៩]

**ឆ៖** បាទ ដូចពិបាកដូចខ្ញុំជម្រាបអ៊ីចឹងថា ធ្វើមិនទាន់ឲ្យគេ គេរករឿង គេទិតៀន គេរករឿងយើង។ ហើយការងារដាំបន្លែមិនមែនឈប់ម៉ោងប្រាំ ម៉ោងប្រាំមួយអី នាំគ្នាធ្វើបានកន្លះម៉ោងអ៊ីចឹងទៅហូបបាយហូបអី។ រួចយប់ឡើងម៉ោងប្រាំពីរចូលធ្វើការទៀត។ មានតែប៉ុណ្ណឹង។

**ស៖** លោកគឺជាកងទ័ពបដិវត្តន៍កម្ពុជា ហើយលោកមានភារកិច្ចកសាងនិងការពារជាតិ។ ដូច្នេះកាលដែលលោកមិនមានការឈប់សម្រាកច្រើន អាហ្នឹងមិនមែនជារឿងអ្វីដែលអាក្រក់នោះទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ខ្ញុំស្តាប់លោកអត់ឮ ប៉ុន្តែអំមិញលោកឆ្លើយថា “បាទ” អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** *(គ្មានការបកប្រែ)*

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:០៤:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៦:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី ក្លូឌា ហ្វេនស៍!

**ថៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវីប្រហែលជាដឹងហើយថា អ្វីដែលលោកសួរ គឺជាការបង្ហាញខុសអំពីអង្គហេតុ។ គាត់និយាយថា គាត់មិនមែនដោយសារលំបាក ដោយសារតែអត់មានការឈប់សម្រាកនោះទេ។ ដូច្នេះ ខ្ញុំមិនចង់ឲ្យ -- ខ្ញុំស្នើសុំដល់សាក្សីកុំឲ្យឆ្លើយតទៅទៀត ហើយសំណួរហ្នឹងវាហាក់ដូចជាមានភាពលម្អៀង។

**លោក វ៉ិចទ័រ កូប៉េ៖**

ហេតុអ្វីបានជាដូច្នេះលោកស្រីថៅក្រម ហ្វេនស៍?

**ថៅក្រម ក្លូឌា ហ្វេនស៍៖**

លោកដឹងខ្លួនឯងច្បាស់ហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអត់ដឹងទេ សូមលោកស្រីពន្យល់ខ្ញុំ។

**ថៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំរីករាយនឹង -- ចំពោះខ្ញុំ ខ្ញុំគិតថា ប្រសិនបើលោកស្ថិតនៅក្នុងស្ថានភាពនោះ លោកបានប្រាប់ទៅដល់សាក្សី គំរាមទៅដល់សាក្សី រំឭកទៅដល់សាក្សីអំពីភារកិច្ចរបស់គាត់។ ខ្ញុំគិតថា វាមានវិធីសាស្ត្រផ្សេងទៀតក្នុងការសួរសំណួរ។

[១៤:០៧:១៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនគួរនិយាយអ្វីដែលខ្ញុំចង់និយាយនោះទេ ប៉ុន្តែយ៉ាងក៏ដោយខ្ញុំបន្តទៅមុខទៀតលោកសាក្សី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** កម្មាភិបាលដទៃទៀតមកពីកងពល៥០២ ដែលចាប់ផ្តើមធ្វើការនៅព្រលានយន្តហោះនៅឆ្នាំ៧៦ដែរនោះ។ ឥឡូវនេះខ្ញុំសួរលោកអ៊ីចេះវិញ ថាតើមានកម្មាភិបាល ឬក៏កងទ័ពមកពីកងពល៥០២ប៉ុន្មាននាក់មកធ្វើការនៅព្រលានយន្តហោះ? តើមានកងទ័ពមកពី៥០២ហ្នឹង១០០នាក់, ១.០០០នាក់ ឬក៏ប៉ុន្មាននាក់ដែរ មកធ្វើការនៅព្រលាន?

**លោក កែវ គីន៖**

**ឆ៖** បាទ ខ្ញុំអត់ដឹងចំនួនទេ។ ខ្ញុំអត់ដឹង ដឹងប៉ុន្មានអីប៉ុន្មាន ព្រោះខ្លះគេនៅកំពង់ឆ្នាំង ខ្លះនៅ

ព្រលាន មិនដឹងជាប៉ុន្មាននាក់។ ខ្ញុំអត់ដឹងដែរ។ ដឹងកម្មាភិបាលប៉ុន្មានរូបអីប៉ុន្មានរូប ខ្ញុំអត់ដឹង។

**ស៖** ប៉ុន្តែខ្ញុំចង់ដឹងថា ភាគច្រើននៃកងទ័ពដែលមកធ្វើការនៅចាប់ពីខែកុម្ភៈ មីនា ៧៦ តើពួកគាត់ភាគច្រើនមកពីកងពល៥០២ មែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៤:០៨:៥៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា សំណួរនេះមិនសូវច្បាស់លាស់ទេ ពីព្រោះថាមានលក្ខណៈទូទៅពេក ហើយមិនបានបែងចែកឲ្យច្បាស់ពីដំណាក់កាលនៃការទៅដល់របស់យោធា ឬក៏ពលករនៅលើការដ្ឋាននោះ។ ខ្ញុំមិនដឹងថា បន្ទាប់ពីពួក -- ពីគាត់ទៅដល់ភ្លាម – អានេះខ្ញុំយល់ក៏ប៉ុន្តែត្រូវតែ ដែលពេលយោងទៅដល់ទាហានដែលត្រូវមកពីកងពលផ្សេងទៀតនោះ សំណួរនេះមិនសូវជាច្បាស់លាស់នោះទេ។ ធ្វើឲ្យសាក្សីនេះ គាត់ស្ថិតនៅក្នុងភាពស្រពេចស្រពិល គាត់មិនដឹងថាត្រូវឆ្លើយទៅសំណួររបៀបណា។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** រយៈពេល៦ខែដំបូងដែលលោកបានទៅដល់ទីនោះ តើមានកម្មាភិបាលប្រហែលជាប៉ុន្មាននាក់ទៅធ្វើការនៅទីនោះ? លោកគិតត្រួសៗមើល គឺកម្មាភិបាលមកពីកងពល៥០២ មានប្រហែលជាប៉ុន្មាននាក់ដំបូងឡើយ?

**លោក កែវ គីន៖**

**ឆ៖** បាទ ខ្ញុំត្រួសៗ គិតឃើញទំនងប្រហែលជា១០នាក់ទៅ២០នាក់ហើយតាមមើល ព្រោះខ្ញុំអត់ដឹងច្បាស់អ៊ីចឹង អត់សូវស្គាល់គេទៀតផង។ ដឹងតែប៉ុណ្ណឹង ដឹងតែថាត្រួសៗ ខ្ទង់ៗ១០នាក់ទៅជិត២០នាក់ហ្នឹង ប្រហែលប្រាំដណ្ដាប់នាក់អីហ្នឹង។

[១៤:១០:២៤]

**ស៖** ឥឡូវនេះ ខ្ញុំនិយាយសំដៅទៅលើពេលដែលៗមានកងទ័ពច្រើនមកធ្វើការនៅឯព្រលានយន្តហោះនោះ ៥០០, ៥.០០០។ តើការកសាង -- និយាយកម្លាំង៦ខែដំបូងមានសរុបទាំងអស់ប៉ុន្មាន

លោក ៥០០ ឬក៏៥.០០០ ប្រហែលជាប៉ុន្មាននាក់ដែរ?

**ឆ៖** កសាងពីឆ្នាំ៧៦ដល់៧៧ មិនដឹង ខ្ញុំថាទំនងជា១.០០០នាក់តាមស្មានមើល៍ ព្រោះខ្ញុំវាមិនសូវពិតប្រាកដ មិនសូវប៉ាន់ទៅរៀបរាប់គេទេ អត់ប៉ាន។ តាមស្មានមើល៍ ព្រោះគេយកប៉ុន្មានភូមិភាគហើយ ឃើញគេនៅតាមតែរោង តាមរោងតាមកន្លែងជម្រកគេហ្នឹង នៅឆ្ងាយៗពីគ្នា មិននៅជិតគ្នា ចុងឯកើតចុងឯលិចឯណោះ។ រួចយើងម៉េចដឹង ធ្វើម៉េចស្មានត្រូវ ខ្ញុំអត់ស្មានត្រូវដែរ។

**ស៖** តើទាហានរាប់ពាន់ -- កងទ័ពរាប់ពាន់នាក់ទាំងនេះ ភាគច្រើនមកពីកងពល៥០២ ឬក៏មកពីកន្លែងផ្សេងៗដែរ?

**ឆ៖** មក -- កងទ័ពច្រើនតែមកពី៥០២ ហើយនិងបូព៌ា និរតីហ្នឹង មកច្រើនតែមិនដឹងមួយភូមិភាគៗហ្នឹងមកប៉ុន្មានរយនាក់ បើខ្ញុំអត់ដឹង អត់ដឹងច្បាស់។ គ្រាន់តែឃើញមកធ្វើឲ្យពេញព្រលានហ្នឹង។ ថ្ងៃត្រង់ថ្ងៃអីទៅ គេទៅសម្រាកកន្លែងគេបាត់ទៅ ហើយកន្លែងមានជិតៗគ្នាឯណា កន្លែងឆ្ងាយៗទាល់ទៅដល់ពេលធ្វើការបានមកក្នុងព្រលានហ្នឹង បានដឹង ឃើញមនុស្សច្រើន ហើយគេៗចេញទៅខ្លះខាងបើកឡានបើកអីគេចេញទៅណាទៅណីអស់ ហើយខ្ញុំស្មានអត់ត្រូវ។

[១៤:១២:៥៣]

**ស៖** ឥឡូវសូមឲ្យលោកផ្តោតទៅលើតែកងទ័ពមកពីកងពល៥០២។ នៅពេលដែលលោកធ្វើទីនោះនៅក្នុងឆ្នាំ១៩៧៧ លោកបានឆ្លើយថា អ្នកទាំងនោះធ្វើការ ឲ្យធ្វើការទីនោះដោយសារតែជាកងទ័ពដែល -- ដោយសារកងទ័ពទាំងនោះជាផ្នែកមួយនៃកងទ័ពអាកាស។ តើអ្នកទាំងនោះជាកងទ័ពអាកាសសុទ្ធ ឬក៏មកពីតំបន់ផ្សេងៗដែរ?

**ឆ៖** បាទ អត់មានមកពីកងទ័ពអាកាសសុទ្ធទេ មានតែមកពីតំបន់ តាមតំបន់ តាមបារ៉ាក់អីខ្លះអីចឹងដែរ អត់រួមគ្នា ជួនកាលមកពីស្រុក ព្រោះពួកអាកាសនេះទៅ អត់ស្គាល់កន្លែងទឹកដីហ្នឹង មានសុំកន្លែងស្រុកកន្លែងអី ស្នើកន្លែងស្រុកអីពីរបីនាក់អីចឹងមក ឲ្យគេដើរបង្ហាញអីចឹងទៅ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ប៉ុន្តែតើលោកដឹងថាកម្លាំងដែលមានកងទ័ពរាប់ពាន់នាក់នេះត្រូវបានគេបញ្ជូនទៅឲ្យធ្វើការព្រលានយន្តហោះកំពង់ឆ្នាំង ដោយសារតែអ្នកទាំងនោះគឺជាកងទ័ព ជាភារកិច្ចរបស់កងទ័ព ឬក៏អ្នកទាំងនោះត្រូវបានបញ្ជូនទៅឲ្យធ្វើការនៅព្រលានយន្តហោះនោះដោយៗ គឺជារូបភាពនៃការដាក់ទណ្ឌកម្ម?

**ឆ៖** តាមខ្ញុំស្មានមើល៍ ប្រហែលជាបញ្ជូនមកឲ្យតាមភារកិច្ចខ្លះ ក៏ដាក់ទណ្ឌកម្មខ្លះ បើមិនដាក់ម៉េច បើធ្វើការដូចខ្ញុំជម្រាបខាងដើមអីចឹង បាយទឹកក៏មិនគ្រប់គ្រាន់ផង។ រួចតែខុសបន្តិចបន្តួច គេបញ្ជូន

គេចាប់បញ្ជូនចាប់អីហ្នឹង គេកសាងកអីអ៊ីចឹង។

[១៤:១៥:០៦]

**ស៖** ឥឡូវនេះសូមផ្តោតទៅលើក្រុមចុងក្រោយនេះ លោកអាចផ្តល់ឧទាហរណ៍បានទេ ពីកងទ័ពដែលមកពីភូមិភាគផ្សេង ដែលមកធ្វើការនៅតាំងពីឆ្នាំដំបូងដែលមកពីភូមិភាគផ្សេងៗ ដែលគេឲ្យមកធ្វើការដែលគិតថា ជាការដាក់ទណ្ឌកម្ម។ លោកមានចាំឈ្មោះកងទ័ពណាខ្លះដែរទេ ដែលមកពីភូមិភាគផ្សេងៗនោះ?

**ឆ៖** ខ្ញុំអត់បានចាំទេ ដឹងតែចាំថាភូមិភាគហ្នឹង។ ឮតែគេនិយាយថាភូមិភាគនេះ ភូមិភាគនោះ ភូមិភាគបូព៌ា ភូមិភាគនិរតីតែម្តង។ តែមិនដឹងកងទ័ពណា ខ្ញុំអត់ចាំ អត់ៗដឹង។ ឮតែគេថា ភូមិភាគបូព៌ា ភូមិភាគនិរតី ភូមិភាគបស្ចិមអ៊ីចឹង។

**ស៖** ខ្ញុំគិតថា កងទ័ពរាប់ពាន់នាក់ មកពីភូមិភាគផ្សេងៗ នៅឆ្នាំដំបូងនោះ គឺមកធ្វើការដូចៗគ្នានៅព្រលានយន្តហោះ។ តើកងណា ក្រុមណាដែលគេឲ្យមកធ្វើការ ហើយលោកគិតថា គឺជាការដាក់ទណ្ឌកម្មនោះ? លោកអាចបញ្ជាក់បានទេ កងណា ក្រុមណា?

**ឆ៖** បាទ ខ្ញុំដឹងតែខាងភូមិភាគបូព៌ាហ្នឹងតែម្តង គេដាក់ទណ្ឌកម្មច្រើន ព្រោះៗឃើញតែចាប់កងហ្នឹងច្រើនជាងគេ។

[១៤:១៧:០១]

**ស៖** ឥឡូវយើងចាប់បន្តនិយាយអំពីកងទ័ពមកពីភូមិភាគបូព៌ា។ តើកងទ័ពភូមិភាគបូព៌ាហ្នឹងមកដល់ព្រលានយន្តហោះដំបូងនៅពេលណា? ឆ្នាំ១៩៧៦ ឬ១៩៧៧ ឬក៏១៩៧៨?

**ឆ៖** ខ្ញុំចាំប្រហាក់ប្រហែលជាឆ្នាំ៧៧ មកដល់។

**ស៖** តើវាអាចជាចុងឆ្នាំ១៩៧៧ដែរឬអត់ទេ?

**ឆ៖** អត់ៗចុងឆ្នាំទេកាលនុ៎ង ពាក់កណ្តាល បើមិនពាក់កណ្តាល ដើមឆ្នាំ៧៧ហ្នឹង ព្រោះខ្ញុំអត់បានគិត អត់បានចាំឲ្យច្បាស់លាស់។

**ស៖** ខ្ញុំយល់ហើយ។ ឥឡូវយើងនិយាយអំពីកងទ័ពដែលលោកបានឃើញធ្វើការនៅព្រលានយន្តហោះ នៅពាក់កណ្តាលឆ្នាំ១៩៧៦។ តើលោកអាចបញ្ជាក់ថា កងទ័ពធ្វើការនៅព្រលានយន្តហោះ ១៩៧៦នោះ ធ្វើម៉េចបានជាលោកអាចយល់ថា ជាការដាក់ -- ជាការយកមកឲ្យលត់ដំ?

**ឆ៖** ព្រោះខ្ញុំដឹងថា ពេលមកចូលធ្វើការនៅឆ្នាំ១៩៧៦ ព្រោះធ្វើការខ្លាំងជាងៗនៅតាមកន្លែង

មុនៗ។ នេះធ្វើទាំងព្រឹក ទាំងល្ងាច ទាំងយប់ អត់មានពេលសម្រាក។ រឿងបាយទឹកខ្លះក៏បានគ្រប់គ្រាន់ ខ្លះក៏អត់។ ខ្ញុំសន្និដ្ឋានថាយ៉ាងអ៊ីចឹង។ រកតែពេលសម្រាកគ្មានផង។

[១៤:១៩:៣០]

**ស៖** លោកសាក្សី ខ្ញុំសួរលោកអំពីឆ្នាំ១៩៧៦។ លោកឆ្លើយថា កងទ័ពមកពីភូមិភាគបូព៌ា គេបញ្ជូនមកដើម្បីយកមកឲ្យលត់ដំកែប្រែ។ តើលោកអាចធ្វើការកត់សម្គាល់ណាមួយថា ក្នុងឆ្នាំ១៩៧៦ លោកអាចសន្និដ្ឋានបាន មានមូលហេតុអីដែរ ដែលបញ្ជាក់ថាគេបញ្ជូនមក៧៦ហ្នឹង គឺយកមកឲ្យលត់ដំកែប្រែនោះ?

**ឆ៖** បាទ ខ្ញុំកត់សម្គាល់ត្រង់ថា តាំងពីការហូបចុក ដើរហើរ ទៅណេះទៅណោះអី ធ្វេចធ្វាច ទៅណេះទៅណោះ អត់បាន នៅតែមួយកន្លែង មានគេដើរមើល ដើរយាមដើរកាមអ៊ីចឹង បានខ្ញុំថាដូចជារឹតបន្តឹង ដូចជាដាក់ទណ្ឌកម្មគ្នាពេកហើយ។ រួចមានបានដើរទៅណេះទៅណោះ ងូតទឹកងូតអីស្រួលបួលណា៎ អត់។ ងូតទឹក ឈប់សម្រាកងូតទឹកបានតែមួយភ្លែត ធ្វើការធ្វើងារទៀតបាត់ អ្នកខ្លាំង។ ព្រោះអត់មានសិទ្ធិសេរីភាព អត់មានបានដើរសោះ បានខ្ញុំថាដូចដាក់ទណ្ឌកម្មគាត់។

**ស៖** ព្រឹកមិញលោកបានឆ្លើយថាលោកត្រូវបានអនុញ្ញាតឲ្យដើរ ឲ្យចាកចេញពីព្រលានយន្តហោះទៅធ្វើការនៅតាមវាលស្រែនានា ជួយធ្វើការប្រជាជន។ តើធ្វើម៉េចបានវា លោកអាចប្រៀបធៀប -- ម្តងលោកឆ្លើយថា គេឲ្យលោកដើរចេញ ហើយម្តងទៀតលោកថាអត់ឲ្យ។ ខ្ញុំសូមដកសំណួរនេះវិញ សូមដកសំណួរនេះចោលវិញ។ លោកសាក្សី នៅក្នុងឆ្នាំ១៩៧៦ លោកមានបានដឹងទេថា កងទ័ពហ្នឹង គេឲ្យធ្វើស្រែហ្នឹង គឺគេឲ្យអង្ករប៉ុន្មានថាំងដែរសម្រាប់កងទ័ព?

[១៤:២១:៤៥]

**ឆ៖** បាទ អត់មានឲ្យផង។ គ្រាន់ដូចថាជួយប្រជាជនពលរដ្ឋអ៊ីចឹង អត់មានឃើញបានអង្ករបានស្រូវអីផង។ និយាយរួមទៅ អត់ឃើញហ្មង។

**ស៖** តើលោកដឹងទេ ចំនួនស្រូវអង្ករ ដែលបានផ្តល់មកឲ្យលោកឆ្នាំ១៩៧៦ គឺថាចំនួនអង្ករហ្នឹង គេឲ្យមកហ្នឹងគឺសម្រាប់កងទ័ពទាំងអស់ ៦.០០០នាក់នៅក្នុងកងពល៥០២ហ្នឹង ឬក៏យ៉ាងម៉េច? ខ្ញុំរៀបសំណួរឡើងវិញ តើមានភាពខុសគ្នាទេនៅក្នុងកងពល៥០២ រវាងកងវរសេនាតូច កងវរសេនាធំ កងអនុសេនាធំ កងអនុសេនាតូចជាដើម។ល។ គឺថាកងនីមួយៗហ្នឹង ចំនួនបរិមាណអង្ករដែលគេចែកមកឲ្យហ្នឹងខុសៗគ្នាទេ ពីកងមួយទៅកងមួយនៅក្នុងកងពល៥០២ហ្នឹង?

**ឆ៖** ខ្ញុំអត់សូវដឹងដែរ ព្រោះឃើញតែគេចែកតាមក្រុមឲ្យ។ កំណត់មួយអាទិត្យ គេចែកឲ្យមួយអាទិត្យអ៊ីចឹងទៅ។ មួយក្រុមហ្នឹងចែកឲ្យមួយអាទិត្យ អង្ករប៉ុន្មានគីឡូៗ គេកំណត់ឲ្យហ្នឹង។ ប៉ុនដាំបាយអត់មានរឹងទេ ដាំបាយជ្រាយដូចបបរដែរ។ វាគ្រាន់បើជាងបបរបន្តិច។ រឿងអង្ករចែកឲ្យតាមកងផ្សេងៗទៀត ខ្ញុំអត់ដឹងទេ។

[១៤:២៣:៣០]

**ស៖** លោកដឹងថាមានភាពខុសគ្នាទេ រវាងកងតូច កងធំនីមួយៗនៅចំណុះឲ្យកងពល៥០២ហ្នឹង ឬក៏ថាកងទ័ពនៅក្នុងកងអនុសេនាតូច នៅក្នុងកងអនុសេនាធំហ្នឹងបានទទួលអង្ករហ្នឹងដូចៗតែគ្នាទេ?

**ឆ៖** បាទ ខ្ញុំអត់សូវដឹងច្បាស់ដែរ មិនដឹងគេបានដូចគ្នា មិនដឹងអត់មិនដឹង បើនិយាយរួមទៅតាមក្រុមគេៗទៅយក ខ្ញុំមិនដឹងថាបានអង្ករដូចគ្នា មិនដឹងក៏អត់ ព្រោះខ្ញុំអត់បានដឹង។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែមេកង ឬមេកងតូច មេកងធំ មេបញ្ជាការអនុសេនាធំ មេបញ្ជាការវរសេនាតូច មាននិយាយថា ន៎! កងរបស់លោកតែម្តង គឺទទួលបានអង្ករតិចជាងកងដទៃទៀត។ គាត់មានដែលបាននិយាយថាអ៊ីចឹងទេ?

**ឆ៖** បាទ មាន។ មានឮនិយាយអ៊ីចឹងដែរ។ តែកងគេបានប៉ុនណាៗ ខ្ញុំអត់ដឹង។ មិនដឹងគេបានតិច មិនដឹងគេបានច្រើន អានេះរស់នៅតាមកន្លែងរៀងៗខ្លួន។

[១៤:២៥:១៣]

**ស៖** លោក ដូច្នេះគឺថាលោកអាចឆ្លើយបានតែចំពោះកងរបស់លោកមួយទេ គឺកងរបស់លោកដែលធ្វើការនៅរោងឡាន។ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ។ ខ្ញុំដឹងតែរោង ដឹងតែកងខ្ញុំហ្នឹង ដឹងតែប៉ុណ្ណឹង។ កងគេដទៃទៀត ខ្ញុំអត់ដឹង។

**ស៖** តែធ្លាប់ដែលឮពីមេកងរបស់លោក មេបញ្ជាការរបស់លោក ឬក៏ពីអ្នកណាម្នាក់នៅក្នុងកងពលរបស់លោកហ្នឹង អំពីជម្លោះប្រដាប់អាវុធនៅ -- ជម្លោះប្រដាប់អាវុធរវាងកងទ័ពភូមិភាគបូព៌ា និងកងទ័ពមជ្ឈិមដែរទេ?

**ឆ៖** បាទ អត់ដឹងផង។ ខ្ញុំអត់ឮមេកងមេក្រុមជជែកអ៊ីចឹងទេ អត់ៗដឹង។

**ស៖** នៅក្នុងឆ្នាំ១៩៧៨ លោកមានដែលឮអំពីការបះបោររបស់កងទ័ពភូមិភាគបូព៌ាទេ?

**ឆ៖** បាទ អត់ដឹងផង។ ឮតែគេថា រោងចក្របះបោរបះអីអ៊ីចឹង ប៉ុន្តែឮថាកងទ័ព អត់មានឮ។

ឮតែគ្នាគេ គេនិយាយគ្នាអ៊ីចឹង ដែលខ្ញុំឮតាមជិតៗស្គាល់គ្នាគេនិយាយអ៊ីចឹង ហើយនៅក្នុងក្រុមគ្នាខ្ញុំអីគេនិយាយអ៊ីចឹង។

[១៤:២៧:១១]

**ស៖** តើលោកធ្លាប់ឮកងទ័ពរាប់រយពាន់នាក់ កងទ័ពខ្មែរក្រហមរាប់រយពាន់នាក់ស្លាប់នៅក្នុងពេលប្រយុទ្ធគ្នាពាក់កណ្ដាលឆ្នាំ១៩៧៨ ចុងឆ្នាំ១៩៧៨ នៅពេលប្រយុទ្ធគ្នាជាមួយវៀតណាមនោះដែរឬទេ?

**ឆ៖** បាទ អត់ដឹងផង។ អត់ឮគេនិយាយអត់អីផង។

**ស៖** តើលោកធ្លាប់ឮកងទ័ពភូមិភាគបូព៌ាត្រូវចាត់ទុកថាជា ទៅជាឈ្លើយសឹកដែរឬទេ?

**ឆ៖** បាទ ខ្ញុំឮគេនិយាយអ៊ីចឹងដែរ។ គេនិយាយតៗតែគ្នានៅក្នុងក្រុម ដូចខ្ញុំជម្រាបអ៊ីចឹង ឮតែគេនិយាយអ៊ីចឹង។

**ស៖** តើលោកឮអ្វីពិតប្រាកដអំពីបញ្ហាដែរខ្ញុំសួរអម្បាញ់មិញនេះ?

**ឆ៖** ពិតប្រាកដឮមកក្នុងក្រុមគ្នាឯងនិយាយ បានខ្ញុំដឹង។ ចេះតែចាំស្ដាប់គេទៅ។

**ស៖** តើលោកនៅចាំអ្វីដែលគេបាននិយាយមកកាន់លោកហ្នឹងទេ?

**ឆ៖** ខ្ញុំអត់ចាំផង។

[១៤:២៩:០៥]

**ស៖** តើលោកនៅចាំឈ្មោះកងពលផ្សេងៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺថាកងទ័ពបដិវត្តន៍កម្ពុជា? ឧទាហរណ៍ ចំនួនកងពលនៃកងទ័ពភូមិភាគបូព៌ា។ លោកគឺជាទាហានម្នាក់ចំណុះឲ្យកងពល៥០២ ចុះកងពលភូមិភាគបូព៌ាមានឈ្មោះ -- មានលេខប៉ុន្មានដែរ? លោកចាំទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។ អត់ដឹងកងពលលេខប៉ុន្មានអីប៉ុន្មាន ខ្ញុំអត់ដឹង។

**ស៖** លោកចាំចំនួនកងពលមកពីភូមិភាគផ្សេងៗទៀតទេ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះ អំពីចំនួនទីប្រឹក្សាចិនធ្វើការនៅព្រលានយន្តហោះបានទេ? តើដំបូងឡើយមានជំនួយការចិនប៉ុន្មាន ហើយក្រោយមកទៀតមានជំនួយការចិនសរុបប៉ុន្មានដែរណេះ?

**ឆ៖** ខ្ញុំអត់ដឹងទេក្រោយមក ដឹងពីមុន១០នាក់ហ្នឹងខ្ញុំដឹង ខាងពិសោធន៍ដី ខាងវាស់វែង ហើយ

ខាងមើលផែនទីមើលអី ខ្ញុំដឹង ដឹងតែ១០នាក់ហ្នឹងមុនដំបូង។ ដល់មកក្រោយៗទៀត ខ្ញុំអត់ដឹង ដឹងប៉ុន្មានអីប៉ុន្មាន។ គេទៅខាងផ្នែកអាគ្រាក់ ផ្នែកឡាន ផ្នែកស្អីគេផ្សេងៗទៅ តែដឹងប៉ុន្មាននាក់ ឃើញឡានខូចអីចិនធ្វើដែរ។ តែដឹងប៉ុន្មាននាក់ៗ ខ្ញុំអត់ដឹងទេ។

[១៤:៣១:២០]

**ស៖** តើលោកធ្លាប់ឮសួរថាមានទីប្រឹក្សាកង -- ទីប្រឹក្សាខាងផ្នែកខាងកងទ័ពរបស់ចិនហ្នឹងមានរហូតទៅដល់៦.០០០នាក់ឯណោះ លោកធ្លាប់ឮអ៊ីចឹង? ខ្ញុំសូមដកសំណួរនេះឡើងវិញ។ លោកសាក្សីនៅចំណុចមួយលោកបានឆ្លើយថា មានការឃ្លាំមើលទៅលើកងទ័ព។ តើវាមាន -- តើការតាមឃ្លាំមើលកងទ័ពទាំងអស់ហ្នឹង គឺដោយសារតែបញ្ហាសន្តិសុខផ្ទៃក្នុង ឬក៏ដោយសារតែបញ្ហាសន្តិសុខផ្ទៃក្រៅ?

**ឆ៖** ខ្ញុំតាមមើល ដឹងគេឃ្លាំមើលៗដូចគេ ឃើញតែគេហ្នឹង មិនដឹងមើលយ៉ាងម៉េចទៀតសន្តិសុខអីស្អីៗ ខ្ញុំអត់ដឹង អត់ៗដឹងទេ។ ដឹងគេរកខាងសន្តិសុខស្អីៗ ខ្ញុំអត់ដឹងដែរ ប៉ុន្តែខ្ញុំធ្វើហ្គារ៉ាសឡានហ្នឹង ខ្ញុំឃើញតែគេធ្វើឡានធ្វើអី ខ្ញុំចេះតែពិនិត្យមើល គេឃើញគេបីបួនប្រាំនាក់អ៊ីចឹង ខ្ញុំថាប៉ុណ្ណឹង។ ខ្ញុំដឹងច្បាស់ប៉ុនណា ខ្ញុំថាតែប៉ុណ្ណឹងតែម្តង។

**ស៖** តើវាត្រឹមត្រូវដែរឬក៏អត់ទេ បើសិនជាខ្ញុំនិយាយថា ការកសាងព្រលានយន្តហោះហ្នឹងគឺថាលាក់ការណ៍សម្ងាត់បំផុត គឺគេមិនឲ្យអ្នកណាម្នាក់ដឹងទេ? បើខ្ញុំនិយាយថាអ៊ីចឹង តើត្រឹមត្រូវដែរឬក៏អត់ទេ?

**ឆ៖** បាទ ខ្ញុំថាបើអត់មានឲ្យពីណាចូល ប្រជាពលរដ្ឋអត់ចូល មានតែគេលាក់ការណ៍សម្ងាត់ដូចគាត់ថាត្រឹមត្រូវដែរនោះ។ អត់មានពីណាដើរចូលបាន មានតែកងទ័ពហ្នឹងតែម្តង ប្រជាជនអីអត់ចូលបានទេ។

[១៤:៣៣:៣៦]

**ស៖** តើវាអាចទេថា ការឃ្លាំមើលកង -- ឃ្លាំនេះគឺដើម្បីតែគេឃ្លាំមើលតែកងទ័ពធ្វើការនៅឯព្រលានយន្តហោះហ្នឹង ឬក៏គេឃ្លាំមើលហ្នឹងដើម្បីកុំឲ្យមានការជ្រៀតចូល ឬក៏ឈ្លានពានចូលពីសំណាក់កងទ័ពដទៃ?

**ឆ៖** គេឃ្លាំមើលអត់ឲ្យប្រជាពលរដ្ឋចូលអី។ តាមមើល បើអត់ឃើញប្រជាជនសោះ ហើយកងទ័ពដទៃណាក៏អត់មានឃើញមកផង ឃើញតែក្រុមចិនដែលខ្ញុំថា១០នាក់ដំបូងហ្នឹង។ មកធ្វើការឃើញតែប៉ុណ្ណឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

[១៤:៣៤:៤៥]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបលោក កែវ គីន។ ខ្ញុំមានសំណួរមួយចំនួនចង់សួរលោកបញ្ជាក់។ ជាដំបូងខ្ញុំចង់សួរពីរឿងតួនាទីរបស់លោកនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ លោកបានបញ្ជាក់ថា លោកបានទៅដំបូងក្នុងរវាងខែ២ ឬខែ៣ ឆ្នាំ១៩៧៦ ដើម្បីទៅធ្វើការវាស់វែងជាមួយនឹងអ្នកជំនាញចិន ហើយមានឈ្មោះ សុង ជាមេក្រុមរបស់លោក។ ហើយបន្ទាប់មកលោកត្រូវគេបញ្ជូនឲ្យទៅធ្វើការនៅឯរោងជាង ក្រោមការគ្រប់គ្រងរបស់ឈ្មោះ ស៊ុំ។ អ៊ីចឹងទាំងពីរនេះ ជាការងាររបស់លោកប្រចាំតាំងពីចាប់ផ្តើមដែលលោកធ្វើការកំពង់ឆ្នាំង នៅការដ្ឋានកំពង់ -- ព្រលានយន្តហោះកំពង់ឆ្នាំងរហូតដល់ពេលបញ្ចប់។ អ៊ីចឹងត្រឹមត្រូវទេ?

**លោក កែវ គីន៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់រយៈពេលដែលលោកទៅធ្វើការក្នុងក្រុមវាស់វែងដឹកនាំដោយឈ្មោះ សុង បានទេ? រយៈពេលប៉ុន្មានខែដែរ តាំងពីលោកទៅដល់?

**ឆ៖** បាទខ្ញុំដើរធ្វើការទីនោះបានប្រហែលជាងមួយអាទិត្យ បានគេដកចេញ។ អត់បានដើរបានយូរផង។ ជាងមួយអាទិត្យអីហ្នឹង។

[១៤:៣៦:៤៩]

**ស៖** បាទ សូមអរគុណ។ ក្នុងពេលដែលដកចេញ ដកទៅកន្លែងរោងជាងហ្នឹងភ្លាម ឬមួយក៏លោកត្រូវបានបញ្ជូនទៅកន្លែងផ្សេងក្នុងរយៈពេលណាមួយ?

**ឆ៖** បាទ ខ្ញុំដកទៅនៅកន្លែងរោងជាងតែម្តង អត់មានទៅណាទៀត។ នៅកន្លែងធ្វើរោងឡាន

ហ្នឹងតែម្តង អត់មានដើរទៅឯណាធ្វើការធ្វើអីទៀត អត់ទេ នៅតែកន្លែងធ្វើតែរោង។

**ស៖** បាទសូមអរគុណ។ នៅកន្លែងធ្វើរោង ខ្ញុំចង់សួរបញ្ជាក់ពីការងាររបស់លោកបន្ថែមបន្តិចថាតើលោករោងដែលធ្វើហ្នឹង វាជារោងនៅកន្លែងតែមួយ ឬមួយក៏រោងធ្វើមានការផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយ?

**ឆ៖** បាទ ធ្វើផ្លាស់ៗ ផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ ជុំវិញព្រលានហ្នឹង។ ធ្វើរួចមួយ ទៅធ្វើឯណោះមួយទៀត ធ្វើកន្លែងឡានកន្លែងអី រ៉ូឡូកន្លែងអាត្រាក់ណោះ មិនមែនធ្វើជាប់គ្នាឯណាអត់ទេ។ ផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ។

**ស៖** បាទ សូមអរគុណ។ កន្លែងដែលលោកធ្វើហ្នឹងនៅបំលាស់ទីជុំវិញបរិវេណការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង ឬមួយនៅខាងក្រៅ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

[១៤:៣៨:៤៧]

**លោក កែវ គីន៖**

**ឆ៖** បាទ នៅខាងក្រៅព្រលានប្រហែលជា២០ម៉ែត្រ ៣០ម៉ែត្រហ្នឹង អត់មាននៅឆ្ងាយពីព្រលានទេ ធ្វើជុំវិញហ្នឹង។ មួយកន្លែងបីបួនប្រាំៗ ប្រវែងប្រាំបីប្រាំបួនម៉ែត្រ ទទឹង៦ម៉ែត្រ ៧ម៉ែត្រអីចឹងទៅ។ អត់មានធ្វើក្រៅព្រលានឆ្ងាយទេ ធ្វើនៅជិតៗ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ លោកចាំបានទេថា ចំនួនរោងដែលលោក -- ដែលក្រុមរបស់លោកបានសាងសង់ហ្នឹងមានប៉ុន្មាន នៅជុំវិញបរិវេណព្រលានហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ បើយូរពេកទៅហើយ មិនដឹងប៉ុន្មានអីប៉ុន្មាន។ ដឹងតែធ្វើជុំវិញព្រលានហ្នឹង ធ្វើពីខាងកើតធ្វើពីខាងលិច។ ដឹងតែប៉ុណ្ណឹង បើចំនួនអត់ដឹង។

**ស៖** លោកអាចបញ្ជាក់បានទេ សំណង់ដែលលោកធ្វើហ្នឹងអំពីអ្វីដែរ?

**ឆ៖** បាទ ធ្វើពីឈើយើងធម្មតា ឈើរោងម៉ាស៊ីនគេអារជិតហ្នឹង។ ហើយយកធ្វើរោងឡានហ្នឹងទៅ អត់មានធ្វើបានស៊ីម៉ង់ត៍អីទេ ធ្វើបានឈើតែម្តង។

[១៤:៤០:២៦]

**ស៖** បាទ ការងារដែលលោកធ្វើរោងដាក់ឡាន ឬក៏គ្រឿងយន្តផ្សេងៗហ្នឹង ចាប់ធ្វើតរហូតគ្មានថ្ងៃឈប់ ឬក៏មានពេលខ្លះដែលលោកសង់រោងនៅកន្លែងមួយរួចរាល់អស់ហើយ លោកឈប់សិន ហើយក្រោយមក មួយរយៈក្រោយមកបានចាប់ផ្តើមសង់នៅកន្លែងមួយទៀត?

**ឆ៖** បាទ អត់ទេ។ ធ្វើរួចមួយចូលមួយៗ អត់មានសម្រាកទេ សម្រាកតែពេលដូចខ្ញុំជម្រាបសម្រាកតែហូបបាយ សម្រាកតែពេលយប់អីហ្នឹង។ យប់ក៏អត់សម្រាកដែរ ប៉ុន្តែមិនមែនធ្វើឡានហ្នឹង -- មិនមែនធ្វើរោង រើសគល់រើសអីផ្សេងៗទៅ។ បើឲ្យធ្វើរួចមួយ ឈប់អី អត់ទេ ធ្វើរហូត។

**ស៖** បាទ សូមអរគុណ។ មុននេះខ្ញុំបានស្តាប់ឮលោកមានប្រសាសន៍អំពីការទៅជួយស្ទូង ហើយនិងមានការដាំបន្លែ។ ហើយមុននេះបន្តិចអំមិញលោកថា មានការរើសគល់រើសអីផ្សេងៗ។ ខ្ញុំចង់សួរបន្ថែមថា លោកមានទៅធ្វើការផ្នែកវាយថ្ម ឬក៏ខួងថ្មផ្សេងទៀតទេ ក្រៅពីការងារដែលខ្ញុំបានរៀបរាប់ជូនអំមិញ?

**ឆ៖** បាទ ខ្ញុំអត់មានទៅទេ ទៅវាយថ្មវាយអី អត់ទៅទេ។ ទៅដាក់ចុចបំផ្ទុះយកថ្មអី អត់ៗទៅទេ ក្រុមគេផ្សេង។ ខ្ញុំដឹងតែនៅកន្លែងធ្វើរោងហ្នឹងតែម្តង។

**ស៖** បាទ សូមអរគុណ។ លោកអាចបែងចែកពេលវេលាបានទេថា ការងារធ្វើរោង និងការងាររើសគល់ឈើ បូកជាមួយនឹងការងារដាំបន្លែ ហើយនិងស្ទូងស្រូវជាដើម តើការងារណាដែលចំណាយពេលច្រើនជាងគេ ហើយអាចជាប៉ុន្មានភាគរយដែរក្នុងពេលវេលាតាំងពីចាប់ផ្តើមរហូតដល់ចុងបញ្ចប់នៃការងារដែលលោកធ្វើនៅការដ្ឋានកំពង់ឆ្នាំង?

[១៤:៤៣:០៥]

**ឆ៖** បាទ ការងារធ្វើរោង ធ្វើចាប់ពីម៉ោងប្រាំមួយ -- ម៉ោងប្រាំពីរទៅទល់ម៉ោងដប់ -- អំម៉ោងដប់មួយ សម្រាក។ ពេលព្រឹកបើអត់ទេ ទៅស្ទូងដូចខ្ញុំជម្រាបអីចឹង។ ពេលព្រឹកម៉ោងបួនកន្លះ ទៅម៉ោងប្រាំកន្លះឡើង ហើយពេលថ្ងៃល្ងាចចេញពីធ្វើរោងមកម៉ោងបួន ឬម៉ោងប្រាំ យើងកាប់ដីដាំបន្លែ។ ម៉ោងប្រាំពីរយើងចាប់ផ្តើមទៅធ្វើយប់ទៀត ទល់ម៉ោងដប់កន្លះ។

**ស៖** បាទ សូមអរគុណ។ អាហ្នឹងជាការងារប្រចាំថ្ងៃរបស់លោក អីចឹងមែនទេ?

**ឆ៖** បាទៗជាការងារប្រចាំថ្ងៃ។ ក្រៅពីការងារដូចខ្ញុំធ្វើ ដូចការងារស្នូលធ្វើរោងធ្វើអីមក យើងឆ្លៀតពេលធ្វើដូចដាំបន្លែ ដូចគេឲ្យទៅស្ទូងទៅអី ទៅៗ។ ហើយយប់ដូចខ្ញុំជម្រាបអីចឹង យប់ៗពីម៉ោង

ប្រាំមួយ ម៉ោងប្រាំពីរទៅម៉ោងដប់ខ្លះកន្លះហ្នឹង--

**ស៖** បាទៗ។

**ឆ៖** រើសគល់ រើសអីហ្នឹងហើយ។

**ស៖** មុននេះអំមិញ លោកមានប្រសាសន៍ថា ជួនកាលការងារធ្វើរោង អត់បានធ្វើទេ ហើយបើទំនេរគេឲ្យទៅរើសគល់ឈើ។ អ៊ីចឹងខ្ញុំចង់បញ្ជាក់សួរថា ការងារដែលរើសគល់ឈើ ហើយនិងការងារធ្វើរោងហ្នឹងវាមានភាពខុសគ្នា ចំណាយពេលខុសគ្នាយ៉ាងម៉េចដែរ វាគិតជាភាគរយបានទេ? អាចថាធ្វើរោងប៉ុន្មានថ្ងៃ ហើយទៅរើសគល់ឈើប៉ុន្មានថ្ងៃ?

[១៤:៤៥:០៨]

**ឆ៖** បាទ ធ្វើរោងធ្វើពេលថ្ងៃ។ រើសយើងរើសពេលយប់។ មិនមែនធ្វើថ្ងៃ រើសឫសគល់ អត់ទេ ធ្វើរោង ថ្ងៃឡើងបានធ្វើរោង យប់ឡើងយើង នេះគេឲ្យរើសគល់រើសអី។ គេដាក់ភ្លើងអគ្គិសនី គេដាក់ភ្លើងអំពូលអីឲ្យយើងមើលដែរ។ ទាល់តែម៉ោងដប់កន្លះ ដូចខ្ញុំជម្រាបអ៊ីចឹង។

**ស៖** បាទៗ--

**ប្រធានអង្គជំនុំ៖**

បាទៗ បានហើយមេធាវី។ បាទ ឥឡូវនេះដល់ពេលម៉ោងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែកសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក កែវ គីន ខ្ញុំសូមបន្តសំណួរ។ មុននេះលោកបានរៀបរាប់អំពីការងារស្នូលរបស់លោកធ្វើការនៅរោងជាង ហើយដែលជាការងារប្រចាំថ្ងៃរបស់លោក លោកធ្វើរៀងរាល់ថ្ងៃ ហើយមានពេលខ្លះលោកទៅស្ទូង ជួយស្ទូងប្រជាពលរដ្ឋជាដើម។ ឥឡូវខ្ញុំចង់សួរបន្ថែមទាក់ទងទៅនឹងការស្ទូងនេះ។ ដោយសារលោកទៅធ្វើការនោះពីឆ្នាំ៧៦ ក្នុងខែ២ ដូច្នេះវាត្រូវឆ្លងកាត់រដូវធ្វើស្រែ អាចថាបីដងរហូតដល់ឆ្នាំ៧៨។ អ៊ីចឹងលោកទៅជួយស្ទូងជារៀងរាល់ឆ្នាំអ៊ីចឹងមែនទេ ឬក៏មួយក៏មានឆ្នាំណាលោកអត់បានទៅជួយ?

[១៥:០៣:០៥]

**លោក កែវ គីន៖**

**ឆ៖** បាទ អត់មានជារៀងរាល់ឆ្នាំទេ មានឆ្នាំណាអត់អ៊ីចឹងដែរ អត់មានបានទៅជួយទេ។ ព្រោះប្រជាជននៅជិតៗហ្នឹងធ្វើស្រែ បើថាកុំឲ្យទំនេរជួយស្ទូងពួកគាត់ មិនមែនស្ទូងរាល់ឆ្នាំទេ អត់ទេ។ ជួនកាលគេដកទៅ បានពូជមក យើងជួយស្ទូងគេម៉្វៃពីរថ្ងៃអ៊ីចឹងទៅ។

**ស៖** បាទ សូមអរគុណ។ លោកនិយាយថា ជួយស្ទូងម៉្វៃពីរថ្ងៃហ្នឹង ម៉្វៃពីរថ្ងៃក្នុងមួយឆ្នាំ មួយរដូវ ឬមួយក៏មានពេលទៅម្តងហើយ ទៅទៀត?

**ឆ៖** បាទ ទាល់តែដកពូជមកបាន បានគេបបួលទៅស្ទូង បើអត់ដកពូជបានយើងអត់ទៅដែរហ្នឹង មានអីស្ទូង។ មិនមែនហៅយើងទៅរាល់ថ្ងៃ ទាល់តែគេដកពូជមកបាននោះ បានគេស្ទូង បើដកពូជអត់ទាន់បាន អត់ទេ។

**ស៖** បាទៗ អ៊ីចឹងលោកអាចបូកសរុបបានទេ ក្នុងមួយរដូវហ្នឹងលោកចំណាយពេលទៅជួយស្ទូងប្រជាពលរដ្ឋហ្នឹងបានប៉ុន្មានថ្ងៃដែរ?

[១៥:០៤:២៥]

**ឆ៖** បាទ ជួនកាលទៅបាន៣ថ្ងៃ ឬ២ថ្ងៃអ៊ីចឹងដែរទេ។ ពីរព្រឹកបីព្រឹក មិនមែនមួយថ្ងៃរាល់

ល្ងាចទេ ពីព្រឹកចាប់ពីម៉ោងបួន ទៅទល់ម៉ោងប្រាំកន្លះហ្នឹង។ បីដងបួនដឹងអីអ៊ីចឹងដែរ។

**ស៖** បាទ អ៊ីចឹងបើសិនជាខ្ញុំសរុបទៅលោកថា អាចមួយឆ្នាំមួយរដូវហ្នឹងទៅបានបីបួនដង ហើយ បីបួនដង បីបួនថ្ងៃ ហើយក្នុងមួយថ្ងៃហ្នឹងអាចពីម៉ោងបួនកន្លះទៅម៉ោងប្រាំ។ អ៊ីចឹងមួយថ្ងៃអាចបានតែកន្លះម៉ោងទេ បើសរុបទៅការងាររបស់លោកបានប្រហែលជា២ម៉ោងទៅ៣ម៉ោងក្នុងមួយរដូវ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** បាទ សូមអរគុណ។ ឥឡូវទាក់ទងទៅនឹងការធ្វើរោងឡានវិញ មុននេះខ្ញុំបានស្ដាប់ឮលោករៀបរាប់អំពីទំហំរោងដែរ ប៉ុន្តែដោយសារខ្ញុំអត់បានសួរពីរឿងទំហំរោងទេ ឥឡូវខ្ញុំចង់ឲ្យលោកបញ្ជាក់សាជាថ្មី។ រោងដែលលោកត្រូវធ្វើហ្នឹង ចំណាយពេលប៉ុន្មានថ្ងៃ ដើម្បីសង់បានរោងមួយ?

**ឆ៖** បាទ ចំណាយពេលខ្ពង់ប្រាំមួយទៅប្រាំពីរថ្ងៃ បានរួចរោងមួយៗ ព្រោះធ្វើគ្នា១០នាក់ទេ គ្នាតិចដែរ អត់មានគ្នាច្រើន។

[១៥:០៦:០៤]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងប្រាំមួយទៅប្រាំពីរថ្ងៃ ដែលមានគ្នា១០នាក់។ លោកអាចបញ្ជាក់ពីទំហំរោងបានទេ បណ្ដោយប៉ុន្មាន ទទឹងប៉ុន្មាន? ហើយអាចចតឡានបានប៉ុន្មានគ្រឿង?

**ឆ៖** បាទរោងមួយ ជួនកាល១០ម៉ែត្រ ជួនកាល១២ម៉ែត្រដែរហ្នឹង។ ចតឡានបាន គេដាក់ពីរជួរ ដាក់ជួនកាល បាន១០គ្រឿងអីហ្នឹង ជួនកាលប្រាំគ្រឿងប្រាំមួយគ្រឿង វាឡានចេញចូលៗ ដាក់អត់ -- អត់ទាំងពេញផង។

**ស៖** បាទ សូមអរគុណ។ ក្នុងការងារជាប្រចាំ ដែលលោកបានឆ្លើយថា លោកមិនដែលបានឈប់ទេ ការធ្វើរោង គឺលោកធ្វើរហូត។ លោកអាចគណនាចំនួនរោងដែលលោកបានធ្វើបានទេ ក្នុងមួយឆ្នាំ បានប៉ុន្មានរោងដែរ ក្នុងក្រុមរបស់លោកហ្នឹង គ្នា១០នាក់ហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់ៗដឹងផង មិនដឹងថាប៉ុន្មាន ព្រោះអត់បានចាំ អត់បានរាប់បានអីទេ តែធ្វើរួច រួចបញ្ជីអីគេនៅលើមេក្រុមមេអីគេណោះ។ មិនដឹងគេទៅធ្វើហ្នឹង វាអត់បានរាប់មើល។

[១៥:០៧:៣៩]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងប្រភេទគ្រឿងម៉ាស៊ីន លោកបានរៀបរាប់ខាងដើម ហើយថា លោកមិនបានស្គាល់ម៉ាកឡានអីច្បាស់លាស់ទេ ប៉ុន្តែលោកអាចស្គាល់ប្រភេទគ្រឿងចក្រ ឬ

គ្រឿងម៉ាស៊ីនដែលលោកធ្វើការរោង ហើយដែលមានគ្រឿងចក្រហ្នឹងមកចតហ្នឹង មានប្រភេទស្អីខ្លះ លោកអាចរៀបរាប់បានទេ?

**ឆ៖** បាទ ប្រភេទអស់ហ្នឹងច្រើនសម្បូរតែអាត្រាក់ ហើយនិងឡាន រ៉ូឡូមិនសូវមានទេ។ មានសម្បូរជាងគេអាត្រាក់ហ្នឹងតែម្តង អាត្រាក់រុញដីហ្នឹង។

**សៈ** បាទ សូមអរគុណ។ នៅពេលដែលលោកធ្វើរោងដាក់គ្រឿងម៉ាស៊ីនទាំងអស់ហ្នឹង លោកមានកត់សម្គាល់ឃើញថា មានគ្រឿងចក្រថ្មីៗ មកបន្ថែមជាបន្តបន្ទាប់ទៀតទេ នៅពេលដែលលោកកំពុងតែធ្វើការ?

[១៥:០៨:៥៤]

**ឆ៖** បាទ មាន។ មានឃើញមកថ្មីៗច្រើន ដូចតែឡាន ដូចតែអាត្រាក់ហ្នឹងមកច្រើន តែខ្ញុំអត់បានរាប់ អត់បានចាំ។

**សៈ** មកញឹកញាប់ប៉ុនណាដែរ លោកអាចចាំបានទេ?

**ឆ៖** បាទ ជួនកាលមក ជួនកាល ពីរខែបីខែវាមកម្តង ប៉ុន្តែមកឡាន៣០, ៤០ឡានអ៊ីចឹង។ ប៉ុន្តែខ្ញុំអត់បានចាំច្បាស់ឡានហ្នឹងមកម្តង -- មកខែណាៗ ខ្ញុំអត់បានចាំទេ។ ខ្ញុំដឹងតែនៅមួយខែពីរខែអីឃើញមក ទាំងអាត្រាក់ ទាំងឡានហ្នឹងដឹកយកមក។ យកមកដាក់នៅហ្គារ៉ាសហ្នឹង។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងបញ្ហាកងការពារ លោកបានបញ្ជាក់ខាងដើមថា មានកងការពាររបស់ចិន ដែលជាអ្នកជំនាញចិនមកធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ ខ្ញុំចង់សួរបន្ថែមថា តើក្រៅពីកងការពារចិនហ្នឹង មានកងការពារផ្សេងទៀត ដែលធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងទេ?

**ឆ៖** បាទ អត់ឃើញមានផង។ ឃើញតែកងការពារក្រុមចិនហ្នឹងតែម្តង អត់ឃើញកងការពារណាក្រៅពីហ្នឹងផង។ ក្រែងគេលាក់ទុកនៅកន្លែងណាៗ ខ្ញុំអត់ដឹង។ ឃើញតែកន្លែង -- ឃើញតែកងការពារចិនហ្នឹង។

[១៥:១១:០១]

**សៈ** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់ឡើងវិញ អំពីការងារធ្វើរោងរបស់លោក ដោយសារថាលោកបានបញ្ជាក់ខាងដើមថា លោកបានបំលាស់ទីចល័តធ្វើរោងជុំវិញបរិវេណព្រលានយន្តហោះកំពង់ឆ្នាំងនោះ។ អ៊ីចឹង នៅពេលដែលលោកផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ លោកមានកត់សម្គាល់

ឃើញកងការពារដែលមានជាប្រដាប់អាវុធហ្នឹងផ្សេងទៀតទេ?

**ឆ៖** បាទ អត់មានឃើញផង ខ្ញុំអត់ឃើញ។ អត់មានឃើញកងប្រដាប់អាវុធណាផ្សេងពីហ្នឹង ឃើញតែបីបួនដប់នាក់ទៅការពារចិនហ្នឹង។ ឃើញតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ព្រឹកមិញ ម៉ោងប្រហែលដប់មួយ ដប់ប្រាំនាទី លោកបានឆ្លើយអំពីការកម្ទេចចោលដោយការខុសសីលធម៌ ហើយលោកបានបញ្ជាក់អំពីការខុសសីលធម៌ហ្នឹង មានការរួមភេទជាដើម។ ខ្ញុំចង់សួរលោកថា លោកមានចាំករណីណាជាក់លាក់មួយ ដែលទាក់ទងទៅនឹងកំហុសសីលធម៌បែបនេះ ហើយត្រូវគេយកទៅកម្ទេចដែរទេ?

**ឆ៖** បាទ ខ្ញុំឃើញតែគេយកអ៊ីចឹង គេថាយើងខុសសីលធម៌សីលអី គេយកទៅអ៊ីចឹង បើខ្ញុំអត់មានដឹងថា ខុសអីៗ ឮតែគេថា ខុសសីលធម៌អ៊ីចឹងតែម្តង។ គេចាប់យកទៅទាំងអស់គ្នាហ្នឹង គេយកទៅខាងណា ខ្ញុំអត់ដឹងដែរ។

[១៥:១៣:០០]

**ស៖** បាទ សូមអរគុណ។ លោកមានចាំឈ្មោះបុគ្គលដែលត្រូវគេចាប់ហ្នឹងទេ ហើយបុគ្គលដែលគេបញ្ជាឲ្យគេចាប់ហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ចាំ បុគ្គលដែលប្រព្រឹត្តអី ខ្ញុំអត់ចាំទេ។ អ្នកបញ្ជាមិនដឹងពីណាបញ្ជាផង ខ្ញុំអត់ដឹង។ អ្នកដែលធ្វើខុសសីលធម៌នោះ ក៏ខ្ញុំអត់ចាំឈ្មោះ អត់ស្គាល់គេផង។

**ស៖** លោកអាចបង្ហាញពីព្រឹត្តិការណ៍ដែលកើតឡើងទេ ថាលោកចាំបានហ្នឹង វាកើតឡើងនៅពេលណាដែរ ក្នុងអំឡុងពេលដែលលោកធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង?

**ឆ៖** បាទ ខ្ញុំអត់បានចំណាំច្បាស់លាស់រឿងហ្នឹងផង។ ដឹងកើតឡើងពេលណា ព្រោះវាភ្លេចបាត់អស់ទៅហើយ។ វាយូរយារណាស់ដែរ។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ខាងដើមអំពីការងារដែលលោកបានធ្វើដែលទាក់ទងទៅនឹងការសង់រោងដាក់ឡាន ការទៅស្ទូង ហើយនិងការរើសគល់ – គល់ឈើ។ ខ្ញុំចង់សួរលោកថា តើលោកមានពេលដើរលេង ឬក៏ចេញទៅក្រៅបរិវេណកន្លែងដែលលោកធ្វើការទាំងបី ដូចខ្ញុំបានរៀបរាប់អម្បាញ់មិញនេះទេ ក្រៅពីកន្លែងទាំងបីហ្នឹង លោកមានដើរទៅកន្លែងផ្សេងទៀតទេ ឬក៏ចេញទៅ ដូចជាទៅរកត្រី ទៅរកអីជាដើម?

[១៥:១៥:០៧]

**ឆ៖** បាទ អត់មានចេញទេបាទ។ ខ្ញុំនៅតែកន្លែងតែម្តង ចេញទាល់សុំច្បាប់គេ។ បើគេឲ្យអនុញ្ញាតឲ្យទៅ ទៅ បើអត់អនុញ្ញាត អត់។ ប៉ុន្តែមិនដែលចេញផងខ្ញុំ។ ចេញពីធ្វើការ សម្រាកងូតទឹក សម្រាកបានបន្តិច ទៅធ្វើទៀត។ អត់ដែលប៊ានដើរចេញទៅណាឆ្ងាយពីកន្លែង ខ្លាចធ្វើការអត់ទាន់ម៉ោងគេ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារ E3/5273 ដែលជាកំណត់ហេតុស្តាប់ចម្លើយរបស់លោក ត្រង់ទំព័រ៥ ជាភាសាខ្មែរ ហើយភាសាបារាំងក៏ទំព័រ៥, ភាសាអង់គ្លេសក៏ទំព័រ៥។ ខ្ញុំសូមដកស្រង់ជូន៖ "ខ្ញុំបានទៅលេងមន្ទីររបស់ ល្វៃ នៅក្នុងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ហើយគេឃើញគេភ្ជង់កាំភ្លើង និងចងមនុស្សនៅទីនោះ ដែលគេធ្វើឡើងនៅម៉ោងប្រាំមួយ ប្រាំពីរយប់។ ក្នុងពេលចាប់ចងមនុស្សតែងមានវត្តមានរបស់ ល្វៃ។" សូមចប់ការដកស្រង់។ ចំណុចនេះ តើលោកនៅប្រកាន់ថាលោកបានទៅឃើញការចាប់ចងហ្នឹងដែរទេ?

**ឆ៖** បាទ ខ្ញុំឃើញ ព្រោះកន្លែងហ្នឹងវានៅជិត វាមិនមែនជិតប៉ុន្មានទេ វានៅជា១០០ម៉ែត្រអី ខ្ញុំឃើញ។ ខ្ញុំឃើញគេចាប់ចងហ្នឹង។ ចាប់ចងភាគច្រើនហៅទៅចូលក្នុងមន្ទីរគាត់ហ្នឹងតែម្តង។ ចាប់ចងរុំមុខៗ លើកដាក់ឡាន ជួនកាលដាក់ឲ្យឡើងឡានខ្លួនឯងហ្នឹង។ ឃើញហ្នឹងនឹងភ្នែក--

[១៥:១៧:០៦]

**ស៖** បាទៗ សូមអរគុណ ខ្ញុំស្តាប់បានហើយកន្លែងហ្នឹង។ ហើយខ្ញុំចង់សួរបញ្ជាក់លោកថា នៅពេលដែលលោកថា កន្លែងរបស់លោកនៅជិតកន្លែងរបស់ ល្វៃ។ ខ្ញុំចាំបានថា កន្លែងរបស់លោកចល័តរហូត។ អ៊ីចឹងកន្លែងដែលលោកបានឃើញហ្នឹងនៅត្រង់ម្តុំណា? នៅចំចំណុចណាដែលថាមានទីតាំងជិតកន្លែងរបស់ ល្វៃ ហ្នឹង?

**ឆ៖** បាទ នៅទួលអំពិល ខ្ញុំដើរមកងូតទឹក ខ្ញុំឃើញ ព្រោះអណ្តូងទឹកនៅកន្លែងក្បែរហ្នឹង។ ខ្ញុំឃើញគេអ៊ីចឹងទៅ ព្រោះកន្លែងវាអត់ឆ្ងាយ អណ្តូងទឹកមកកន្លែង វាជិតដែរ។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់អំមិញថា ទួលអំពិល។ អ៊ីចឹងទួលអំពិលហ្នឹង នៅចំទីតាំងកន្លែងណានៃព្រលានយន្តហោះ នៃការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង?

**ឆ៖** បាទ នៅឆៀង នៅខាងត្បូងឆៀងខាងលិចព្រលានបន្តិច នៅកន្លែងហ្គារ៉ាសសាំង កន្លែងគេចាក់សាំងឡានចាក់សាំងអីហ្នឹង។ នៅជាប់ហ្នឹង ឆ្លងតែថ្នល់មួយដល់គ្នា ដល់កន្លែងទួលអំពិលហ្នឹង។ មន្ទីរគាត់នៅហ្នឹង។

[១៥:១៨:៤៤]

**ស៖** បាទ ខ្ញុំមានចំណុចមិនច្បាស់លាស់មួយក្នុងសក្ខីកម្មរបស់លោក លោកថាទៅលេងកន្លែងល្វៃ។ ហើយអំមិញនេះលោកថា លោកទៅងូតទឹក។ តើមួយណាពិតប្រាកដ?

**ឆ៖** បាទ ខ្ញុំទៅងូតទឹក ដើរទៅចំ ដើរទៅខាងលិចកន្លែងហ្នឹង។ មុនដំបូងនាំគ្នាដើររបៀបលេងពីរនាក់ ដើរទៅងូតហ្នឹង ដើរលេងៗទៅ ឃើញគេអ៊ីចឹងទៅ ខ្ញុំទៅហួសទៅងូតទឹកទៅ។ មិនមែនគោលបំណងចង់ទៅលេងចង់អីទេ អត់ប៊ានចូលទៅកន្លែងគេហ្នឹងនោះ។ ខ្ញុំថាដើរក្បែរកន្លែងងូតទឹកហ្នឹង។

**ស៖** បាទ សូមអរគុណ។ ចម្ងាយប៉ុន្មានដែរពីកន្លែងលោកងូតទឹកទៅកន្លែង ល្វៃ ហ្នឹង?

**ឆ៖** ពីកន្លែងខ្ញុំងូតទឹកទៅកន្លែង តាល្វៃ ហ្នឹងខ្ទង់ ១០០ម៉ែត្រ ប៉ុន្តែថ្ងៃល្ងាចដែរ ថ្ងៃថ្មើរហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរចំណុចមួយទៀត ទាក់ទងនឹងឯកសាររបស់លោកដដែល ត្រង់ទំព័រ៦ ជាភាសាខ្មែរ ហើយភាសាទាំងបីក៏ទំព័រ៦ដូចគ្នា។ ខ្ញុំសូមដកស្រង់៖ "ខ្ញុំធ្លាប់ឃើញក្បួនឡានហ្ស៊ីប-A2 ពីរទៅបីឡានមកទស្សនកិច្ចការដ្ឋាននេះ ប៉ុន្តែមិនដឹងថាជានរណាទេ។" សូមចប់ការដកស្រង់។ ខ្ញុំដឹងហើយថាលោកមិនដឹងថានរណា តើលោកអាចបញ្ជាក់ថា មានជាជនបរទេស ឬក៏ជាគណៈប្រតិភូខ្មែរ? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ប្រហែលជាខ្មែរៗហើយ ព្រោះបើកឡានមកហ្នឹងមួយពេលៗហ្នឹង។ បើបរទេស មិនមែនបរទេសទេ គឺខ្មែរហ្នឹងហើយ អត់មានឃើញអ្នកក្រៅពីហ្នឹង គ្រាន់តែខ្ញុំមិនស្គាល់គេ ឃើញគេបើកឡានចុះឡើងៗ។

[១៥:២១:២៨]

**ស៖** បាទ សូមអរគុណ។ តើលោកស្គាល់ប្រភេទឡានហ្ស៊ីប-A2ទេ ជាឡានស៊ីវិល ឬក៏ជាឡានយោធា?

**ឆ៖** បាទ ជាឡានយោធា អត់មានឡានស៊ីវិលទេ ប៉ុន្តែខ្ញុំឮគេថាឡាននេះ ឡានហ្ស៊ីប-A2អ៊ីចឹងខ្ញុំថាតាមគេ ប៉ុន្តែឡានហ្នឹងតូចៗ។ ប៉ុន្តែអត់មានស៊ីវិលទេមានៗយោធាតែម្ដង មានកាំភ្លើងមានអ៊ីចឹង។

**ស៖** បាទ អ៊ីចឹងខ្ញុំសូមសួរបញ្ជាក់បន្ថែម តាមសក្ខីកម្មរបស់លោកអម្បាញ់មិញនេះ អ្នកដែលជាគណៈប្រតិភូនៅក្នុងឡាននោះជាយោធា។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអញ្ជើញសហការីបន្តបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

[១៥:២២:៥២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ខ្ញុំមានសំណួរខ្លីៗបន្តិចបន្តួច ដើម្បីសួរទាក់ទងទៅនឹងចម្លើយរបស់លោក។ លោកបានឆ្លើយថា លោកឆ្លើយថា លោកធ្វើការនៅរោងឡាន ពីព្រោះថាលោកស្ថិតនៅក្នុងកងពល៥០២នៃកងទ័ពអាកាស។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកធ្លាប់បានឃើញរោងដែលគេ -- នៅកន្លែងការដ្ឋានហ្នឹងមានកន្ទុំរុយក៏មាន ហើយមានឡាន មានអី សម្ភារៈផ្សេងៗ តើលោកបានឃើញអាហ្នឹងដែរទេ?

**លោក កែវ គីន៖**

**ឆ៖** បាទ អត់ឃើញផង អត់មានឃើញកន្ទុំរុយឃើញៗអី ឃើញតែឡាននៅនឹងរោងហ្នឹង។

**ស៖** អ៊ីចឹងក្រៅពីឃ្លាំងហ្នឹង នៅការដ្ឋានហ្នឹង តើលោកមានធ្លាប់ឃើញឧទ្ធម្ភាគចក្រចុះចត ឬក៏ ឡើង ហោះឡើងដែរឬទេ?

**ឆ៖** បាទ អត់មានផង ព្រោះអត់មានឃើញឡើងផង អត់មានឃើញឧទ្ធម្ភាគចក្រដាក់អីផង អត់មានឃើញ។

[១៥:២៤:២៨]

**ស៖** លោកបាននិយាយអំពី ល្វៃ ថាជាមេរបស់លោក លោកបាននិយាយនៅក្នុងចម្លើយរបស់ លោកនៅក្នុងសវនាការហ្នឹង លោកនិយាយពីមេបញ្ជាការ ម៉េត ផងដែរ។ អ៊ីចឹងខ្ញុំសួរថា តើមានមេ ផ្សេងទៀតដែលមានវត្តមាននៅលើការដ្ឋាននេះដែរឬទេ គឺការដ្ឋានព្រលានយន្តហោះហ្នឹង?

**ឆ៖** បាទ អត់មានផង មានតែប៉ុន្មាននាក់ហ្នឹង។ មានតែប៉ុន្មាននាក់ហ្នឹង តាល្វៃ, តាម៉េត ហ្នឹង។ តាម៉េត ហ្នឹងមកមួយពេលៗ បើ តាល្វៃ នៅប្រចាំជាប់នៅហ្នឹងតែម្តង ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ខ្ញុំដូចជាបានធ្វើកំណត់ត្រាថាលោកបានធ្វើជាមួយឈ្មោះ យ៉េង ផងដែរ។ អ៊ីចឹងតើលោក ចាំថាមានឈ្មោះ យ៉េង ហ្នឹងជាមេលោកដែរ នៅការដ្ឋានព្រលានយន្តហោះហ្នឹង?

**ឆ៖** បាទ យ៉េង ហ្នឹងគាត់ហ្នឹងខាងៗសេដ្ឋកិច្ច ខាងបាយទឹក គាត់នៅកំពង់ឆ្នាំងណោះហ្នឹង គាត់នៅទីក្រុងឯណោះ ខ្ញុំនៅព្រលានឯណោះ។ គាត់ទៅម្តងបានឃើញ បើនេះអត់ទៅក៏ខ្ញុំអត់ដែលឃើញដែរ។ ប៉ុន្តែគាត់នៅកំពង់ នៅកំពង់ឆ្នាំងឯណោះ។

[១៥:២៦:១៥]

**ស៖** ខ្ញុំចោទសំណួរនេះទៅកាន់លោកនោះ ព្រោះថាកាលពីម្សិលមិញយើងបានស្តាប់សាក្សី ចាន់ ម៉ន –ឈ្មោះហៅ ចាន់ ម៉ន ហ្នឹងហៅ គុយ– គាត់បានពន្យល់ថា យ៉េង ហ្នឹងជាប្រធានការដ្ឋាន ហើយគាត់ហ្នឹងហើយដែលមានអំណាចពេញដៃនៅកន្លែងហ្នឹង ក្នុងការងារប្រចាំថ្ងៃហ្នឹង។ អ៊ីចឹងព័ត៌មាននេះ បើតាមបទពិសោធន៍របស់លោកហ្នឹង លោកមិនអាច មិនដឹងទេពីរឿងហ្នឹង ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ ខ្ញុំអត់ៗដឹង។ ព្រោះអត់ដឹងថាគាត់កាន់ការិយា -- កន្លែងសំណង់នៅហ្នឹង ខ្ញុំអត់ដឹងដែរ។ ព្រោះចំណាំតែឃើញគាត់នៅកំពង់ឆ្នាំង ឮគេថានៅកំពង់ឆ្នាំងណោះ ហើយមកព្រលាន គាត់មកមួយពេលៗអ៊ីចឹង។ ប៉ុនគាត់ហ្នឹងខាង -- តាមខ្ញុំដឹងខាងដឹកស្បៀងដឹកអី។ ខ្ញុំឃើញគេចែកស្បៀងចែកស្អី។ យ៉េង ហ្នឹងអ្នកចែក។

**ស៖** លោកសាក្សី ចាន់ ម៉ន ហ្នឹងគាត់និយាយថា យ៉េង ហ្នឹងជាអ្នកចែកការងារឲ្យយោធាធ្វើ។ អ៊ីចឹងតើលោកដឹងដែរទេ ថាគាត់ហ្នឹងធ្វើការសម្រេចទាក់ទងនឹងក្រុមដឹកជញ្ជូន ហើយនិងក្រុមយោធាដែលធ្វើការនៅទីហ្នឹង ក៏ដូចជាអង្គភាពលោកផងដែរ។ តើលោកធ្លាប់ដឹងពីរឿងហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំៗ ចំពោះខ្ញុំផ្ទាល់ ខ្ញុំអត់ដឹងទេ។ ព្រោះមិនសូវដែលឃើញគេ បានខ្ញុំថាអត់ដឹង។ បើខ្ញុំដឹង ខ្ញុំប្រាប់ថាដឹងហើយ ប៉ុន្តែខ្ញុំអត់ដឹង។ មិនដឹងគាត់ខាងអីៗ ព្រោះ--។

[១៥:២៨:២៩]

**ស៖** នៅពេលដែលលោកឆ្លើយតបទៅនឹងសំណួរកាលពីព្រឹកមិញ គឺសំណួររបស់សហព្រះរាជអាជ្ញានោះ ហើយនិងៗមេធាវីនាំមុខនោះ លោកឆ្លើយថា ចាន់ ម៉ន ហ្នឹងជាអ្នកបើកបរ ហើយគាត់មិនមានមុខងារអ្វីផ្សេងទៀត។ អ៊ីចឹងខ្ញុំសួរថា តើគាត់មានទំនាក់ទំនងពិសេស ណាមួយជាមួយនឹងមេបញ្ជាការ ម៉េត ដែរឬទេ ឬក៏មេណានៅថ្នាក់លើបន្តបន្ទាប់ទៀតទេ?

**ឆ៖** បាទ ចំពោះ ចាន់ ម៉ន ហ្នឹងខ្ញុំធ្លាប់ឃើញតែគាត់ដើរជាមួយ តាឡៃ, ជាមួយ ម៉េត ជាមួយអត់សូវដែលឃើញដើរទេ ប៉ុន្តែគាត់ដើរបានរយៈពេលខ្លីដែរ។ ផុតពីហ្នឹងទៅគេបញ្ជូនទៅខាងណាទៀត

វាបែកគ្នាអស់ទៅ។ ខ្ញុំមិនសូវដឹង ដល់បែកចេញពីគ្នាហើយ។ ប៉ុនពីដើមនៅជាមួយគ្នា ដល់ខ្ញុំចេញមុនមកនៅ ម៉ន ហ្នឹងជាមួយ តាល្វៃ ហ្នឹង។ តែផុតពីហ្នឹងទៀត មិនដឹងគេចេញទៅឯណាឯណី គេទំនាក់ទំនងការងារស្អី ក៏ខ្ញុំមិនដឹងដែរ។

**ស៖** ខ្ញុំសូមការបំភ្លឺដូចតទៅនេះ។ អ៊ីចឹងនោះព្រោះថា កាលពីព្រឹកមិញនោះលោកបានឆ្លើយថា នៅពេលណាមួយ ចាន់ ម៉ន ហ្នឹង មេៗនោះលែងទុកចិត្ត ចាន់ ម៉ន ហ្នឹង។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកមានមូលដ្ឋានអ្វីក្នុងការនិយាយថា មេៗថ្នាក់លើលែងទុកចិត្តគាត់នោះ?

[១៥:៣០:២១]

**ឆ៖** បាទ ចំណុចនេះខ្ញុំដឹង ពីគាត់និយាយ ចាន់ ម៉ន គាត់និយាយ ព្រោះគាត់លែងនៅជាមួយ បានន័យថាគេដកសេចក្ដីទុកចិត្ត ព្រោះបើនៅកន្លែងនោះទាល់តែអ្នកស្អាតបាត ប្រវត្តិរូបល្អល្អាច់ដែលបាននៅកន្លែងហ្នឹងបាន តែបើប្រវត្តិរូបជាប់និន្នាការហ្នឹងអី អត់ឲ្យនៅទេកន្លែង តាល្វៃ ហ្នឹងនោះ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** តើគាត់និយាយប្រាប់លោកនៅពេលណាដែរ?

**ឆ៖** បាទ និយាយប្រាប់នៅពេលយួន -- ដែលវៀតណាមជិតចូលហើយ ចូលជិតដល់ហើយ បាននិយាយប្រាប់។ វៀតណាមចូលជិតដល់មានធ្វើអីទៀត អត់។ នាំគ្នាប្រមូល – គិតតែប្រមូលអីវ៉ាន់រត់។

**ស៖** តើលោកចង់និយាយថា នៅពេលដែលលោករត់ ពេលដែលពេលលោករត់យួនហ្នឹងហើយ ឬ ដែលគេលែងទុកចិត្តលោក ចាន់ ម៉ន ហ្នឹង?

**ឆ៖** បាទ លែងទុកចិត្ត ចាន់ ម៉ន តាំងពីមុនរត់យួន។ តាំងពីមុនប្រហែលបីបួនខែឯណោះ ព្រោះខ្ញុំវាអត់ឃើញដើរជាមួយ បានតែនឹកឃើញថា គេដកសេចក្ដីទុកចិត្តហើយ លែងនៅជាមួយហើយ។ បើ ចាន់ ម៉ន ហ្នឹងមានជាប់និន្នាការអីដែលមិនដឹង ខ្ញុំអត់ដឹងដែរ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

[១៥:៣២:៣២]

**ស៖** អ្វីដែលខ្ញុំមិនយល់នោះគឺថា លោកនិយាយជាមួយគាត់ពីរឿងនោះនៅកន្លែងណា? ហើយគាត់ឈប់ធ្វើការជាមួយ ល្វៃ ហើយ ក៏ប៉ុន្តែគាត់នៅតែធ្វើការនៅព្រលានយន្តហោះហ្នឹងដដែល ឬក៏យ៉ាងណា?

**ឆ៖** បាទ គាត់នៅធ្វើការនៅព្រលានយន្តហោះហ្នឹងដដែល។ ប៉ុន្តែមិនដឹងគេនៅធ្វើការខាងអី

បើខ្ញុំអត់ដែលឃើញ ទើបតែរត់ហ្នឹងបានឃើញ។ ខាងបើកឡានក៏មិនដឹង ឃើញចំណាំតែបើកឡាន។ អត់ដែលឃើញធ្វើអី ឃើញតែបើកឡានហ្នឹងហើយ។ ដល់ពេលរត់បានជួបគ្នា អាជិតរត់បានជួបគ្នា។

**ស៖** ខ្ញុំចោទសំណួរទាំងអស់នេះហ្នឹង ពីព្រោះថាម្សិលមិញហ្នឹងលោក ចាន់ ម៉ន គាត់ប្រាប់ថា គាត់ទំនងជាត្រូវបានគេចាប់ខ្លួននៅលើការដ្ឋានផ្ទាល់តែម្តង ហើយគាត់ត្រូវបានគេបញ្ជូនទៅមន្ទីរស-២១ ហើយ ល្វៃ និង ម៉េត ហ្នឹងបានមកយកគាត់ដោយជិះយន្តហោះ។ អ៊ីចឹងបើមើលក្រឡេកមើលទៅ ខ្ញុំឃើញថា ដូចជាមិនមានការដកសេចក្តីទុកចិត្តអីពី ចាន់ ម៉ន ហ្នឹងទេ។ អ៊ីចឹងខ្ញុំចង់សួរថាតើលោកមានបានពិភាក្សាជាមួយគាត់ ជាមួយ ចាន់ ម៉ន ហ្នឹងពេលមុនរត់យួនហ្នឹងដែរឬទេ? និយាយពីកាលៈទេសៈនៃការចាប់ខ្លួនគាត់អីជាដើមនេះ?

[១៥:៣៤:២៩]

**ឆ៖** បាទ អត់ៗមានបានពិភាក្សាអីផង។ អត់បានជួបគ្នាផងពីមុនហ្នឹងមក។ ខ្ញុំអត់ដឹងថាគេចាប់ខ្លួនចាប់អី ខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំមិនយល់ថា គាត់មិនបានជួបគាត់មុនពេលរត់យួន ពីព្រោះថាលោកនិយាយថា មុននោះៗពេលលោកដឹងថា គាត់ជាអ្នកបើកបរ។ អ៊ីចឹងលោកដឹងថា គាត់ជាអ្នកបើកបរហ្នឹង ដឹងនៅពេលណា នៅពេលដែលគេចាប់ខ្លួនគាត់នុ៎ង -- នៅពេលដែលឃើញគាត់បើកបរឡានហ្នឹងតែម្តង ឬក៏យ៉ាងម៉េច ឬក៏ដឹងតាំងពីមុនមកថា គាត់ជាអ្នកបើកបរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

ខ្ញុំគិតថា សំណួរនេះធ្វើឲ្យស្រពេចស្រពិល ពីព្រោះថាមានពេលខុសគ្នាជាច្រើន។ គាត់និយាយថា គាត់មិនដែលធ្លាប់ជួបគាត់ពីមុនមកនោះទេ គឺថាគាត់ធ្វើការជាមួយគ្នាហ្នឹងនៅលើការដ្ឋាន ហើយជាមួយនឹង ល្វៃ ហ្នឹង។ អ៊ីចឹងត្រូវបែកចែកពេលដំណាក់កាលពេលវេលាឲ្យច្បាស់លាស់ បើមិនអ៊ីចឹងទេទៅមុខមិនរួចទេ និងមិនអាចច្បាស់លាស់បានទេ។

[១៥:៣៦:០៨]

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំមើលទៅឃើញថា មិនមែនជាការជំទាស់ពីសំណាក់ព្រះរាជអាជ្ញា ដោយសារតែមិនច្បាស់លាស់ហ្នឹងហើយ បានខ្ញុំសូមការបំភ្លឺពីសាក្សីនេះ។ សំណួរខ្ញុំដូចជាច្បាស់ហើយ ខ្ញុំសួរគាត់ហ្នឹងដើម្បីសូមការបំភ្លឺទេ។ ខ្ញុំមិនមែនធ្វើឲ្យមានការស្រពេចស្រពិលទេ ខ្ញុំសូមឲ្យគាត់ជួយបំភ្លឺ។ សំណួរខ្ញុំហ្នឹងវាសមហេតុសមផល។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**សៈ** ខ្ញុំសួរសុំឲ្យសាក្សីបំភ្លឺថា តើនៅពេលដែលគាត់បានជួបលោក ចាន់ ម៉ន ជាលើកទី១ នោះជួបនៅពេលណា?

**លោក កែវ គីន៖**

**ឆ៖** ខ្ញុំអត់ឮ។

**សៈ** អម្បាញ់មិញនេះ លោកមានបញ្ហាជាមួយប្រដាប់ស្តាប់។ ខ្ញុំមិនបានយល់ពីចម្លើយមុនអ៊ីចឹងខ្ញុំអម្បាញ់មិញហ្នឹង ខ្ញុំសួរលោកថា តើលោកជួបលោក ចាន់ ម៉ន នោះជាលើកទី១ នៅពេលណាដែរ?

[១៥:៣៧:៣៧]

**ឆ៖** គាត់សួរសំណួរអី ខ្ញុំអត់ឮរលីង។ ឮតែឆែៗរហូត អត់ឮផង។

**សៈ** ឥឡូវលោកឮខ្ញុំនិយាយហើយឬនៅ? ខ្ញុំឃើញថា លោកងក់ក្បាល បានន័យថា ឮហើយ។ ខ្ញុំមិនយល់ចម្លើយលោកអង្កាល់អម្បាញ់មិញនេះ។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកជួប ចាន់ ម៉ន ហ្នឹងជាលើកទី១ នៅពេលណា? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ខ្ញុំជួប ចាន់ ម៉ន លើកទី១ នៅគាត់បើកឡាន។ គាត់បើកឡានមកពីណាជួបខ្ញុំឯកន្លែងដាក់រោងឡានហ្នឹង ហើយក៏គាត់បាននិយាយប្រាប់។ ខ្ញុំបានដឹងតែប៉ុណ្ណឹង បានជួបគាត់ម្តងហ្នឹង។

**សៈ** ពេលដែលលោកនិយាយថា លោកជួបគាត់តែម្តងហ្នឹង គឺថាពេលដែលលោករត់យួនហ្នឹងឬក៏មុនហ្នឹង?

**ឆ៖** បាទ មុនហ្នឹងប្រហែលជាពីរថ្ងៃបីថ្ងៃហ្នឹង។ គាត់រៀបចំរត់ដូចគ្នា។ គាត់ក៏រៀបចំរត់ ខ្ញុំក៏រៀបចំរត់ បានជួបគ្នា។ ផុតពីនោះអត់ -- ពីមុនៗមកអត់ដែលបានជួបទេ តាំងពីលែងនៅជាមួយគ្នាមកលែងបានជួបគ្នា។

[១៥:៣៩:៥១]

**ស៖** ខ្ញុំដូចជាឮលោកនិយាយថា នៅពេលដែលលោកចូលធ្វើបដិវត្តន៍លោកជានីរសារ លោកមិនមែនជានីរសាររបស់ ល្វៃ ទេ ឬក៏យ៉ាងណា?

**ឆ៖** បាទ ខ្ញុំនីរសាររបស់គាត់ នីរសាររបស់គាត់តាំងពីឆ្នាំ៧៤ តាំងពីចូលមកបានប៉ុន្មានៗខែ បានខ្ញុំធ្វើនីរសារ ដល់៧៥ខ្ញុំឈប់។ មកធ្វើព្រលានហ្នឹង ខ្ញុំឈប់តែម្តង ឈប់មុនមកធ្វើព្រលានហ្នឹង។ ពីមុននៅនីរសារឲ្យគាត់ ជាមួយ ចាន់ម៉ន ចាន់អីហ្នឹង ជាមួយគ្នាហ្នឹង។

**ស៖** ខ្ញុំលើករឿងនេះឡើងនោះ ព្រោះថាលោកដូចជាបាននិយាយថា មានប្រហែលជាចន្លោះពីបួនទៅដប់ -- នីរសារ១០នាក់ធ្វើនៅក្នុងអង្គភាពរបស់លោក ហើយលោក ចាន់ ម៉ន នេះបានពន្យល់ថាគាត់ហ្នឹងក៏ជានីរសាររបស់ ល្វៃ ដែរមុនឆ្នាំ១៩៧៥។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកមិនបានស្គាល់គាត់មុនឆ្នាំ៩៧៥ទេឬ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់គាត់ទេមុនហ្នឹង ទើបមកធ្វើនីរសារនេះ បានៗស្គាល់គ្នា។ មុនៗអត់ដែលមានទំនាក់ទំនង អត់មានបានសួរគ្នា។ គេនៅស្រុកជិតហ្នឹងដែរ ប៉ុន្តែអត់ស្គាល់គ្នា។

[១៥:៤១:៤៨]

**ស៖** ចុះបើខ្ញុំយល់មិនច្រឡំទេហ្នឹងគឺថាពេល -- គាត់ជួបលោកជាលើកទី១ហ្នឹង គាត់និយាយប្រាប់លោកថា ល្វៃ ហ្នឹងលែងទុកចិត្តគាត់ហើយ អ៊ីចឹងមែនទេ? ជួបលោកលើកទី១ហ្នឹង និយាយរឿងហ្នឹងប្រាប់លោកតែម្តង?

**ឆ៖** បាទៗ និយាយប្រាប់ខ្ញុំតែម្តង។ គាត់ថា គាត់លែងនៅជាមួយ គាត់គេដកគាត់ចេញហើយលែងនៅជាមួយហើយ។ ដកសេចក្តីទុកចិត្តអីក៏ឮនិយាយ ប៉ុន្តែគ្រាន់គាត់ថាលែងនៅជាមួយ។ ទៅនៅនុ៎ង ដកសេចក្តីទុកចិត្ត បានអត់ឲ្យនៅជាមួយហ្នឹង។ បានខ្ញុំដឹង។

**ស៖** ជាសំណួរចុងក្រោយរបស់ខ្ញុំហើយ ទាក់ទងប្រធាននេះហ្នឹង។ អ៊ីចឹងគាត់មិនបាននិយាយអំពីការចាប់ខ្លួនគាត់ ឬក៏មានគេជិះឧទ្ធម្ភាគចក្រហ្នឹងមកជួយគាត់។ ពេលហ្នឹងអត់មាននិយាយរឿងទាំងអស់ហ្នឹងប្រាប់លោកទេ អ៊ីចឹងណ៎ា? ពីរឿងចាប់ខ្លួនគាត់ ហើយមានអ្នកមកជួយដែលជិះឧទ្ធម្ភាគចក្រអីជាដើមហ្នឹង មកជួយគាត់ អត់មាននិយាយរឿងហ្នឹងទេ ឬក៏យ៉ាងណា?

**ឆ៖** បាទ អត់មាននិយាយរឿងហ្នឹងផង។ ខ្ញុំអត់ដឹងរឿងចាប់ខ្លួន អត់ដឹងណាជិះឧទ្ធម្ភាគចក្រមកជួយអី ខ្ញុំអត់ដឹងទាំងអស់។ ខ្ញុំអត់ៗដឹងផង។ ដឹងគេចាប់ខ្លួនពីថ្ងៃណា ពីថ្មើរណា ខ្ញុំអត់ដឹង ហើយ

ពីណាមកជួយ ក៏ខ្ញុំអត់ដឹងដែរ។

[១៥:៤៣:៣៧]

**ស៖** លោកបាននិយាយអំពីការងារផ្សេងៗដែលលោកបំពេញមុន ហើយនិងក្នុងពេលដែលលោកធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ អ៊ីចឹងក្រៅពីការងារជានីរសារ ហើយនិងជាយោធាដែលត្រូវចាត់តាំងឲ្យធ្វើការនៅអង្គភាពដឹកជញ្ជូននុំង តើលោកមានតួនាទីអីផ្សេងទៀត ដែលគេកំណត់ឲ្យធ្វើដែរឬទេ ការងារផ្សេងទៀត?

**ឆ៖** បាទ អត់មានទេ មានធ្វើតែការងារដូចខ្ញុំជម្រាបពីខាងដើមអ៊ីចឹង មានតែប៉ុណ្ណឹង។ ទៅណាក៏អត់ មកណាក៏អត់ នៅតែកន្លែងធ្វើការហ្នឹងតែម្តង។

**ស៖** អ៊ីចឹងជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថាលោកមិនមានបុណ្យសក្តិអ្វីជាក់លាក់នោះទេ?

**ឆ៖** បាទ ខ្ញុំអត់មានមែន។ អត់មានបុណ្យស័ក្តិ អត់មានស្អីនឹងគេ ខលស្លូវ ចាន់ ម៉ន មើល៍ក៏អាចដឹងដែរ។ អត់មានអីទាំងអស់ ព្រោះយុទ្ធជនសុទ្ធសាធហ្នឹងតែម្តង។

**ស៖** លោកបាននិយាយថា លោកមិនដែលចូលរួមកិច្ចប្រជុំធំៗ នៅព្រលានយន្តហោះកំពង់ឆ្នាំងទេ ក៏ប៉ុន្តែលោកចូលប្រជុំនៅក្នុងអង្គភាពដឹកជញ្ជូនរបស់លោក ទាក់ទងទៅនឹងការបំពេញការងាររបស់លោក។ ក្នុងលក្ខខណ្ឌនេះ តើយើងយល់ស្របនឹងគ្នាដែរឬទេ ក្នុងការនិយាយថា លោកមិនមានមធ្យោបាយអ្វីដើម្បីឲ្យដឹងថា ថ្នាក់លើចេញសេចក្តីសម្រេចយ៉ាងណា? ហើយរបៀបចេញ -- ហើយក៏មិនដឹងពីរបៀបចេញសេចក្តីសម្រេចណាមួយនោះដែរ តើការនិយាយដូច្នេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

[១៥:៤៥:៤៩]

**ស៖** អម្បាញ់មិញនេះ នៅពេលដែលមេធាវី នួន ជា សួរលោកទាក់ទងទៅនឹងចំនួនកងពល និងអង្គភាពផ្សេងៗទៀត កងវរសេនាតូច វរសេនាធំអីជាដើមនោះ លោកមិនអាចឆ្លើយបានទេ ពីព្រោះលោកមិនបានរៀនសូត្រឲ្យដឹងអំពីបំណែងចែកយោធានោះទេ។ តើការនិយាយដូច្នេះត្រឹមត្រូវដែរឬទេ លោកមិនដឹងអំពីបំណែងចែកយោធាទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។ ខ្ញុំអត់ដឹងមែន។

**ស៖** តើការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា លោកមិនបានទទួលការបណ្តុះបណ្តាលផ្នែក

យោធា ហើយអ៊ីចឹងលោកមិនដឹងពីព័ត៌មានដែលថ្នាក់លើដឹង ឬក៏មានទាក់ទងទៅនឹងការអំពើចារកម្មទេ? តើខ្ញុំនិយាយយ៉ាងដូច្នេះ ត្រឹមត្រូវដែរឬទេ?

**ធ៖** បាទ ពិតជាត្រឹមត្រូវហើយ។ ខ្ញុំអត់មានបានធ្វើអីផ្សេងក្រៅពីហ្នឹងទេ។ អត់មានបានធ្វើអីទាំងអស់។ គាត់និយាយត្រូវហើយ។

**ស៖** ឥឡូវខ្ញុំសូមបញ្ចប់ការចោទសំណួរ ដោយនិយាយអំពីចំណុចមួយចំនួន គឺទាក់ទងទៅនឹងលក្ខខណ្ឌការងារ ដូចដែលលោកបានលើកឡើងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារ E3/5273។ ERN ជាភាសាបារាំងគឺ 00355858, ERN ជាភាសាខ្មែរគឺ 00282943, ERNជាភាសាអង់គ្លេសគឺ 00290502។ សំណួរដែលគេចោទសួរទៅលោក សួរថា៖ "តើរបបអាហារកម្មករនៅព្រលានយន្តហោះហ្នឹងយ៉ាងម៉េចដែរ?" ចម្លើយរបស់លោក លោកឆ្លើយថា៖ "ចំពោះក្រុមខ្ញុំការហូបចុកគឺសមរម្យ ប៉ុន្តែអ្នកផ្សេងទៀត ខ្ញុំមិនដឹងទេ។" តើលោករក្សាចម្លើយលោកដែរឬទេ គឺថាចំពោះក្រុមផ្សេងៗទៀតលោកមិនដឹងទេ ក៏ប៉ុន្តែសម្រាប់ក្រុមលោកនោះ បើយោងតាមស្ថានភាពដែលថាប្រទេសកម្ពុជាទើបចេញពីសង្គ្រាមហ្នឹង គឺរបបអាហារហ្នឹងសមរម្យហើយ? លោកចាំចម្លើយហ្នឹងទេ?

[១៥:៤៨:២៣]

**ធ៖** បាទ ចាំៗ។

**ស៖** ខ្ញុំដឹងថា សំណួរខ្ញុំអំមិញហ្នឹងច្បាស់ ឬមិនច្បាស់ទេ។ តើលោកចាំដែរឬទេ ថាលោកបាននិយាយថា របបអាហារហ្នឹងសមរម្យ?

**ធ៖** បាទ ខ្ញុំនៅចាំ។

**ស៖** លោកបាននិយាយអំពីរោងឡាន ដែលសង់នៅចម្ងាយប៉ុន្មានម៉ែត្រពីព្រលានយន្តហោះហ្នឹង តើលោកធ្លាប់ធ្វើរោងប្រេងឥន្ធនៈដែរឬទេ? ឬក៏ឃ្លាំងដែលគេ -- ឃ្លាំងប្រេងម៉ាស៊ូតអីជាដើមនោះ លោកធ្លាប់ធ្វើរោងដាក់ រោងស្តុកម៉ាស៊ូត ឬក៏សាំងអីទេ?

**ធ៖** ខ្ញុំធ្លាប់តែធ្វើរោងឡាន។ រោងម៉ាស៊ូតអី គេធ្វើរួចមុនខ្ញុំហើយ។ ខ្ញុំទៅតាមក្រោយគេ។

**ស៖** តើលោកស្គាល់យោធាម្នាក់ឈ្មោះ ស្រ៊ុន ជ័យ? ឈ្មោះ ស្រ៊ុន ជ័យ លោកស្គាល់គាត់ទេ?

**ធ៖** ខ្ញុំស្គាល់។

**ស៖** នៅក្នុងចម្លើយមួយគឺឯកសារ E3/5526 ស្រ៊ុន ជ័យ នេះគាត់និយាយពីការងារពេលយប់។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកហ្នឹង ក៏លោកនិយាយផងដែរថា លោកធ្វើការពី

ម៉ោងដប់ប្រាំពីរដល់ម៉ោងម្ភៃពីរ។ អ៊ីចឹងខ្ញុំសុំឲ្យ នឹងឲ្យលោកធ្វើការអត្ថាធិប្បាយនៅពេលបន្តិចទៀតនេះ គឺចម្លើយ និងសំណួរលេខ១០។ សំណួរដែលសួរទៅគាត់ដូចតទៅនេះ៖ “តើលោកអាចរៀបរាប់អំពីលក្ខខណ្ឌការងារ របបហូបចុក ព្យាបាលជំងឺ និងការឈប់សម្រាករបស់កងទ័ពដែលធ្វើការនៅទីនោះបានដែរឬទេ?” ចម្លើយគាត់ឆ្លើយដូចតទៅនេះ៖ “ការងារនៅទីនោះ ចាប់ផ្តើមធ្វើត្រឹមម៉ោងប្រាំមួយព្រឹករហូតដល់ម៉ោងដប់មួយថ្ងៃត្រង់ ហើយឈប់សម្រាកដើម្បីហូបបាយ។ ហើយចាប់ផ្តើមបន្តទៀតពីម៉ោងមួយរសៀល រហូតដល់ម៉ោងប្រាំល្ងាច ទើបសម្រាកហូបបាយល្ងាច។ បន្ទាប់មកមានការប្រជុំជីវភាពជារៀងរាល់ថ្ងៃ។ ហើយក្រោយពីការប្រជុំ កងទ័ពត្រូវសម្រាករហូតដល់ភ្លឺ ប៉ុន្តែមានវេនសម្រាប់ធ្វើការយប់ដែរ។ អ្នកដែលធ្វើការពេលថ្ងៃ មិនធ្វើការពេលយប់ទេ។” សុំបញ្ចប់ការដកស្រង់។ តើនៅក្នុងអង្គភាពរបស់លោក របបការងារនេះ ដូចថាមានក្រុមធ្វើការពេលយប់ ហើយនិងការងារពេលថ្ងៃនេះអត់មានទេ ឬក៏យ៉ាងណា? ព្រោះតាមសាក្សី ស្រ៊ុន ជ័យ នេះគាត់និយាយថាមានក្រុមធ្វើការពេលយប់និងពេលថ្ងៃ។ អ៊ីចឹងតើនៅអង្គភាពលោកមានទេ ក្រុមធ្វើការពេលយប់ ពេលថ្ងៃនេះ?

[១៥:៥២:១៨]

**ឆ៖** បាទ ខ្ញុំមាន។ ស្រ៊ុន ជ័យ គាត់នៅចាក់សាំងហ្នឹង ហើយខ្ញុំជាងផ្ទះឯណោះ ខាងជាងរោងនៅហ្នឹង។ គាត់ខាងពិការ គាត់ចាក់សាំងឯណោះផ្សេង។ គាត់ធ្វើការតែយប់មែនហ្នឹង ព្រោះឡានព្រោះស្ទីចេញចូលយប់ៗ។ គេធ្វើខ្លះថ្ងៃ គេផ្លាស់គ្នាគេហ្នឹង ខ្ញុំអត់សូវដឹងដែរព្រោះគ្នាគេច្រើនដែរ។ បើចំពោះក្រុមខ្ញុំតែម្តង ធ្វើហ្នឹងហើយ ធ្វើថ្ងៃផង។

**ស៖** ខ្ញុំចោទសំណួរឡើងវិញឲ្យច្បាស់លាស់បន្តិច។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ហ្នឹង គាត់និយាយថាមានក្រុមដែលធ្វើការពេលយប់ ហើយនិងក្រុមផ្សេងទៀតធ្វើការពេលថ្ងៃមិនមែនជាមនុស្សតែមួយទេ។ អ៊ីចឹងខ្ញុំសួរថាតើនៅក្នុងក្រុមលោកនោះ អង្គភាពលោកហ្នឹងមានក្រុមការងារយប់ ហើយនិងក្រុមការងារថ្ងៃដែរឬទេ?

**ឆ៖** បាទ អត់មានក្រុមការងារ – មានតែក្រុមការងារថ្ងៃ យប់ក៏ក្រុមដដែលៗហ្នឹងធ្វើទាំងអស់តែគ្នាហ្នឹង។ ធ្វើតែក្រុមខ្ញុំហ្នឹងធ្វើ ដូចខ្ញុំជម្រាបហ្នឹង រើសឫសឈើឫសគល់អីហ្នឹង យប់។ ថ្ងៃឡើងធ្វើការធ្វើរោងឡានដដែលហ្នឹង។ បើក្រុម ស្រ៊ុន ជ័យ ហ្នឹងគាត់មាន គាត់ខាងពិការ គេមិនសូវប្រើគាត់ឯណា។ គាត់ទៅចាក់សាំង នៅចាក់សាំងនេះ ខាងស្តាំដៃខ្ញុំ។

**ស៖** តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា លោកមិនដឹងអំពីអង្គភាពផ្សេងទៀតទេ

ក្រៅពីអង្គភាពដឹកជញ្ជូនរបស់លោកនេះ លោកមិនដឹងរឿងរ៉ាវអ្វីនៅក្នុងអង្គភាពផ្សេងទេ។ តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយដូច្នេះ?

**ឆ៖** បាទ។

**ស៖** លោកនិយាយឆ្លើយថា "បាទ" ហ្នឹងបានន័យថាលោកមិនដឹងពីរឿង -- មិនដឹងពីអ្វីកើតឡើងនៅក្នុងអង្គភាពផ្សេងទៀតទេ។ លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំចង់និយាយអ៊ីចឹង ព្រោះខ្ញុំដឹងតែអង្គភាពខ្ញុំ អង្គភាពគេដទៃ ខ្ញុំអត់ដឹង។

**ស៖** តើលោកយល់ស្របនឹងខ្ញុំទេថា នៅក្នុងក្រុមរបស់លោកហ្នឹងមានមនុស្សជាង១០នាក់?

**ឆ៖** បាទ ក្រុមខ្ញុំមានមនុស្ស១០នាក់ហ្នឹង។

**ស៖** លោកបាននិយាយដោយសង្ខេបអំពីក្រុមកងការពារ ការពារគណៈប្រតិភូចិន។ តើលោកដឹងដែរឬទេថា តើនៅក្នុងចំណោមអ្នកដែលគេចាត់ឲ្យទៅក្នុងកងការពារចិនហ្នឹង មានឈ្មោះ គត់ – សម្រាប់អ្នកបកប្រែ គឺសរសេរជាភាសាបារាំងគេសរសេរ – អ៊ីចឹងឈ្មោះ គត់។ ឈ្មោះ គត់ លោកស្គាល់ឈ្មោះ គត់ ទេ គាត់ជាកងការពារ ការពារជនជាតិចិននៅសម័យនោះ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ។ អត់ស្គាល់ឈ្មោះ គត់ ឈ្មោះអីហ្នឹងផង។ ខ្ញុំអត់ស្គាល់។

**កញ្ញា អង់តា ហ្គីសសេ៖**

ដើម្បីជៀសវាងបញ្ហា ខ្ញុំសូមឲ្យលោកមេធាវី គង់ សំអុន អានឈ្មោះហ្នឹងឲ្យលោកយល់ច្បាស់។

[១៥:៥៦:៤៩]

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ឈ្មោះហ្នឹងគឺឈ្មោះ អ៊ុត១ បាទ។

**លោក កែវ គីន៖**

**ឆ៖** ឈ្មោះ អ៊ុត! អ៊ុត ហ្នឹងខ្ញុំស្គាល់។ បើ គត់ អត់ទេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** តើលោកជួបគាត់ច្រើនដងដែរឬទេ?

**ឆ៖** បាទ អត់ៗមានបានជួបទេ ប៉ុន្តែខ្ញុំឮគេថាឈ្មោះ អ៊ុត ៗហ្នឹង អត់ដែលបានជួបផង។

**ស៖** ហើយគាត់ហ្នឹងធ្វើការនៅក្នុងកងការពារ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ គាត់ធ្វើការនៅកងការពារហ្នឹងហើយ។ ខ្ញុំក៏មិនដែលបានជួបដែរ។

**សៈ** តើលោកមានចាំទេថា ថាតើនៅពេលដែលលោកធ្វើការនៅលើការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង មានពេលណាមួយនោះ យោធាត្រូវបានគេៗបញ្ជូនទៅឱ្យធ្វើ -- ទៅច្បាំងក្នុងក្របខ័ណ្ឌនៃជម្លោះប្រដាប់អាវុធរវាងវៀតណាម និងខ្មែរ? លោកដឹងទេ ថាមានគេបញ្ជូនយោធាទៅ?

**ផៈ** បាទ ខ្ញុំៗអត់ដឹងផង។ គេបញ្ជូនខាងណាៗ ខ្ញុំដឹង បើកន្លែងខ្ញុំអត់ដឹងទេ អត់ដឹងគេបញ្ជូនផង។ ទាល់តែដល់ពេលរត់ហ្នឹងបានគេថាវៀតណាមចូល បានដឹង។ ត្រង់បញ្ជូនទៅអី ខ្ញុំអត់ដឹងទេ។

**សៈ** តើលោកមានស្គាល់ឈ្មោះយោធាម្នាក់ឈ្មោះ គង់ គីម? លោកមានស្គាល់ឈ្មោះ គង់ គីម ហ្នឹងទេ?

**ផៈ** បាទ ខ្ញុំអត់ស្គាល់ផង។ អត់ស្គាល់ឈ្មោះ គង់ គីម ហ្នឹងទេ។ ដឹងគាត់នៅឯណាអីឯណី ខ្ញុំអត់ស្គាល់។

[១៥:៥៩:២៧]

**សៈ** ខ្ញុំសូមដកស្រង់ចម្លើយគាត់ ដែលគាត់បានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត -- អ្នកស៊ើបអង្កេត ហើយបន្ទាប់មកខ្ញុំចោទសំណួរមួយចំនួន គឺឯកសារ E3/3959។ ERN ជាភាសាបារាំងគឺ 00486100, ERN ជាភាសាខ្មែរគឺ 00270168 ទៅដល់ 9, ERN ជាភាសាអង់គ្លេស 00278686។ ខ្ញុំសូមដកស្រង់ ចម្លើយសំណួរពីរ ERN ដូចគ្នាទេះ "សំណួរ៖ តើអង្គការបញ្ជូនលោកទៅច្បាំងជាមួយវៀតណាមនៅពេលណា?" ខ្ញុំសូមបញ្ជាក់ថា គង់ គីម ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងនោះពីរបីខែ ហើយគេបញ្ជូនគាត់ពីព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងហើយទៅច្បាំងជាមួយវៀតណាម។ "អ៊ីចឹងតើពេលគេបញ្ជូនលោកទៅច្បាំងជាមួយវៀតណាមនៅពេលណា? ចម្លើយ៖ ដើមឆ្នាំ១៩៧៧ ក្រុមយើងហ្នឹងត្រូវបានរៀបចំដើម្បីច្បាំងជាមួយវៀតណាម។ យើងចេញទៅតាមផ្លូវជាតិលេខ៥ បន្ទាប់មកទៀតទៅកាត់តាមកំពង់ចាម។ សំណួរ៖ មុននឹងចេញទៅច្បាំងជាមួយវៀតណាមតើអង្គការមានបាននិយាយអំពីយុទ្ធសាស្ត្រ ឬក៏មូលហេតុដែលត្រូវច្បាំងជាមួយវៀតណាមដែរឬទេ? ចម្លើយ៖ ពីដើមបើពីដំបូងនៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងមានកិច្ចប្រជុំមួយ ពេលនោះគេនិយាយថា វៀតណាមសម្លាប់ប្រជាជនខ្មែរ ធ្វើឱ្យយើងឈឺចាប់ ពួកគេឈ្លានពានយើងចូលមកដល់ទន្លេមេគង្គ ដុតផ្ទះ ដុតស្រូវ។ ហើយនៅពេលប្រជុំនេះ ខ្ញុំត្រូវបានកាន់តួនាទីជាប្រធានអនុសេនាតូច...។ល។" សំណួរខ្ញុំដូចតទៅ តើនៅពេលណាមួយនោះលោកមានធ្លាប់ឮគេនិយាយអំពីកិច្ចប្រជុំដែលមេៗ ដឹកនាំធ្វើមេៗនៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងដឹកនាំធ្វើដែរឬទេ? ហើយនៅក្នុងកិច្ចប្រជុំហ្នឹង គេនិយាយអំពី

ជម្លោះប្រដាប់អាវុធជាមួយវៀតណាម?

**ឆ៖** បាទ ខ្ញុំអត់មានឮៗគេនិយាយផង។ អត់ឮគេនិយាយពីរឿងជម្លោះអាវុធជម្លោះអី និង បញ្ជូនទៅណាទៅណី ខ្ញុំអត់បានទៅនឹងគេទេ នៅតែព្រលានហ្នឹង ទាល់តែរត់ដូចខ្ញុំជម្រាបអ៊ីចឹង ទាល់តែរត់បានដឹង។ ដឹងគេបញ្ជូនទៅថ្នើរណា គេជម្លោះប្រដាប់អាវុធថ្នើរណា ខ្ញុំអត់ដឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំសួរចប់ហើយលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃ នៅរសៀលថ្ងៃស្អែក ថ្ងៃសុក្រ ទី១២ ខែមិថុនា ឆ្នាំ២០១៥ ដែលនឹងចាប់ផ្ដើមពីម៉ោងមួយកន្លះរសៀល។ ហើយសវនាការនៅរសៀលថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-932 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក កែវ គីន ដែលបានចំណាយពេលវេលាដ៏មានតម្លៃផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សី ក្នុងរយៈពេល២ថ្ងៃកន្លងទៅនេះ។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនេះ។ ការផ្ដល់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ វត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានជួបតែសំណាងល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក កែវ គីន វិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប ខៀវ សំផន និង នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញនៅរសៀលថ្ងៃស្អែកឲ្យបានមុនម៉ោងមួយកន្លះ។ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*